ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ



# ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍កៅស៊ូធម្មជាតិ ឆ្ពោះទៅឆ្នាំ២០៣០

ឆ្នាំ២០២០






# អារម្ភកថា

កៅស៊ូធម្មជាតិ គឺជាដំណាំកសិឧស្សាហកម្មរយៈពេលវែងមួយប្រភេទ ដែលមានតួនាទីយ៉ាងសំខាន់ និងផ្តល់ផលប្រយោជន៍ដល់សេដ្ឋកិច្ចជាតិ សង្គម ជាពិសេសបានផ្តល់ចំណូលសម្រាប់បង្កើនជីវភាពរស់នៅ និងបង្កើតការងារនៅតាមមូលដ្ឋានជនបទ។ លើសពីនេះទៅទៀត កៅស៊ូធម្មជាតិក៏បានចូលរួមចំណែកយ៉ាងសកម្មនៅក្នុងការការពារបរិស្ថានប្រកបដោយចីរភាព បង្កើតជាគម្របបៃតង រក្សាលំនឹងធម្មជាតិ និងការពារការហូរច្រោះដី។

ជាការពិត កំណើននៃការអភិវឌ្ឍកៅស៊ូធម្មជាតិដ៏មានសក្តានុពលនេះ គឺអាស្រ័យទៅលើកត្តាជាច្រើនដែលបានផ្តល់ភាពអនុគ្រោះដល់ដំណាំកៅស៊ូនៅកម្ពុជា រួមមាន៖ (១) ប្រទេសកម្ពុជាបានទទួលសុខសន្តិភាព សុវត្ថិភាពល្អប្រសើរ ក្រោមការដឹកនាំដ៏ឈ្លាសវៃ និងប្រកបដោយគតិបណ្ឌិតដ៏ខ្ពង់ខ្ពស់បំផុតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា (២) រាជរដ្ឋាភិបាលបានដាក់ចេញគោលនយោបាយសេរីភាវូបនីយកម្មផ្នែកសេដ្ឋកិច្ច សំដៅជំរុញការធ្វើវិនិយោគគ្រប់វិស័យ ជាពិសេសគោលនយោបាយលើកទឹកចិត្តដល់កសិករឱ្យចូលរួមដាំដុះកៅស៊ូលើដីចម្ការរបស់ខ្លួន និង (៣) កម្ពុជានៅតែមានសក្តានុពលខ្ពស់ក្នុងការអភិវឌ្ឍដំណាំកៅស៊ូ ទាំងនៅក្នុងតំបន់ប្រពៃណី (ដែលសម្បូរទៅដោយដីក្រហម) ក៏ដូចជានៅក្នុងតំបន់មិនមែនប្រពៃណី (រួមមានដីប្រផេះ ដីខ្មៅ ឬដីល្បាយខ្សាច់) ដែលស្ថិតនៅភាគខាងលិច ខាងជើង និងភាគឦសាននៃប្រទេស។

នៅក្នុង “យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤” និង “ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ២០១៩-២០២៣” រាជរដ្ឋាភិបាលបានចាត់ទុកវិស័យកសិកម្មជាវិស័យអាទិភាពមួយក្នុងចំណោមវិស័យដទៃទៀត ដែលបានរួមចំណែករុញកំណើនផលទុនជាតិក្នុងការអភិវឌ្ឍសេដ្ឋកិច្ច ផ្តល់ការងារ និងប្រាក់ចំណូលដល់ប្រជាពលរដ្ឋនៅជនបទ ដែលមានជីវភាពរស់នៅពឹងអាស្រ័យលើការងារកសិកម្ម។

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍កៅស៊ូធម្មជាតិឆ្ពោះទៅឆ្នាំ២០៣០ត្រូវបានរៀបចំឡើង ដើម្បីរួមចំណែកឆ្លើយតប និងសម្រេចនូវចក្ខុវិស័យរបស់រាជរដ្ឋាភិបាល ព្រមទាំងមានសង្គតិភាពទៅនឹងផែនការមេវិស័យកសិកម្មឆ្នាំ២០៣០ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ ម្យ៉ាងវិញទៀត ផែនការយុទ្ធសាស្ត្រនេះជាមគ្គុទេសក៍គ្រឹះសម្រាប់អនុវត្តផែនការសកម្មភាពរបស់អគ្គនាយកដ្ឋានកៅស៊ូ រួមជាមួយនឹងដៃគូពាក់ព័ន្ធទាំងអស់ ដោយយកចិត្តទុកដាក់ជាសំខាន់ធ្វើការដោះស្រាយលើបញ្ហាប្រឈមនានា និងផ្តល់យន្តការសំខាន់ៗនៅក្នុងការអភិវឌ្ឍអនុវិស័យកៅស៊ូប្រកបដោយនិរន្តរភាព។ ចក្ខុវិស័យចម្បងនៃផែនការយុទ្ធសាស្ត្រនេះ គឺធ្វើឱ្យកៅស៊ូធម្មជាតិកម្ពុជាជាអនុវិស័យមានលក្ខណៈបរិយាប័ន្ន និងប្រកួតប្រជែង ដែលផ្តល់ផលប្រយោជន៍ប្រកបដោយនិរន្តរភាពដល់គ្រប់ភាគីពាក់ព័ន្ធទាំងអស់។ គោលដៅចម្បងឆ្នាំ២០៣០ ដែលត្រូវសម្រេចក្នុងផែនការយុទ្ធសាស្ត្រនេះគឺ៖ (១) បង្កើនផ្ទៃដីយកផលឱ្យបានចំនួនប្រមាណ ៣៣១ពាន់ហិកតា (២) បង្កើនទិន្នផលកៅស៊ូឱ្យបានចំនួនប្រមាណ ១ ៤០០គ.ក្រ./ហិកតា/ឆ្នាំ (៣) បង្កើនផលិតផលកៅស៊ូឱ្យបានចំនួនប្រមាណ ៤៦៣ពាន់តោន (៤) បង្កើនការនាំចេញកៅស៊ូឱ្យបានចំនួនប្រមាណ ៤៤៩ពាន់តោន និង(៥) បង្កើនផលចំណូលសរុបពីផលិតផលកៅស៊ូឱ្យបានចំនួនប្រមាណ ៩៦១លានដុល្លារអាមេរិក។ ដើម្បីសម្រេចគោលដៅនៃផែនការយុទ្ធសាស្ត្រនេះ ស្នូលយុទ្ធសាស្ត្រសម្រាប់អភិវឌ្ឍកៅស៊ូធម្មជាតិចំនួន៤ ត្រូវបានដាក់ចេញគឺ៖ (១) ការពង្រីក និងការធ្វើឱ្យប្រសើរឡើងនូវខ្សែច្រវាក់ផលិតកម្មកៅស៊ូ (២) ការលើកកម្ពស់ការងារពិសោធ និងការស្រាវជ្រាវកៅស៊ូ (៣) ការពង្រឹងសេវាគាំទ្រ និងគ្រប់គ្រងអង្គភាព និង (៤) ការជំរុញវិនិយោគ និងហិរញ្ញប្បទានតាមរយៈដៃគូក្នុងការអភិវឌ្ឍកៅស៊ូធម្មជាតិ។







ក្នុងនាមក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខ្ញុំមានជំនឿយ៉ាងមុតមាំថា ផែនការសកម្មភាពដែលមាននៅក្នុងផែនការយុទ្ធសាស្ត្រនេះ ពិតជាត្រូវបានអនុវត្តជាក់ស្តែង ដោយមានការចូលរួមយ៉ាងសកម្មពីគ្រប់ដៃគូ និងស្ថាប័នពាក់ព័ន្ធទាំងអស់ ដែលធ្វើឱ្យដំណើរការអនុវត្តផែនការយុទ្ធសាស្ត្រនេះទទួលបានលទ្ធផលប្រកបដោយប្រសិទ្ធភាពតាមផែនការ និងការរំពឹងទុក សម្រាប់ចូលរួមចំណែកក្នុងការសម្រេចបាននូវចក្ខុវិស័យរបស់រាជរដ្ឋាភិបាល ក្នុងការប្រែក្លាយប្រទេសកម្ពុជាពីប្រទេសដែលមានចំណូលមធ្យមកម្រិតទាប បន្តឆ្ពោះទៅសម្រេចបានជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០។

ថ្ងៃ ចន្ទ ១៣ កើត ខែ អស្សុជ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ តុលា ឆ្នាំ២០២១

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**វេង សាខុន**






# មាតិកា

## ផ្នែកទី១

## ការវិភាគស្ថានភាពកៅស៊ូធម្មជាតិឆ្នាំ២០១០-២០១៩

**១. សេចក្តីផ្តើម** ......................................................................... **១**

១.១ សាវតារ ......................................................................... ១

១.២ ការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍កៅស៊ូធម្មជាតិឆ្ពោះទៅឆ្នាំ២០៣០ ........................ ៣

១.៣ ទម្រង់នៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍កៅស៊ូធម្មជាតិឆ្ពោះទៅឆ្នាំ២០៣០ ........................ ៤

**២ ការវិភាគស្ថានភាពកៅស៊ូធម្មជាតិពិភពលោក** ......................................................... **៥**

២.១ ការផ្គត់ផ្គង់និងតម្រូវការកៅស៊ូធម្មជាតិ ......................................................... ៥

២.២ ថ្លៃកៅស៊ូធម្មជាតិ ......................................................................... ៦

២.៣ ទស្សនវិស័យកៅស៊ូពិភពលោក ......................................................... ៦

**៣ ការវិភាគស្ថានភាពកៅស៊ូធម្មជាតិនៅកម្ពុជា** ......................................................... **៧**

៣.១ ផ្ទៃដី ......................................................................... ៧

៣.២ ផលិតកម្ម ......................................................................... ៩

៣.៣ ការកែច្នៃ ......................................................................... ៩

៣.៤ ការនាំចេញ ......................................................................... ៩

៣.៦ ការស្រាវជ្រាវនិងពិសោធន៍ ......................................................................... ១១

៣.៦.១ ការអភិវឌ្ឍពូជកៅស៊ូ ......................................................................... ១១

៣.៦.២ ការរៀបចំអនុសាសន៍ក្លូនកៅស៊ូ ......................................................................... ១២

៣.៦.៣ ផ្នែកដាំដុះនិងការពារ ......................................................................... ១៣

៣.៦.៤ ផ្នែកសរីរសាស្ត្រនិងការយកផលទឹកជ័រ ......................................................................... ១៣

៣.៦.៥ ផ្នែកមន្ទីរពិសោធជាតិយថាប្រភេទ ......................................................................... ១៤

៣.៦.៦ ចម្ការពិសោធ ......................................................................... ១៥

៣.៧ ការបណ្តុះបណ្តាលនិងផ្ទេរបច្ចេកវិទ្យា ......................................................................... ១៥

៣.៨ កម្លាំងពលកម្ម ......................................................................... ១៦

៣.៩ កិច្ចសហប្រតិបត្តិការរវាងវិស័យសាធារណៈ ឯកជន និងដៃគូអភិវឌ្ឍន៍ ......................................... ១៦

**៤ បញ្ហាប្រឈមនិងកត្តាអំណោយផល** ......................................................................... **១៧**

៤.១ ការវិភាគ SWOT ......................................................................... ១៧

៤.១.១ កត្តាខាងក្នុង (Internal factor) ......................................................................... ១៨

៤.១.២ កត្តាខាងក្រៅ (External factor) ......................................................................... ១៨

**៥. និន្នាការវិវត្តនៃកៅស៊ូធម្មជាតិ** ......................................................................... **១៩**

**៦. សន្និដ្ឋាន** ......................................................................... **១៩**





# ផ្នែកទី២
# ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍កៅស៊ូធម្មជាតិឆ្ពោះទៅឆ្នាំ២០៣០


**១. សេចក្តីផ្តើម** ........ **២០**
**២. ចក្ខុវិស័យ** ........ **២០**
**៣. បេសកកម្ម** ........ **២១**
**៤. គោលបំណងនិងគោលដៅ** ........ **២១**
៤.១ គោលបំណង ........ ២១
៤.២ គោលដៅ ........ ២១
**៥. ក្របខណ្ឌយុទ្ធសាស្ត្រ** ........ **២១**
៥.១ ការវិភាគ TOWS ........ ២១
៥.២ ស្នូលយុទ្ធសាស្ត្រ ........ ២៤
៥.២.១ សូចនាករសមិទ្ធកម្ម ........ ២៦
៥.២.២ យុទ្ធសាស្ត្រទី១៖ ការពង្រីកនិងការធ្វើឱ្យប្រសើរឡើងនូវខ្សែច្រវាក់ផលិតកម្មកៅស៊ូ ........ ៣០
៥.២.៣ យុទ្ធសាស្ត្រទី២៖ ការលើកកម្ពស់ការងារពិសោធនិងការស្រាវជ្រាវកៅស៊ូ ........ ៣៨
៥.២.៤ យុទ្ធសាស្ត្រទី៣៖ ការពង្រឹងសេវាគាំទ្រនិងអង្គភាព ........ ៤២
៥.២.៥ យុទ្ធសាស្ត្រទី៤៖ ការជំរុញវិនិយោគនិងហិរញ្ញប្បទានតាមរយៈដៃគូក្នុងការអភិវឌ្ឍកៅស៊ូធម្មជាតិ ........ ៤៦
**៦. រចនាសម្ព័ន្ធនៃការអនុវត្ត ការតាមដានត្រួតពិនិត្យ និងការវាយតម្លៃ ផែនការយុទ្ធសាស្ត្រ ៥៥**
៦.១ រចនាសម្ព័ន្ធនៃការអនុវត្ត ........ ៥៥
៦.២ ការតាមដាន ត្រួតពិនិត្យ និងការវាយតម្លៃ ........ ៥៦
**៧. កត្តារាំងនៅពេលអនុវត្ត** ........ **៥៧**
**៨. សន្និដ្ឋាន** ........ **៥៨**






# តារាង


តារាងទី១ ៖ ការផ្គត់ផ្គង់និងតម្រូវការកៅស៊ូធម្មជាតិពិភពលោក .......... ៧
តារាងទី២ ៖ សមិទ្ធផលនៃការងារផ្នែកបង្កាត់និងជម្រើសពូជកៅស៊ូ .......... ១២
តារាងទី៣ ៖ អនុសាសន៍ក្លូនកៅស៊ូនៅកម្ពុជាសម្រាប់ឆ្នាំ២០១៨-២០២០ .......... ១៣
តារាងទី៤ ៖ ស្ថិតិសំណាកទឹកជ័រដែលបានវិភាគសរីរសាស្ត្ររយៈពេល៥ឆ្នាំ ២០១៤-២០១៨.......... ១៤
តារាងទី៥ ៖ បទដ្ឋានកំណត់យថាប្រភេទកៅស៊ូកម្ពុជា(CSR) .......... ១៤
តារាងទី៦ ៖ ចំនួនភាគសំណាកកៅស៊ូ CSR (២០១០-២០១៩).......... ១៥
តារាងទី៧ ៖ ការវិភាគម៉ាទ្រីកTOWS សម្រាប់យុទ្ធសាស្ត្រដោះស្រាយភាពខ្សោយនិងភាពគំរាមកំហែង.......... ២២
តារាងទី៨ ៖ ស្នូលយុទ្ធសាស្ត្រសម្រាប់ដោះស្រាយបញ្ហាប្រឈម .......... ២៥
តារាងទី៩ ៖ ចំណុចដៅនៃសមិទ្ធកម្មផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍កៅស៊ូធម្មជាតិឆ្ពោះទៅឆ្នាំ២០៣០.......... ២៨
តារាងទី១០ ៖ អត្រាកំណើននៃសូចនាករសំខាន់ៗ (%).......... ២៩
តារាងទី១១ ៖ គម្រោងចំណាយលើយុទ្ធសាស្ត្រទី១.......... ៣០
តារាងទី១២ ៖ សូចនាករ និងគោលដៅ កម្មវិធី/គម្រោងទី១.១ នៃយុទ្ធសាស្ត្រទី១ .......... ៣១
តារាងទី១៣ ៖ សូចនាករ និងគោលដៅ កម្មវិធី/គម្រោងទី១.២ នៃយុទ្ធសាស្ត្រទី១ .......... ៣២
តារាងទី១៤ ៖ សូចនាករ និងគោលដៅ កម្មវិធី/គម្រោងទី១.៣ នៃយុទ្ធសាស្ត្រទី១ .......... ៣៣
តារាងទី១៥ ៖ សូចនាករ និងគោលដៅ កម្មវិធី/គម្រោងទី១.៤ នៃយុទ្ធសាស្ត្រទី១ .......... ៣៤
តារាងទី១៦ ៖ សូចនាករ និងគោលដៅ កម្មវិធី/គម្រោងទី១.៥ នៃយុទ្ធសាស្ត្រទី១ .......... ៣៥
តារាងទី១៧ ៖ សូចនាករ និងគោលដៅ កម្មវិធី/គម្រោងទី១.៦ នៃយុទ្ធសាស្ត្រទី១ .......... ៣៥
តារាងទី១៨ ៖ សូចនាករ និងគោលដៅ កម្មវិធី/គម្រោងទី១.៧ នៃយុទ្ធសាស្ត្រទី១ .......... ៣៦
តារាងទី១៩ ៖ គម្រោងចំណាយលើយុទ្ធសាស្ត្រទី២ .......... ៣៨
តារាងទី២០ ៖ សូចនាករ និងគោលដៅ កម្មវិធី/គម្រោងទី២.១ នៃយុទ្ធសាស្ត្រទី២ .......... ៣៩
តារាងទី២១ ៖ សូចនាករ និងគោលដៅ កម្មវិធី/គម្រោងទី២.២ នៃយុទ្ធសាស្ត្រទី២ .......... ៤០
តារាងទី២២ ៖ សូចនាករ និងគោលដៅ កម្មវិធី/គម្រោងទី២.៣ នៃយុទ្ធសាស្ត្រទី២ .......... ៤១
តារាងទី២៣ ៖ គម្រោងចំណាយលើយុទ្ធសាស្ត្រទី៣ .......... ៤២
តារាងទី២៤ ៖ សូចនាករ និងគោលដៅ កម្មវិធី/គម្រោងទី៣.១ នៃយុទ្ធសាស្ត្រទី៣ .......... ៤៣
តារាងទី២៥ ៖ សូចនាករ និងគោលដៅ កម្មវិធី/គម្រោងទី៣.២ នៃយុទ្ធសាស្ត្រទី៣ .......... ៤៤
តារាងទី២៦ ៖ សូចនាករ និងគោលដៅ កម្មវិធី/គម្រោងទី៣.៣ នៃយុទ្ធសាស្ត្រទី៣ .......... ៤៤
តារាងទី២៧ ៖ សូចនាករ និងគោលដៅ កម្មវិធី/គម្រោងទី៣.៤ នៃយុទ្ធសាស្ត្រទី៣ .......... ៤៥
តារាងទី២៨ ៖ គម្រោងចំណាយលើយុទ្ធសាស្ត្រទី៤.......... ៤៦
តារាងទី២៩ ៖ សូចនាករ និងគោលដៅ កម្មវិធី/គម្រោងទី៤.១ នៃយុទ្ធសាស្ត្រទី៤ .......... ៤៧
តារាងទី៣០ ៖ សូចនាករ និងគោលដៅ កម្មវិធី/គម្រោងទី៤.២ នៃយុទ្ធសាស្ត្រទី៤ .......... ៤៨
តារាងទី៣១ ៖ សូចនាករ និងគោលដៅ កម្មវិធី/គម្រោងទី៤.៣ នៃយុទ្ធសាស្ត្រទី៤ .......... ៤៩
តារាងទី៣២ ៖ សូចនាករ និងគោលដៅ កម្មវិធី/គម្រោងទី៤.៤ នៃយុទ្ធសាស្ត្រទី៤ .......... ៥០







តារាងទី៣៣៖ សូចនាករ និងគោលដៅ កម្មវិធី/គម្រោងទី៤.៥ នៃយុទ្ធសាស្ត្រទី៤ ..................................... ៥១
តារាងទី៣៤៖ សូចនាករ និងគោលដៅ កម្មវិធី/គម្រោងទី៤.៦ នៃយុទ្ធសាស្ត្រទី៤ ..................................... ៥២
តារាងទី៣៥៖ សូចនាករ និងគោលដៅ កម្មវិធី/គម្រោងទី៤.៧ នៃយុទ្ធសាស្ត្រទី៤ ..................................... ៥២
តារាងទី៣៦៖ សូចនាករ និងគោលដៅ កម្មវិធី/គម្រោងទី៤.៨ នៃយុទ្ធសាស្ត្រទី៤ ..................................... ៥៣
តារាងទី៣៧៖ សូចនាករ និងគោលដៅ កម្មវិធី/គម្រោងទី៤.៩ នៃយុទ្ធសាស្ត្រទី៤ ..................................... ៥៤
តារាងទី៣៨៖ អង្គភាពសំខាន់ៗដែលអនុវត្តនិងតួនាទីចំបងៗ ..................................................................... ៥៥






# រូបភាព


រូបភាពទី១ ៖ ការផ្គត់ផ្គង់និងតម្រូវការកៅស៊ូធម្មជាតិពិភពលោកឆ្នាំ២០១០-២០១៩ .................................... ៥

រូបភាពទី២ ៖ ផែនទីបង្ហាញទីតាំងចម្ការកៅស៊ូកសិឧស្សាហកម្មនិងកៅស៊ូគ្រួសារនៅកម្ពុជា ឆ្នាំ២០១៩ ............. ៨

រូបភាពទី៣ ៖ ការវិវត្តនៃទិន្នផលកៅស៊ូរយៈពេល១០ឆ្នាំ ............................................................... ៨

រូបភាពទី៤ ៖ ការនាំចេញនិងថ្លៃកៅស៊ូ (២០១០-២០១៩)................................................................ ១០

រូបភាពទី៥ ៖ ការប្រៀបធៀបតម្លៃកៅស៊ូកម្ពុជានិងម៉ាឡេស៊ី(២០១០-២០១៩) ......................................... ១១

រូបភាពទី៦ ៖ កម្លាំងពលកម្មក្នុងអនុវិស័យកៅស៊ូឆ្នាំ២០១០-២០១៩ (ពាន់នាក់) ...................................... ១៦

រូបភាពទី៧ ៖ ក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍កៅស៊ូធម្មជាតិឆ្ពោះទៅឆ្នាំ២០៣០..............................២៦






# ឧបសម្ព័ន្ធ


ឧបសម្ព័ន្ធទី១ ៖ ស្ថិតិផ្ទៃដីកៅស៊ូសរុប ផ្ទៃដីកៅស៊ូយកផល និងផលិតផលឆ្នាំ២០១០-២០១៩ ........................ ៥៩

ឧបសម្ព័ន្ធទី២ ៖ ស្ថិតិនៃការបង្កើតថ្មីនូវរោងចក្រ សិប្បកម្មកែច្នៃផលិតផលកៅស៊ូធម្មជាតិ ឆ្នាំ២០១០-២០១៩ .. ៦០

ឧបសម្ព័ន្ធទី៣ ៖ ចម្ការពិសោធចាប់ពីឆ្នាំ១៩៩៥-២០០៦ និង ២០០៧-២០១៧ ........................................ ៦១

ឧបសម្ព័ន្ធទី៤ ៖ ការបណ្តុះបណ្តាលនិងផ្ទេរបច្ចេកវិទ្យា (នាក់) ................................................................ ៦៣

ឧបសម្ព័ន្ធទី៥ ៖ បញ្ជីសង្ខេបសកម្មភាពនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍កៅស៊ូធម្មជាតិឆ្ពោះទៅឆ្នាំ២០៣០ ....... ៦៤

ឧបសម្ព័ន្ធទី៦ ៖ គំនូសបង្រួញនៃធាតុសំខាន់ៗរបស់ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍កៅស៊ូធម្មជាតិ ..................... ៧០

ឧបសម្ព័ន្ធទី៧ ៖ ម៉ាទ្រីកនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍កៅស៊ូធម្មជាតិ ...................................................... ៧១

ឧបសម្ព័ន្ធទី៨ ៖ សំណើគម្រោងនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍កៅស៊ូធម្មជាតិឆ្ពោះទៅឆ្នាំ២០៣០ ................. ៩៦






# បញ្ជីអក្សរកាត់

| | | |
|---|---|---|
| ១. | គ.ក្រ. | : គីឡូក្រាម |
| ២. | ន.ក.ផ.ក. | : នាយកដ្ឋានកែច្នៃផលិតផលកៅស៊ូ |
| ៣. | ន.ទ.ស.អ. | : នាយកដ្ឋានទីផ្សារ និងសហប្រតិបត្តិការអន្តរជាតិ |
| ៤. | ន.ផ.ហ.ស. | : នាយកដ្ឋានផែនការ ហិរញ្ញវត្ថុ និងស្ថិតិ |
| ៥. | ន.រ.ន. | : នាយកដ្ឋានរដ្ឋបាល និងនីតិកម្ម |
| ៦. | ន.អ.ក. | : នាយកដ្ឋានអភិវឌ្ឍន៍កៅស៊ូ |
| ៧. | ម.ក.រ.ន. | : មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត |
| ៨. | ហ.ត. | : ហិកតា |
| ៩. | អ.ក. | : អគ្គនាយកដ្ឋានកៅស៊ូ |
| ១០. | ADS | : Air-Dried Sheet |
| ១១. | AFD | : Agence Française De Développement |
| ១២. | ANRPC | : Association of Natural Rubber Producing Countries |
| ១៣. | ARBC | : Asean Rubber Business Council |
| ១៤. | ASDP | : Agriculture Strategic Development Plan |
| ១៥. | CATAS | : Chinese Academy of Tropical Agricultural Sciences |
| ១៦. | CIRAD | : Centre de Coopération Internationale en Recherche Agronomique pour le Développement |
| ១៧. | CRRI | : Cambodian Rubber Research Institute |
| ១៨. | CSR | : Cambodian Specified Rubber |
| ១៩. | d3 | : Third Daily Tapping (once in three days) |
| ២០. | d4 | : Fourth Daily Tapping (once in four days) |
| ២១. | d5 | : Fifth Daily Tapping (once in five days) |
| ២២. | d6 | : Sixth Daily Tapping (once in six days) |
| ២៣. | FAO | : Food and Agriculture Organization |
| ២៤. | GAP | : Good Agriculture Practice |
| ២៥. | GIS | : Geographic Information System |
| ២៦. | GPP | : Good Processing Practices |
| ២៧. | IMF | : International Monetary Fund |
| ២៨. | IRA | : International Rubber Association |
| ២៩. | IRRDB | : International Rubber Research and Development Board |
| ៣០. | IRSG | : International Rubber Study Group |
| ៣១. | ITRC | : International Tripartite Rubber Council |
| ៣២. | NSDP | : National Strategic Development Plan |
| ៣៣. | OPEC | : Organization of the Petroleum Exporting Countries |






៣៤. RSS : Ribbed Smoked Sheet
៣៥. SMR : Standard Malaysian Rubber
៣៦. SWOT : Strengths, Weaknesses, Opportunities and Threats
៣៧. TOWS : Threats, Opportunities, Weaknesses and Strengths
៣៨. TSR : Technically Specified Rubber






# ផ្នែកទី១
# ការវិភាគស្ថានភាពកៅស៊ូធម្មជាតិឆ្នាំ២០១០-២០១៩

## ១. សេចក្តីផ្តើម

### ១.១ សាវតារ

១- កៅស៊ូធម្មជាតិ គឺជាដំណាំយុទ្ធសាស្ត្រនិងសេដ្ឋកិច្ចមួយប្រភេទដែលផ្តល់ប្រយោជន៍ជាច្រើនដល់អ្នកដាំ ដល់សេដ្ឋកិច្ចជាតិ ដល់សង្គមទាំងមូល និងបរិស្ថាន ជាពិសេសបានចូលរួមលើកកម្ពស់ប្រាក់ចំណូលសេដ្ឋកិច្ចជាតិនិងសេដ្ឋកិច្ចគ្រួសារកសិករ ចូលរួមកាត់បន្ថយភាពក្រីក្រ តាមរយៈការបង្កើតការងារនិងមុខរបរមានស្ថិរភាពជូនប្រជាពលរដ្ឋនៅតាមតំបន់ជនបទ និងកាត់បន្ថយការធ្វើចំណាកស្រុក ផ្តល់ជាវត្ថុធាតុដើមសម្រាប់វិស័យឧស្សាហកម្ម ផលិតជាមុខទំនិញរាប់ពាន់មុខសម្រាប់បម្រើតម្រូវការប្រើប្រាស់ប្រចាំថ្ងៃដូចជា៖ សំបកកង់យានយន្ត សម្ភារក្នុងលំនៅដ្ឋាន និងក្នុងផ្នែកវេជ្ជសាស្ត្រ (ស្រោមដៃពេទ្យ ស្រោមអនាម័យ។ល។) ប្រើជាកំណល់សំណង់អាគារ ផ្លូវថ្នល់ និងស្ពានធំៗទប់ទល់ការជួលរលំដោយសាររញ្ជួយផែនដី។ល។ ផ្តល់ឈើសម្រាប់ប្រើប្រាស់ក្នុងវិស័យ សំណង់ ផលិតគ្រឿងសង្ហារឹម ជាឈើតន្ទនៈ ចូលរួមចំណែកជួយកាត់បន្ថយការកាប់បំផ្លាញព្រៃឈើធម្មជាតិ ការពារការហូរច្រោះដី និងជាគម្របបៃតងឡើងវិញ ដើម្បីចូលរួមក្នុងការថែរក្សាលំនឹងបរិស្ថាន ដោយកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ និងកាត់បន្ថយបម្រែបម្រួលអាកាសធាតុ ដែលជាបញ្ហាប្រឈមរបស់ពិភពលោកសំខាន់មួយ នាពេលបច្ចុប្បន្ននិងទៅអនាគត។

២- ដំណាំកៅស៊ូត្រូវបានដាំជាលើកដំបូងក្នុងប្រវត្តិសាស្ត្រកម្ពុជានាឆ្នាំ១៩១០ ដោយលោក **ប៊ូ យ៉ា** ជនជាតិបារាំង នៅក្នុងស្រុកព្រៃនប់ ខេត្តកំពត (បច្ចុប្បន្នខេត្តព្រះសីហនុ) លើផ្ទៃដីជាង ១៥០ហិកតា បន្ទាប់ក្រោយមកស្ថិតនៅអូរពោធិ៍ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ (បច្ចុប្បន្នខេត្តព្រះវិហារ) មានចម្ការកៅស៊ូមួយទៀតបានធ្វើការដាំដុះលើផ្ទៃដី ១២០ហិកតា និងបានធ្វើអាជីវកម្មលើផ្ទៃដីចំនួន ៨០ហិកតា។ ដល់ឆ្នាំ១៩២១ ទើបដំណាំកៅស៊ូជាលក្ខណៈឧស្សាហកម្មទ្រង់ទ្រាយធំ ត្រូវបានបង្កើតឡើងដោយក្រុមហ៊ុនវិនិយោគរបស់បារាំងធំៗចំនួន៥ នៅលើដីក្រហមបាសាល់នាខេត្តកំពង់ចាម ខេត្តក្រចេះ និងខេត្តរតនគិរី លើផ្ទៃដីទំហំជាង ៥០ ០០០ហិកតា។ ក្រោយពីបានទទួលឯករាជ្យពីអាណានិគមបារាំង ដោយមានការផ្តួចផ្តើមគំនិត និងការជំរុញយ៉ាងសកម្មរបស់ក្រុមហ៊ុនចម្ការកៅស៊ូកសិឧស្សាហកម្មបរទេសធំៗ ឈានមកដល់ដំណាក់កាលខ្ពស់បំផុតនៅចុងឆ្នាំ១៩៦៧ ដែលមានផ្ទៃដីកៅស៊ូសរុបចំនួន ៦៤ ០៥៤ហិកតា ក្នុងនោះផ្ទៃដីចៀរជ័រមានចំនួន ៣៥ ៤៦៣ហិកតា ដែលផលិតបានជ័រកៅស៊ូចំនួន ៥៣ ៧១៦តោន។ ជាមួយគ្នានោះ ផ្ទៃដីចម្ការកៅស៊ូគ្រួសារតូចតាចនិងមធ្យមដែលមានទីតាំងនៅក្បែរចម្ការកៅស៊ូកសិឧស្សាហកម្មធំៗ មានចំនួនជាង ១០ ០០០ហិកតា ផងដែរ។

៣- ចាប់ពីឆ្នាំ១៩៧០ មកដល់ឆ្នាំ១៩៧៩ ចម្ការកៅស៊ូមួយផ្នែកធំបានទទួលរងការបំផ្លិចបំផ្លាញយ៉ាងធ្ងន់ធ្ងរដោយសារសង្គ្រាម ជាពិសេសនៅក្រោមការគ្រប់គ្រងនៃរបបខ្មែរក្រហម។

៤- ក្រោយថ្ងៃរំដោះ៧មករា ឆ្នាំ១៩៧៩ រដ្ឋាភិបាលកម្ពុជាបានប្រមូលផ្តុំចម្ការកៅស៊ូកសិឧស្សាហកម្មធំៗដែលនៅសេសសល់ក្រោយសម័យសង្គ្រាម ដើម្បីស្តារនិងដំណើរការធ្វើអាជីវកម្មឡើងវិញជាបន្តបន្ទាប់តាមរយៈការបង្កើតជាអង្គភាពចម្ការកៅស៊ូរដ្ឋ ក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់





និងនេសាទ។ រហូតដល់ឆ្នាំ១៩៨២ អង្គភាពចម្ការកៅស៊ូបានផ្តាច់ចេញពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដោយបង្កើតជាអគ្គនាយកដ្ឋានចំការកៅស៊ូ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី រួមមានបីក្រុមហ៊ុន គឺ (១) ក្រុមហ៊ុនចម្ការកៅស៊ូ៧មករា (២) ក្រុមហ៊ុនចម្ការកៅស៊ូមេមត់ (៣) ក្រុមហ៊ុនចម្ការកៅស៊ូត្រើយស្លាំទន្លេមេគង្គ(*សេចក្តីសម្រេចលេខ១៤៥៩.៣៧០ អក.ចត ចុះថ្ងៃទី៤ ខែតុលា ឆ្នាំ ១៩៨២ ស្តីពីការបង្កើតក្រុមហ៊ុនចម្ការកៅស៊ូ០៧មករា*)។ នៅឆ្នាំ១៩៩០ រដ្ឋាភិបាលរដ្ឋកម្ពុជាបានសម្រេចបំបែកចេញជាក្រុមហ៊ុនតូចៗចំនួន៦ ក្រោមរូបភាពជាអង្គភាពស្វយ័យាភិបាលសេដ្ឋកិច្ច ស្ថិតក្រោមការគ្រប់គ្រងរបស់រដ្ឋ ក្រុមហ៊ុនទាំងនោះរួមមាន (១) ក្រុមហ៊ុន៧មករា (២) ក្រុមហ៊ុនមិត្តភាព (៣) ក្រុមហ៊ុនសាមគ្គី (៤) ក្រុមហ៊ុនក្រែក (៥) ក្រុមហ៊ុនបឹងកេត និង(៦) ក្រុមហ៊ុន២ធ្នូ (*ក្រឹត្យលេខ ១២ក្រ ចុះថ្ងៃទី ១០ ខែកុម្ភៈ ឆ្នាំ១៩៩០*)។ នៅឆ្នាំ១៩៩៣ ក្រុមហ៊ុនចម្ការកៅស៊ូទាំងអស់បានប្តូរឈ្មោះមកជា (១) ក្រុមហ៊ុនចម្ការកៅស៊ូជុប (២) ក្រុមហ៊ុនចម្ការកៅស៊ូក្រែក (៣) ក្រុមហ៊ុនចម្ការកៅស៊ូមេមត់ (៤) ក្រុមហ៊ុនចម្ការកៅស៊ូស្នួល (៥) ក្រុមហ៊ុនចម្ការកៅស៊ូចំការអណ្តូង និង (៦) ក្រុមហ៊ុនចម្ការកៅស៊ូបឹងកេត ជាមួយគ្នានោះ មូលដ្ឋានចម្ការកៅស៊ូតាប៉ាវបានបំបែកចេញពីក្រុមហ៊ុនចម្ការកៅស៊ូជុប បង្កើតទៅជា (៧) ក្រុមហ៊ុនចម្ការកៅស៊ូតាប៉ាវ និងនៅឆ្នាំ១៩៩៧ មូលដ្ឋានចម្ការកៅស៊ូពាមជាំង ក៏បានបំបែកចេញពីចម្ការកៅស៊ូជុប បង្កើតទៅជា (៨) ក្រុមហ៊ុនចម្ការកៅស៊ូពាមជាំង (*អនុក្រឹត្យលេខ៧២ អនក្រ ចុះថ្ងៃទី២៩ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការបង្កើតក្រុមហ៊ុនចំការកៅស៊ូពាមជាំង*)។

៥- តាមរយៈគោលនយោបាយបើកទូលាយរបស់រាជរដ្ឋាភិបាល នៅឆ្នាំ១៩៩៩ ក្រុមហ៊ុនចម្ការកៅស៊ូរដ្ឋទាំងអស់ត្រូវបានធ្វើអវិនិយោគ ដោយបានបង្កើតឱ្យទៅជាគ្រឹះស្ថានសាធារណៈមានលក្ខណៈសេដ្ឋកិច្ច។ បន្ទាប់មកនៅក្នុងអំឡុងឆ្នាំ២០០៨-២០០៩ ក្រុមហ៊ុនចម្ការកៅស៊ូរដ្ឋទាំងអស់ត្រូវបានធ្វើអវិនិយោគទាំងស្រុង ដោយលក់និងជួលទៅឱ្យផ្នែកឯកជន។ បច្ចុប្បន្ននេះ នៅកម្ពុជាចម្ការកៅស៊ូទាំងអស់ត្រូវបានបែងចែកជាពីរប្រភេទគឺ៖

១. **ចម្ការកៅស៊ូកសិឧស្សាហកម្ម** ជាចម្ការកៅស៊ូដែលដាំដុះដោយរូបវន្តបុគ្គលឬនីតិបុគ្គល (ជាក្រុមហ៊ុន ជាសមាគម ជាសហគមន៍ ឬឯកជន) ក្នុងទំហំដីចាប់ពី ៤៥ហិកតាឡើងទៅ និងប្រើប្រាស់កម្លាំងពលកម្មពីខាងក្រៅ។ ចម្ការកៅស៊ូទាំងនេះរួមមាន៖

- អតីតចម្ការកៅស៊ូរដ្ឋមាន៖ ចម្ការកៅស៊ូចម្ការអណ្តូង បឹងកេត ពាមជាំង ជុប ក្រែក មេមត់ និងស្នួល ត្រូវបានផ្ទេរទៅឱ្យក្រុមហ៊ុនឯកជនគ្រប់គ្រង ចាប់តាំងពីឆ្នាំ២០០៨-២០០៩ កន្លងមក ដោយឡែកចម្ការកៅស៊ូឡាបានសៀក ខេត្តរតនគិរី ត្រូវបានជួលឱ្យវិស័យឯកជន ធ្វើការវិនិយោគស្តារ ជួល និងអភិវឌ្ឍន៍ តាំងពីឆ្នាំ១៩៩៧មក
- ចម្ការកៅស៊ូសម្បទានដីសេដ្ឋកិច្ច៖ ជាចម្ការកៅស៊ូដែលដាំដុះនៅលើសម្បទានដីសេដ្ឋកិច្ចដែលទទួលបានសម្បទានពីរាជរដ្ឋាភិបាល
- ចម្ការកៅស៊ូឯកជន។

២. **ចម្ការកៅស៊ូគ្រួសារ** ជាចម្ការកៅស៊ូដែលដាំជាលក្ខណៈគ្រួសារក្នុងទំហំដីក្រោម ៤៥ហិកតា។ ចម្ការកៅស៊ូប្រភេទនេះបានធ្វើការដាំដុះនៅលើដីចម្ការកម្មសិទ្ធរបស់ខ្លួនផ្ទាល់ ឬជាដីសម្បទានសង្គមកិច្ចដែលរដ្ឋបានបែងចែកជូនគ្រួសារនីមួយៗ។ ចម្ការកៅស៊ូទាំងនេះ មានសន្ទុះរីកចម្រើនយ៉ាងឆាប់រហ័ស អាស្រ័យដោយសារការបើកទូលាយគោលនយោបាយសេរីភាវូបនីយកម្ម របស់





រាជរដ្ឋាភិបាល និងនិន្នាការអំណោយផលនៃតម្លៃកៅស៊ូលើទីផ្សារពិភពលោក មានការកើនឡើងយ៉ាងខ្ពស់ជាបន្តបន្ទាប់ ចាប់ពីឆ្នាំ២០០៧ដល់ឆ្នាំ២០១៣។

៦- ដំណាំកៅស៊ូនៅកម្ពុជាមានសន្ទុះរីកចម្រើនយ៉ាងខ្លាំង អាស្រ័យដោយមានការគាំទ្រពីរដ្ឋាភិបាលកម្ពុជា ក្រសួងស្ថាប័នពាក់ព័ន្ធ និងម្យ៉ាងដោយសារស្ថានភាពនយោបាយ សន្តិសុខល្អប្រសើរ សក្តានុពលនៃដីសមស្រប និងគោលនយោបាយទីផ្សារសេរី លើការលក់ដូរផលិតផលកៅស៊ូគ្រួសារក្នុងស្រុក។ ទន្ទឹមនឹងនេះ ការចូលរួមពីផ្នែកឯកជន ក្នុងការធ្វើវិនិយោគលើសម្បទានដីសេដ្ឋកិច្ច និងផ្នែកកៅស៊ូគ្រួសារ បានធ្វើឱ្យផ្ទៃដីដាំដុះកៅស៊ូកើនឡើងគួរឱ្យកត់សម្គាល់។

៧- រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវ “**កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី៦នៃរដ្ឋសភា**” និង “**យុទ្ធសាស្រ្តចតុកោណដំណាក់កាលទី៤**” បំពេញតួនាទីជាឯកសារក្របខណ្ឌគោលនយោបាយគ្រប់ជ្រុងជ្រោយសម្រាប់រៀបចំ “**ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ២០១៩-២០២៣**” ក្នុងនោះនៅតែចាត់ទុកវិស័យកសិកម្មជាវិស័យអាទិភាព ដោយបានកំណត់យ៉ាងច្បាស់ថា វិស័យកសិកម្មនៅតែមានតួនាទីសំខាន់ ក្នុងការបង្កើតការងារ ការធានាសន្តិសុខស្បៀង ការអភិវឌ្ឍជនបទ និងការកាត់បន្ថយភាពក្រីក្រ។ គោលដៅផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ២០១៩-២០២៣ របស់រាជរដ្ឋាភិបាលគឺឱ្យមានកំណើនសេដ្ឋកិច្ចក្នុងអត្រាមធ្យមប្រចាំឆ្នាំរង្វង់៧% និងកាត់បន្ថយភាពក្រីក្រឱ្យស្ថិតនៅក្នុងអត្រាទាបជាង១០%។ ដើម្បីចូលរួមចំណែកសម្រេចបាននូវសមិទ្ធផលទាំងនេះ ក្នុងវិស័យកសិកម្ម រាជរដ្ឋាភិបាលនឹងផ្តោតអាទិភាពលើ៖ (១) ការជំរុញការរៀបចំនិងដាក់ឱ្យអនុវត្តផែនការមេអភិវឌ្ឍន៍វិស័យកសិកម្មឆ្នាំ២០៣០ និងផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍វិស័យកសិកម្មឆ្នាំ២០១៩-២០២៣, (២) ការបន្តជំរុញការរៀបចំការអនុម័តនិងការអនុវត្តច្បាប់ស្តីពី ការការពាររុក្ខជាតិនិងភូតគាមអនាម័យ និងច្បាប់ស្តីពីផលិតកម្មកសិកម្មតាមកិច្ចសន្យា, (៣) ការបង្កើនផលិតភាព គុណភាព និងពិពិធកម្មតាមរយៈការបង្កើនការវិនិយោគលើការស្រាវជ្រាវនិងការអភិវឌ្ឍពូជដំណាំ ពូជសត្វ និងការចិញ្ចឹមសត្វនិងត្រីដែលផ្តល់តម្លៃបន្ថែមខ្ពស់ ការជំរុញការអភិវឌ្ឍកសិដ្ឋានគំរូ ការជំរុញការផ្តល់សេវាបច្ចេកទេសកសិកម្មសមស្រប ការពង្រឹងការគ្រប់គ្រងសហគមន៍កសិកម្ម ការរៀបចំយន្តការផលិតកម្មកសិកម្មតាមកិច្ចសន្យា ការកាត់បន្ថយថ្លៃដើមផលិតកម្មនិងកែច្នៃ ការពង្រឹងគុណភាពនៃធាតុចូលកសិកម្ម ការសិក្សាការរៀបចំឱ្យមានសេវាធានារ៉ាប់រងផលិតកម្មកសិកម្ម និងការជំរុញការប្រើប្រាស់បច្ចេកវិទ្យាវៃឆ្លាតនិងឌីជីថល, (៤) ការលើកកម្ពស់ឧស្សាហកម្មកែច្នៃ តាមរយៈការជំរុញឱ្យមានការវិនិយោគលើដំណាំដែលមានសក្តានុពល ដូចជា៖ ស្រូវ ដំឡូងមី ស្វាយ ស្វាយចន្ទី ចេក កៅស៊ូ ម្រេច បន្លែជាដើម តាមរយៈការរៀបចំយុទ្ធសាស្រ្តតាមមុខដំណាំនីមួយៗ, (៥) ការបន្តជំរុញការដាំបន្លែគ្រប់ប្រភេទជំនួសឱ្យការនាំចូលនិងការរៀបចំបង្កើតទីផ្សារបោះដុំ និងចែកចាយបន្លែដែលមានស្តង់ដានិងអនាម័យខ្ពស់, (៦) ការជំរុញពាណិជ្ជូបនីយកម្មកសិកម្ម, (៧) ការជំរុញការចិញ្ចឹមសត្វនិងវារីវប្បកម្ម។ល។ តាមបរិបទខាងលើ កៅស៊ូនៅតែជាដំណាំយុទ្ធសាស្រ្តដែលរាជរដ្ឋាបាលនៅបន្តយកចិត្តទុកដាក់ខ្ពស់មួយផងដែរ។

## ១.២ ការរៀបចំផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍កៅស៊ូធម្មជាតិឆ្ពោះទៅឆ្នាំ២០៣០

៨- ផែនការយុទ្ធសាស្រ្តសម្រាប់ការអភិវឌ្ឍឧស្សាហកម្មកៅស៊ូធម្មជាតិនៅកម្ពុជា២០១១-២០២០ បានរៀបចំនិងដាក់ឱ្យអនុវត្តតាំងពីឆ្នាំ២០១១ សំដៅរួមចំណែកសម្រេចនូវគោលដៅនៃផែនការយុទ្ធសាស្រ្ត





អភិវឌ្ឍន៍វិស័យកសិកម្ម២០០៩-២០១៣ ក៏ដូចផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ២០០៩-២០១៣ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣របស់រាជរដ្ឋាភិបាល។ ផែនការយុទ្ធសាស្ត្រសម្រាប់ការអភិវឌ្ឍឧស្សាហកម្មកៅស៊ូធម្មជាតិនៅកម្ពុជា២០១១-២០២០ មានស្នូលយុទ្ធសាស្ត្រចំនួន៦គឺៈ (១) ការធានាគុណភាពនិងផលិតភាពនៃការដាំដុះកៅស៊ូ (២) ការសិក្សាអំពីលទ្ធភាពប្រើប្រាស់ដោយស្របច្បាប់នូវសក្ដានុពលដីទំនេរដែលសកបនឹងដំណាំកៅស៊ូ (៣) ការជំរុញការដាំដុះកៅស៊ូគ្រួសារ (៤) ការជំរុញចម្ការកៅស៊ូកសិឧស្សាហកម្មដើម្បីធ្វើជាស្នូលនៃការអភិវឌ្ឍចម្ការកៅស៊ូគ្រួសារ (៥) ការជំរុញខ្សែច្រវាក់តម្លៃកៅស៊ូឱ្យបានល្អ និង(៦) ការពង្រឹងតួនាទីដឹកនាំរបស់អគ្គនាយកដ្ឋានកៅស៊ូនិងអភិបាលកិច្ច។ ចំណុចដៅនៃសូចនាករចុងក្រោយចំបងរបស់យុទ្ធសាស្ត្រនេះ គឺបានគ្រោងផ្ទៃដីកៅស៊ូសរុបនៅឆ្នាំ២០២០ ឱ្យបានចំនួន ៣០០ ៤៣៣ហិកតា តែតាមការអនុវត្តនិងការពិនិត្យជាក់ស្ដែង ចំណុចដៅនេះបានសម្រេចរួចរាល់តាំងពីក្នុងឆ្នាំ២០១៣មកម្លេះ និងតាមភាពជាក់ស្ដែងគិតត្រឹមចុងឆ្នាំ២០១៩ ផ្ទៃដីកៅស៊ូសរុបមានដល់ទៅចំនួន ៤០៥ ៦៧១ហិកតា ឃើញថាកើនលើសការគ្រោងទុកចំនួន ១០៥ ២៣៨ ហិកតា ស្មើនឹង ៣៥,០៣% ឯណោះ។ ម្យ៉ាងទៀត ដើម្បីឱ្យស្របតាមស្ថានភាពជាក់ស្ដែងៈ (១) ភាពរីកចម្រើននៃប្រទេសជាតិ (២) គោលបំណង និងគោលដៅនៃយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤, ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ២០១៩-២០២៣, និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម ២០១៩-២០២៣ និង(៣) តម្រូវការជាធាតុចូលសម្រាប់ផែនការមេអភិវឌ្ឍន៍វិស័យកសិកម្មឆ្នាំ២០៣០ ចាំបាច់តម្រូវឱ្យមាន ការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍កៅស៊ូធម្មជាតិឆ្ពោះទៅឆ្នាំ២០៣០នេះឡើង។

៩- ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍កៅស៊ូធម្មជាតិឆ្ពោះទៅឆ្នាំ២០៣០ ត្រូវបានរៀបចំបង្កើតឡើងសម្រាប់ជាមូលដ្ឋានគ្រឹះក្នុងការអនុវត្តផែនការសកម្មភាពរបស់អគ្គនាយកដ្ឋានកៅស៊ូ និងសហការជាមួយដៃគូដែលពាក់ព័ន្ធ ដោយយកចិត្តទុកដាក់ជាសំខាន់ធ្វើការដោះស្រាយលើបញ្ហាប្រឈមនានា និងផ្ដល់យន្តការដោះស្រាយសំខាន់ៗ សំដៅលើកកម្ពស់សក្ដានុពលដំណាំកៅស៊ូ ឱ្យទទួលបានភាពល្អប្រសើរទាំងបរិមាណនិងគុណភាព ដោយជំរុញការអភិវឌ្ឍខ្សែច្រវាក់តម្លៃកៅស៊ូឱ្យបានល្អប្រសើរ និងអភិវឌ្ឍប្រកបដោយនិរន្តរភាព ដើម្បីបង្កើនបន្ថែមប្រាក់ចំណូលនិងបង្កើតការងារនៅជនបទ រួមចំណែកជួយជំរុញប្រទេសដែលមានចំណូលមធ្យមកម្រិតទាប បន្តសម្រេចឡើងទៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ ចូលរួមថែរក្សាបរិស្ថាន និងគ្រប់គ្រងធនធានធម្មជាតិប្រកបដោយចីរភាព។

## ១.៣ ទម្រង់នៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍កៅស៊ូធម្មជាតិឆ្ពោះទៅឆ្នាំ២០៣០

១០- ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍កៅស៊ូធម្មជាតិឆ្ពោះទៅឆ្នាំ២០៣០ ត្រូវបានរៀបចំឡើងជា២ផ្នែកសំខាន់ គឺ**ផ្នែកទី១ ស្ដីពីការវិភាគស្ថានភាពកៅស៊ូធម្មជាតិឆ្នាំ២០១០-២០១៩** ដែលនៅក្នុងផ្នែកនេះ ផ្ដោតចំណុចសំខាន់លើៈ (១) សេចក្ដីផ្ដើម (២) ការវិភាគស្ថានភាពកៅស៊ូធម្មជាតិពិភពលោក ដោយបានលើកឡើងពីការផ្គត់ផ្គង់និងតម្រូវការកៅស៊ូធម្មជាតិ កត្តាដែលនាំឱ្យតម្លៃកៅស៊ូធម្មជាតិមានការប្រែប្រួល និងនិន្នាការកៅស៊ូធម្មជាតិពិភពលោក (៣) ការវិភាគស្ថានភាពកៅស៊ូធម្មជាតិនៅកម្ពុជា មានជាអាទិ៍ដូចជាៈ ផ្ទៃដី ផលិតកម្ម ការកែច្នៃ ការនាំចេញ តម្លៃនិងទីផ្សារ ការស្រាវជ្រាវនិងពិសោធន៍ ការបណ្ដុះបណ្ដាលនិងផ្ទេរបច្ចេកវិទ្យា និងកម្លាំងពលកម្មក្នុងអនុវិស័យកៅស៊ូ កិច្ចសហប្រតិបត្តិការរវាងផ្នែកសាធារណៈ ឯកជន និងដៃគូអភិវឌ្ឍន៍ (៤) បញ្ហាប្រឈមនិងកត្តាអំណោយផល (៥) និន្នការវិវត្ត





នៃកៅស៊ូធម្មជាតិ និង (៦) សន្និដ្ឋាន។ **ផ្នែកទី២ ស្តីពីផែនការយុទ្ធសាស្ត្រអភិវឌ្ឍកៅស៊ូធម្មជាតិឆ្ពោះទៅឆ្នាំ២០៣០** ដែលអធិប្បាយអំពី៖ (១) សេចក្តីផ្តើម (២) ចក្ខុវិស័យ (៣) បេសកកម្ម (៤) គោលបំណងនិងគោលដៅ (៥) ក្របខណ្ឌយុទ្ធសាស្ត្រ ដែលបង្ហាញអំពីការវិភាគជាយុទ្ធសាស្ត្រនិងស្នូលយុទ្ធសាស្ត្រ (៦) រចនាសម្ព័ន្ធនៃការអនុវត្ត ការតាមដានត្រួតពិនិត្យ និងការវាយតម្លៃផែនការយុទ្ធសាស្ត្រ (៧) កត្តារារាំងនៅពេលអនុវត្ត (៨) សន្និដ្ឋាន និង (៩) ឧបសម្ព័ន្ធ ដែលមានបង្ហាញអំពីតារាងម៉ាទ្រិកលម្អិត។

# ២ ការវិភាគស្ថានភាពកៅស៊ូធម្មជាតិពិភពលោក

## ២.១ ការផ្គត់ផ្គង់និងតម្រូវការកៅស៊ូធម្មជាតិ

១១- ចាប់ពីឆ្នាំ២០១០ដល់ឆ្នាំ២០១៣ និន្នាការនៃការផ្គត់ផ្គង់កៅស៊ូធម្មជាតិលើពិភពលោក បានស្ទុះឡើងពី ១០ ៤០៣ពាន់តោន ដល់ ១២ ២៨២ពាន់តោន។ ការផ្គត់ផ្គង់នេះបានធ្លាក់ចុះបន្តិចវិញនៅឆ្នាំ២០១៤ មកត្រឹម ១២ ១៤៩ពាន់តោន បន្ទាប់មកចាប់ផ្ដើមឡើងវិញរហូតមក។ ជារួមចាប់ពីឆ្នាំ២០១០ រហូតដល់ឆ្នាំ២០១៩ ការផ្គត់ផ្គង់កៅស៊ូធម្មជាតិនៅលើពិភពលោកមានអត្រាកំណើនសមាសប្រចាំឆ្នាំក្នុងរង្វង់ ៣,២%។ តាមការព្យាកររបស់សមាគមបណ្តាប្រទេសផលិតកៅស៊ូធម្មជាតិ (ANRPC) នៅក្នុងឆ្នាំ២០១៩ ការផ្គត់ផ្គង់កៅស៊ូធម្មជាតិនៅលើពិភពលោកមានចំនួនប្រមាណ ១៣ ៧៦៤លានតោន គឺមានកំណើនចំនួនប្រមាណ ៣ ៣៦១ពាន់តោន ស្មើនឹងប្រមាណ ៣២,៣០% បើធៀបនឹងឆ្នាំ២០១០ ដែលមានចំនួនប្រមាណ ១០ ៤០៣ពាន់តោន។

១២- ចាប់ពីឆ្នាំ២០១០ដល់ឆ្នាំ២០១៩ តម្រូវការកៅស៊ូធម្មជាតិពិភពលោកមាននិន្នាការកើនឡើងជាបន្តបន្ទាប់ ដែលក្នុងនោះ តម្រូវការកៅស៊ូធម្មជាតិនាឆ្នាំ២០១០ មានចំនួនប្រមាណ ១០ ៧៥៩ពាន់តោន និងបានកើនឡើងដល់ចំនួនប្រមាណ ១៣ ៧០២លានតោន នៅឆ្នាំ២០១៩ ដែលមានកំណើនចំនួនប្រមាណ ២ ៩៤៣ពាន់តោន ស្មើនឹងប្រមាណជា ២៧,៣៥% និងមានអត្រាកំណើនសមាសប្រចាំឆ្នាំរង្វង់ ២,៤៤% (រូបភាពទី១)។




រូបភាពទី១៖ ការផ្គត់ផ្គង់និងតម្រូវការកៅស៊ូធម្មជាតិពិភពលោកឆ្នាំ២០១០-២០១៩






## ២.២ ថ្លៃកៅស៊ូធម្មជាតិ

១៣- ជាទូទៅនិន្នាការថ្លៃកៅស៊ូធម្មជាតិមានការប្រែប្រួល ដោយសារទទួលរងឥទ្ធិពលពីកត្តាសំខាន់ៗចំនួន ២គឺ៖ កត្តាមូលដ្ឋាននិងកត្តាមិនមែនមូលដ្ឋាន។ កត្តាទាំងពីរនេះ គឺជាកត្តាដែលតែងតែជះឥទ្ធិពលធ្វើឱ្យមានបម្រែបម្រួលថ្លៃមុខទំនិញពាណិជ្ជកម្ម (Commodity Price) ក្នុងនោះក៏មានថ្លៃកៅស៊ូផងដែរ។

១៤- **កត្តាមូលដ្ឋាន** គឺផ្តោតសំខាន់ទៅលើបរិមាណផ្គត់ផ្គង់និងតម្រូវការ។ ក្នុងករណីមានឱនភាពក្នុងការផ្គត់ផ្គង់ (បរិមាណផ្គត់ផ្គង់តិចជាងបរិមាណតម្រូវការ) ធ្វើឱ្យថ្លៃកៅស៊ូឡើងខ្ពស់។ ផ្ទុយទៅវិញ ក្នុងករណីមានអតិរេកក្នុងការផ្គត់ផ្គង់ (បរិមាណផ្គត់ផ្គង់ច្រើនជាងបរិមាណតម្រូវការ) ធ្វើឱ្យថ្លៃកៅស៊ូចុះទាប។ និន្នាការនៃកត្តាមូលដ្ឋាននេះ ជះឥទ្ធិពលទៅលើថ្លៃកៅស៊ូធម្មជាតិក្នុងរយៈពេលវែង ក៏ដូចជាថ្លៃមុខទំនិញពាណិជ្ជកម្មនានាក្នុងទីផ្សារ បើធៀបទៅនឹងកត្តាមិនមែនមូលដ្ឋាន។

១៥- **កត្តាមិនមែនមូលដ្ឋាន** គឺផ្តោតទៅលើកត្តាផ្សេងៗទៀត ដែលជះឥទ្ធិពលទៅលើថ្លៃកៅស៊ូ រួមមាន៖ កត្តាប្រេងឆៅ មុខទំនិញលោហៈ កត្តារូបិយប័ណ្ណ (អត្រាប្តូរប្រាក់ដុល្លារសហរដ្ឋអាម៉េរិក) កត្តាមូលនិធិជំនួញ (Speculative Fund) និងវិបត្តិសេដ្ឋកិច្ចពិភពលោកជាដើម។ ជាក់ស្តែង ប៉ុន្មានឆ្នាំចុងក្រោយនេះ ភាពតានតឹងពាណិជ្ជកម្មរវាងសហរដ្ឋអាម៉េរិកនិងចិន បានជះឥទ្ធិពលទៅលើថ្លៃមុខទំនិញពាណិជ្ជកម្មនានានៅលើទីផ្សារពិភពលោក ក្នុងនោះក៏មានថ្លៃកៅស៊ូធម្មជាតិផងដែរ។

## ២.៣ ទស្សនវិស័យកៅស៊ូពិភពលោក

១៦- ការព្យាករអំពីការផ្គត់ផ្គង់កៅស៊ូធម្មជាតិពិភពលោក ផ្អែកលើទិន្នន័យនិងនិន្នាការនៃផ្ទៃដីដាំដុះ ផ្ទៃដីយកផល (ចៀរជ័រ) និងទិន្នផលជាមធ្យមដែលទទួលបានពីបណ្តាប្រទេសនានា ពិសេសពីបណ្តាប្រទេសជាសមាជិក នៃសមាគមបណ្តាប្រទេសផលិតកៅស៊ូធម្មជាតិ ដែលផ្គត់ផ្គង់កៅស៊ូធម្មជាតិប្រមាណ៩០% នៃផលិតផលកៅស៊ូធម្មជាតិពិភពលោក។ ចំពោះតម្រូវការកៅស៊ូធម្មជាតិ ត្រូវបានធ្វើចំណោល ដោយផ្អែកតាមបម្រែបម្រួលនៃផលិតផលក្នុងស្រុកសរុប (Gross Domestic Product) និងសេដ្ឋកិច្ចពិភពលោកដែលបានប្រមើល និងអត្រាកំណើននៃការប្រើប្រាស់របស់បណ្តាប្រទេសប្រើប្រាស់។ តាមការព្យាកររបស់ANRPC បានបង្ហាញថា៖ ក្នុងឆ្នាំ២០២០ ផលិតផលកៅស៊ូធម្មជាតិពិភពលោកនឹងមានចំនួនប្រមាណ ១៣ ១៩៩ពាន់តោន រីឯតម្រូវការនឹងមានចំនួនប្រមាណ ១២ ៦៦៨ ពាន់តោន។ ស្ថានភាពនេះបានបង្ហាញឱ្យឃើញថា ការផ្គត់ផ្គង់កៅស៊ូធម្មជាតិពិភពលោកនៅឆ្នាំ២០២០ នឹងមានអតិរេក ប្រមាណជា ៥៣១ពាន់តោន។

១៧- ចាប់ពីឆ្នាំ២០២០-២០២២ បរិមាណផ្គត់ផ្គង់កៅស៊ូធម្មជាតិនឹងនៅបន្តច្រើនជាងតម្រូវការ ជាមធ្យមពី ២២៤ពាន់តោន/ឆ្នាំ ទៅ ៥៣១ពាន់តោន/ឆ្នាំ។ បើផ្អែកតាមទិន្នន័យសន្និធិចុងឆ្នាំនិងតម្រូវការដែលរំពឹងទុក បរិមាណនេះអាចផ្គត់ផ្គង់ការប្រើប្រាស់បានរយៈពេលចំនួនប្រមាណពី ២,៩ខែ ទៅ ៣,២ខែ។ ចាប់ពីឆ្នាំ២០២៣-២០២៥ បរិមាណផ្គត់ផ្គង់កៅស៊ូធម្មជាតិតិចជាងតម្រូវការជាមធ្យមពី ៨៥ពាន់តោន/ឆ្នាំទៅ ៨៧៤ពាន់តោន/ឆ្នាំ។ បើផ្អែកតាមទិន្នន័យសន្និធិចុងឆ្នាំនិងតម្រូវការដែលរំពឹងទុក បរិមាណ





នេះ អាចផ្គត់ផ្គង់ការប្រើប្រាស់បានរយៈពេលចំនួនប្រមាណពី ២,៤ខែ ទៅ ១,៨ខែ។ ចំពោះបរិការណ៍នេះ ថ្លៃកៅស៊ូនឹងមាននិន្នាការងើបឡើងវិញចាប់ពីឆ្នាំ២០២៣ដល់ឆ្នាំ២០២៥ (តារាងទី១)។

តារាងទី១៖ ការផ្គត់ផ្គង់និងតម្រូវការកៅស៊ូធម្មជាតិពិភពលោក

| ឆ្នាំ | ការផ្គត់ផ្គង់ (ពាន់តោន) | % បម្រែបម្រួល | តម្រូវការ (ពាន់តោន) | % បម្រែបម្រួល | ប្រៀបធៀប(ពាន់តោន) | សន្និធិចុងក្រោយ (ពាន់តោន) | ចំនួនខែប្រើប្រាស់សន្និធិ |
|---|---|---|---|---|---|---|---|
| ២០១៩(ជាក់ស្តែង) | ១៣ ៧៦៤ | -០,០៤ | ១៣ ៧០២ | -៦,៤ | ៦២ | ២ ៨៥៣ | ២,៥ |
| ២០២០(រំពឹងទុក) | ១៣ ១៩៩ | -៤,១ | ១២ ៦៦៨ | -៧,៥ | ៥៣១ | ៣ ៣៨៤ | ៣,២ |
| ២០២១(រំពឹងទុក) | ១៥ ៧៣៧ | ១៩,២ | ១៥ ៣២៩ | ២១ | ៤០៩ | ៣ ៧៩៣ | ២,៩ |
| ២០២២(រំពឹងទុក) | ១៦ ០៩០ | ២,២ | ១៥ ៨៤៦ | ៣,៤ | ២២៤ | ៤ ០១៧ | ៣,១ |
| ២០២៣(រំពឹងទុក) | ១៦ ៣៤៩ | ១,៦ | ១៦ ៤៣៣ | ៣,៧ | -៨៥ | ៣ ៩៣២ | ២,៨ |
| ២០២៤(រំពឹងទុក) | ១៦ ៦៥២ | ១,៨ | ១៧ ០៨៤ | ៣,៩ | -៤៣២ | ៣ ៥០០ | ២,៤ |
| ២០២៥(រំពឹងទុក) | ១៦ ៩០១ | ១,៥ | ១៧ ៧៧៥ | ៤,១ | -៨៧៤ | ២ ៦២៦ | ១,៨ |

(ប្រភព៖ ANRPC- Jan & June,2020)

## ៣ ការវិភាគស្ថានភាពកៅស៊ូធម្មជាតិនៅកម្ពុជា

### ៣.១ ផ្ទៃដី

១៨- ក្នុងរយៈពេល១០ឆ្នាំកន្លងទៅនេះ ផ្ទៃដីដំណាំកៅស៊ូមានការកើនឡើងជាបន្តបន្ទាប់។ មកដល់ឆ្នាំ ២០១៩ ផ្ទៃដីកៅស៊ូកម្ពុជាសរុបមានចំនួន ៤០៥ ៦៧១ហិកតាដែលបានបែងចែកជា០២ផ្នែកគឺ៖ ផ្ទៃដីចម្ការកៅស៊ូកសិឧស្សាហកម្ម សរុបមានចំនួន ២៤៤ ៥៦៨ហិកតា ស្មើនឹង ៦០% និងផ្ទៃដីចម្ការកៅស៊ូគ្រួសារមានចំនួន ១៦១ ១០៣ហិកតា ស្មើនឹង ៤០% នៃផ្ទៃដីកៅស៊ូសរុប។ បើប្រៀបធៀបទៅឆ្នាំ ២០១០ ដែលមានផ្ទៃដីដាំកៅស៊ូសរុបចំនួន ១៨១ ៣៤៤ ហិកតា ឃើញថាការវិវត្តដាំដុះកៅស៊ូមកដល់ឆ្នាំ២០១៩ មានកំណើនចំនួន ២២៤ ៣២៧ហិកតា ស្មើនឹង ១២៣,៧% ក្នុងអត្រាកំណើនសមាសប្រចាំឆ្នាំស្មើនឹង ៩,៣៥%។ ចំណែកផ្ទៃដីកៅស៊ូយកផលក្នុងឆ្នាំ២០១៩ មានចំនួន ២៥០ ៤៧៧ហិកតា បើធៀបនឹងឆ្នាំ២០១០ ដែលមានផ្ទៃដីចំនួន ៣៨ ៤០៦ហិកតា គឺមានការកើនចំនួន ២១២ ០៧១ហិកតា ស្មើនឹង ៥៥២,២% ក្នុងអត្រាកំណើនសមាសប្រចាំឆ្នាំស្មើនឹង ២៣,១៦% (ឧបសម្ព័ន្ធទី១)។

១៩- និន្នាការនៃការកើនឡើងផ្ទៃដីកៅស៊ូក្នុងរយៈពេល១០ឆ្នាំចុងក្រោយនេះ បណ្តាលមកពីកត្តាអំណោយផលជាច្រើនដូចជា៖ (១) ប្រកាសលេខ០៣ ប្រក. របស់រាជរដ្ឋាភិបាលស្តីពីការអភិវឌ្ឍដំណាំកៅស៊ូគ្រួសារនៅកម្ពុជាឆ្នាំ២០០០ (២) គោលនយោបាយការផ្តល់សម្បទានដីសេដ្ឋកិច្ចដល់ក្រុមហ៊ុនវិនិ-យោគដើម្បីវិនិយោគដាំដុះដំណាំកៅស៊ូ (៣) ការកើនឡើងនៃតម្លៃកៅស៊ូនៅលើពិភពលោកនាអំឡុងឆ្នាំ២០០៨-២០១៣ (៤) ប្រទេសកម្ពុជាមានសុខសន្តិភាពនិងស្ថេរភាពនយោបាយពេញលេញ (៥) គោលនយោបាយផ្តល់កម្មសិទ្ធនិងបែងចែកដីសម្បទានសង្គមកិច្ចជូនដល់ប្រជាពលរដ្ឋ និង (៦) ដីមានសក្តានុពលកបនឹងដំណាំកៅស៊ូ។ល។ ប៉ុន្តែចាប់ពីឆ្នាំ២០១៦មក អត្រាកំណើននៃការដាំដុះកៅស៊ូនៅ






កម្ពុជាមានការថមថយមកវិញ បណ្ដាលមកពី៖ (១) ការធ្លាក់ចុះយ៉ាងគំហុកនៃតម្លៃកៅស៊ូនៅទីផ្សារពិភពលោក (២) រាជរដ្ឋាភិបាលបានធ្វើការបញ្ឈប់ផ្ដល់ដីសម្បទានសេដ្ឋកិច្ច (៣) វិបត្តិសេដ្ឋកិច្ចពិភពលោក (៤) ផ្ទៃដីមានសក្ដានុពលកបនឹងដំណាំកៅស៊ូសល់តិចតួច និង (៥) កង្វះការថែទាំបណ្ដាលឱ្យកៅស៊ូងាប់និងភ្លើងឆេះជាដើម។




រូបភាពទី២៖ ផែនទីបង្ហាញទីតាំងចម្ការកៅស៊ូកសិឧស្សាហកម្មនិងកៅស៊ូគ្រួសារនៅកម្ពុជា ឆ្នាំ២០១៩

២០- ទិន្នផលកៅស៊ូរយៈពេលដប់ឆ្នាំចុងក្រោយនេះ មិនមានការខុសគ្នាខ្លាំងនោះទេ ដោយទិន្នផលជាមធ្យមប្រចាំឆ្នាំមានចំនួន ១ ១៤២គីឡូក្រាម/ហិកតាប៉ុណ្ណោះ។ បើប្រៀបធៀបនឹងទិន្នផលឆ្នាំ២០១០ ដែលមានចំនួន ១ ១០០គីឡូក្រាម/ហិកតា ទិន្នផលឆ្នាំ២០១៩ មានការកើនឡើងត្រឹមតែ ៤៨គីឡូក្រាម/ហិកតាប៉ុណ្ណោះ ដែលអត្រាកំណើនសមាសប្រចាំឆ្នាំស្មើនឹង ០,៤៨%។




រូបភាពទី៣៖ ការវិវត្តនៃទិន្នផលកៅស៊ូរយៈពេល១០ឆ្នាំ






## ៣.២ ផលិតកម្ម

២១- រយៈពេល១០ឆ្នាំកន្លងមកនេះ ផលិតផលកៅស៊ូមានការកើនឡើងជាបន្តបន្ទាប់ ពីមួយឆ្នាំទៅមួយឆ្នាំ។ នៅក្នុងឆ្នាំ២០១៩ ផលិតផលកៅស៊ូសរុបមានចំនួន ២៨៧ ៦២៨តោន បើធៀបនឹងឆ្នាំ២០១០ មានចំនួន ៤២ ២៥០តោន គឺកើនឡើងចំនួន ២៤៥ ៣៧៨តោន ស្មើនឹង ៥៨០,៧៨% ក្នុងអត្រាកំណើនសមាសប្រចាំឆ្នាំក្នុងរង្វង់ ២៣,៧៥% (ឧបសម្ព័ន្ធទី១)។

## ៣.៣ ការកែច្នៃ

២២- នៅឆ្នាំ២០១៩ រោងចក្រ សិប្បកម្មកែច្នៃកៅស៊ូនិងឈើកៅស៊ូមានចំនួនសរុប ១៥៤កន្លែង ក្នុងខេត្តចំនួន១១ (ត្បូងឃ្មុំ កំពង់ចាម រតនគិរី ក្រចេះ កំពង់ធំ មណ្ឌលគិរី ព្រះវិហារ ស្ទឹងត្រែង ព្រះសីហនុ ប៉ៃលិន និងឧត្តរមានជ័យ)។ ក្នុងនោះរោងចក្រកែច្នៃកៅស៊ូបញ្ជាក់តាមលក្ខណៈបច្ចេកទេស (TSR: Technically Specified Rubber) ចំនួន ៤៦ ដែលមានសមត្ថភាពផលិតកៅស៊ូបានជាមធ្យមប្រមាណ ២០១ ៦០០តោន/ឆ្នាំ រោងចក្រកែច្នៃទឹកជ័រខាប់ (CL: Concentrated Latex) ចំនួន ០១កន្លែង មានសមត្ថភាពផលិតជាមធ្យមប្រមាណ ៦ ០០០តោន/ឆ្នាំ សិប្បកម្មកែច្នៃកៅស៊ូសន្លឹកសម្ងួតដោយមានផ្សែង (RSS: Ribbed Smoked Sheet) និងសិប្បកម្មកែច្នៃកៅស៊ូសន្លឹកសម្ងួតដោយខ្យល់ក្តៅ (ADS: Air-Dried Sheet) មានចំនួន ៩៦កន្លែង ដែលមានសមត្ថភាពផលិត ៣៨ ១៧៦ តោន/ឆ្នាំ និងរោងចក្រកែច្នៃឈើកៅស៊ូ (RWF: Rubber Wood Factory) ចំនួន ១១កន្លែង ដែលបានកែច្នៃឈើមូលទៅជាផលិតផលកែច្នៃបឋមចំនួន ៤០ ១១០ម៉ែត្រគូប/ឆ្នាំ។

## ៣.៤ ការនាំចេញ

២៣- បរិមាណនៃនាំចេញកៅស៊ូធម្មជាតិកម្ពុជា មាននិន្នាការកើនឡើងជាលំដាប់។ ការនាំចេញកៅស៊ូក្នុងឆ្នាំ២០១៩ មានបរិមាណដល់ទៅ ២៨២ ០៧១តោន បើធៀបនឹងឆ្នាំ២០១០ ដែលមានការនាំចេញចំនួនប្រមាណត្រឹមតែ ៤២ ០០០តោន ការនាំចេញកៅស៊ូនៅឆ្នាំ២០១៩ បានកើនឡើងចំនួនប្រមាណ ២៤០ ០៧១តោន ស្មើនឹង ៥៧១,៦% ក្នុងអត្រាកំណើនសមាសប្រចាំឆ្នាំក្នុងរង្វង់ ២៤,០៥%។ លទ្ធផលនៃកំណើននេះ បានមកពីការរៀបចំផែនការយុទ្ធសាស្ត្រលើការកែលម្អវិស័យកសិកម្ម ជាពិសេសការផ្តល់សម្បទានដីសេដ្ឋកិច្ច និងការឡើងថ្លៃកៅស៊ូនៅបណ្តាឆ្នាំ២០០៨-២០១៣ ដែលនាំមានការពង្រីកវិសាលភាពផ្ទៃដីដាំដុះដំណាំកៅស៊ូ ទៅលើដីដែលកបនឹងមុខដំណាំនេះ។








រូបភាពទី៤៖  ការនាំចេញនិងថ្លៃកៅស៊ូ (២០១០-២០១៩)

## ៣.៥ តម្លៃនិងទីផ្សារ

២៤ - ចាប់ពីឆ្នាំ២០១០-២០១១ ថ្លៃកៅស៊ូចាប់ឡើងជាគំហុកពី ២ ៦៥៥ដុល្លារអាម៉េរិក/តោន នៅឆ្នាំ២០១០ ទៅ ៤ ២៧៦ដុល្លារអាម៉េរិក/តោនជាមធ្យម នៅឆ្នាំ២០១១។ បន្ទាប់មក ចាប់ពីចុងឆ្នាំ២០១១ ថ្លៃកៅស៊ូចាប់ធ្លាក់ចុះជាបន្តបន្ទាប់ដល់ ១ ២០៣ដុល្លារអាម៉េរិក/តោន នៅឆ្នាំ២០១៥។ ប៉ុន្តែចាប់ពីចុងឆ្នាំ២០១៦ ថ្លៃកៅស៊ូបានចាប់ផ្តើមងើបឡើងវិញបន្តិចរហូតដល់ឆ្នាំ២០១៧ ដែលមានតម្លៃ ១ ៥៨៦ ដុល្លារអាម៉េរិក/តោន រួចក៏ធ្លាក់វិញនៅឆ្នាំ២០១៨ ក្នុងតម្លៃមធ្យមត្រឹមតែ ១ ៣១៩ដុល្លារអាម៉េរិក/តោន។ នៅឆ្នាំ២០១៩ កៅស៊ូថ្លៃជាមធ្យម ១ ៣៣៦ដុល្លារអាម៉េរិក/តោន។ កត្តាដែលនាំឱ្យថ្លៃកៅស៊ូធ្លាក់ចុះគឺបណ្តាលមកពី៖ (១) ការផ្គត់ផ្គង់លើសតម្រូវការ (២) សន្និធិកៅស៊ូនៅសល់ច្រើនក្នុងឃ្លាំងនានា នៃទីផ្សារសៀងហៃ និងនៅមជ្ឈមណ្ឌលពាណិជ្ជកម្មសេរីក្វាងទុង (៣) ក្តីកង្វល់និងការបារម្ភនានាអំពីការធ្លាក់ចុះសេដ្ឋកិច្ចចិន ដោយសារតែសង្គ្រាមពាណិជ្ជកម្មរវាងសហរដ្ឋអាម៉េរិចនិងប្រទេសចិន រួមនឹងគោលនយោបាយសងសឹកគ្នាទៅវិញទៅមកលើការយកពន្ធអាករលៀងៗខ្លួនរបស់មហាយក្សសេដ្ឋកិច្ចទាំងពីរ និង (៤) ឥទ្ធិពលអវិជ្ជមាននៃកត្តាខាងក្រៅផ្សេងៗទៀតដូចជា៖ មូលនិធិជំនួញ អត្រាប្តូររូបិយបណ្ណអន្តរជាតិ និងថ្លៃប្រេងឆៅ។ បើធៀបនឹងថ្លៃកៅស៊ូម៉ាឡេស៊ី ក្នុងរយៈពេល១០ឆ្នាំ (២០១០-២០១៩) ថ្លៃកៅស៊ូកម្ពុជាមានត្រឹមតែ ៧៩ទៅ ៩៦ភាគរយប៉ុណ្ណោះ (រូបភាពទី៥)។

២៥- រហូតមកដល់ឆ្នាំ២០១៩ ទីផ្សារកៅស៊ូធម្មជាតិកម្ពុជា នៅតែពឹងលើទីផ្សារនាំចេញ ពីព្រោះមិនទាន់មានអ្នកវិនិយោគិនក្នុងនិងក្រៅស្រុក ធ្វើការវិនិយោគលើផ្នែកកៅស៊ូលំហូរខាងក្រោម (Rubber downstream sector) ដែលអាចជួយស្រូបយកផលិតផលកៅស៊ូកែច្នៃបឋម ធ្វើជាវត្ថុធាតុដើមបម្រើឱ្យឧស្សាហកម្មកម្មន្តសាលផលិតផលសម្រេច។ ប្រសិនបើមានផ្នែកកៅស៊ូលំហូរខាងក្រោម នោះការនាំចូលផលិតផលសម្រេចពីកៅស៊ូនឹងអាចថយចុះ ការផលិតនិងការប្រើប្រាស់ផលិតផលសម្រេចពី





កៅស៊ូក្នុងស្រុកនឹងកើតមាន ទីផ្សារសម្រាប់ផលិតផលសម្រេចពីកៅស៊ូក្នុងស្រុកក៏នឹងកើតមាន និងកៅស៊ូរបស់កសិករកៅស៊ូគ្រួសារនឹងលក់បានថ្លៃល្អប្រសើរផងដែរ។




រូបភាពទី៥ ៖ ការប្រៀបធៀបថ្លៃកៅស៊ូមធ្យមរបស់កម្ពុជានិងម៉ាឡេស៊ី (២០១០-២០១៩)

## ៣.៦ ការស្រាវជ្រាវនិងពិសោធន៍

២៦- ការស្រាវជ្រាវនិងពិសោធន៍កៅស៊ូ សំដៅជំរុញការអភិវឌ្ឍលើគ្រប់ផ្នែកពាក់ព័ន្ធនឹងដំណាំកៅស៊ូ ជារួមមាន៖ ការធ្វើសុវត្ថិកម្មនៃគុណភាពកៅស៊ូ ការបង្កើតនូវបទដ្ឋានគុណភាព ការផ្តល់នូវវិញ្ញាបនបត្រយថាប្រភេទកៅស៊ូកម្ពុជា ការអភិវឌ្ឍក្លូនកៅស៊ូ ការធ្វើវិញ្ញាបនបត្រច្បារពូជ ការអភិវឌ្ឍបច្ចេកទេសដាំដុះ ថែទាំកូនកៅស៊ូ ការយកផលទឹកជ័រ ការបណ្តុះបណ្តាល ការផ្សព្វផ្សាយ និងការផ្ទេរបច្ចេកវិទ្យាថ្មីៗដល់អ្នកដាំកៅស៊ូ។ សមិទ្ធផលសំខាន់ៗក្នុងផ្នែកពិសោធនិងស្រាវជ្រាវរបស់វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជាមានដូចខាងក្រោម៖

### ៣.៦.១ ការអភិវឌ្ឍពូជកៅស៊ូ

២៧- ការងារដែលបានអនុវត្តនៅក្នុងផ្នែកបង្កាត់ពូជ សំដៅធ្វើសុវត្ថិកម្មក្លូនកៅស៊ូ តាមរយៈការនាំចូល ការប្តូរក្លូនជាមួយបណ្តាប្រទេសជាសមាជិកIRRDB ការបង្កាត់និងជម្រើសពូជ ការពង្រឹងគុណភាពរុក្ខសម្ភារ ជាពិសេសការគ្រប់គ្រងច្បារពូជ ការអភិវឌ្ឍក្លូនកៅស៊ូកម្ពុជា និងការផ្តល់ជាអនុសាសន៍ក្លូនកៅស៊ូសម្រាប់ការដាំដុះតាមដំណាក់កាល ឆ្លើយតបទៅនឹងលក្ខខណ្ឌក្សេត្របរិស្ថានតាមតំបន់ ក្នុងគោលបំណងបង្កើននូវផលិតភាព បង្កើនចំណូលដល់អ្នកដាំដុះកៅស៊ូ និងរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។ សកម្មភាពការងារនិងសមិទ្ធផលសំខាន់ៗក្នុងការអភិវឌ្ឍពូជកៅស៊ូ រួមមាន៖





តារាងទី២៖ សមិទ្ធផលនៃការងារផ្នែកបង្កាត់និងជម្រើសពូជកៅស៊ូ

| ល.រ | សកម្មភាពអាទិភាព | បរិមាណ | ឆ្នាំ |
|---|---|---|---|
| ១ | ការរៀបចំច្បារបង្កាត់ពូជកៅស៊ូ(១៦មេបា) | ០១ចម្ការ | ២០១៣ |
| ២ | ចម្ការពិសោធក្លូនទ្រង់ទ្រាយធំ | ៣០ពិសោធន៍ | ២០១៨ |
| ៣ | ការបង្កើតច្បារពូជ | ៧៤ក្លូន(៦,៦ហ.ត) | ២០១៨ |
| ៤ | ការកសាងធនធានសេនេទិចកៅស៊ូ | ២០សេណូទីប | ២០១៨ |
| ៥ | ការរៀបចំអនុសាសន៍ក្លូនកៅស៊ូ | ០៦លើក | ២០១៨ |
| ៦ | គម្រោងធម្មនិយាមកម្មច្បារពូជ(ការវិភាគច្បារពូជ) | ១២៨ ច្បារពូជ (១០៣,៦ហ.ត) | ២០១៨ |
| ៧ | ការផ្តល់វិញ្ញាបនបត្របញ្ជាក់គុណភាពច្បារពូជ | ១៩ច្បារពូជ (១៥,៦៥ហ.ត) | ២០១៨ |
| ៨ | ការនាំចូលក្លូនកៅស៊ូពីបរទេស (IRRDB) | ២៦ក្លូន | ២០០៥-២០១៨ |
| ៩ | ការផ្លាស់ប្តូរក្លូនទៅបរទេស (ថៃនិងឥណ្ឌា) | ០៥ក្លូន | ២០១៥-២០១៨ |
| ១០ | ការរៀបចំច្បារពូជគោលក្រោមគម្រោង AFD | ២,០ហ.ត | ២០១៨ |
| ១១ | ក្រុមហ៊ុនចម្ការពិសោធ | ៦២ | ២០១៩ |

### ៣.៦.២ ការរៀបចំអនុសាសន៍ក្លូនកៅស៊ូ

២៨- អនុសាសន៍ក្លូនកៅស៊ូ សំដៅដល់ការធ្វើពិពិធកម្មក្លូនកៅស៊ូទៅតាមដំណាក់កាលនីមួយៗ ដើម្បីបញ្ចៀសនូវហានិភ័យផ្សេងៗ ព្រមជាមួយនឹងការធានានូវនិរន្តរភាពក្នុងផលិតកម្ម និងការអភិវឌ្ឍដំណាំកៅស៊ូ។ អនុសាសន៍ក្លូនកៅស៊ូសម្រាប់ការដាំដុះត្រូវបានវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជារៀបចំទៅតាមដំណាក់កាលដូចខាងក្រោម៖

- អនុសាសន៍ក្លូនលើកទី១សម្រាប់ឆ្នាំ២០០២-២០០៣
- អនុសាសន៍ក្លូនលើកទី២សម្រាប់ឆ្នាំ២០០៤-២០០៦
- អនុសាសន៍ក្លូនលើកទី៣សម្រាប់ឆ្នាំ២០០៧-២០០៩
- អនុសាសន៍ក្លូនលើកទី៤សម្រាប់ឆ្នាំ២០១១-២០១៣
- អនុសាសន៍ក្លូនលើកទី៥សម្រាប់ឆ្នាំ២០១៤-២០១៦
- អនុសាសន៍ក្លូនលើកទី៦សម្រាប់ឆ្នាំ២០១៨-២០២០





តារាងទី៣៖ អនុសាសន៍ក្លូនកៅស៊ូនៅកម្ពុជាសម្រាប់ឆ្នាំ២០១៨-២០២០

| **ថ្នាក់ទី ១** | **ថ្នាក់ទី ២** | **ថ្នាក់ទី ៣** |
|---|---|---|
| RRIC 121 | GT 1 | BPM 24 |
| IRCA 230 | IRCA 109 | IRCA 111 |
| IRCA 130 | RRIM 712 | IRCA 41 |
| PB 280 | RRIC 100 | PB 330 |
| RRIM 600 | RRIC 101 | PB 324 |
| | PB 217 | PB 314 |
| | KV 4 | PB 310 |
| | PB 235 | PR 303 |
| | | PR 261 |

### ៣.៦.៣ ផ្នែកដាំដុះនិងការពារ

២៩- ការពិសោធក្នុងផ្នែកដាំដុះនិងការពារ គឺដើម្បីធ្វើប្រសើរឡើងនូវវិធីសាស្ត្រដាំដុះ ការអនុវត្តកសិកម្មល្អ ការគ្រប់គ្រងជីជាតិដី បង្កើនប្រសិទ្ធភាពនៃចម្ការនិងការប្រើប្រាស់ដី ការបង្កើតនូវចំណូលបន្ថែមតាមរយៈការធ្វើពិពិធកម្មកៅស៊ូជាមួយនិងដំណាំរួមផ្សំ។ សកម្មភាពនិងសមិទ្ធផលសំខាន់ៗនៃការពិសោធដែលបានអនុវត្តនៅក្នុងផ្នែកនេះរួមមាន៖ (១) អភិវឌ្ឍន៍រុក្ខសម្ភារដាំដុះ (២) ការប្រើប្រាស់ជីលើកៅស៊ូមិនទាន់យកផល និងកៅស៊ូយកផល (៣) ការធ្វើពិពិធកម្មដំណាំរួមផ្សំ និងរុក្ខជាតិព្រៃនៅចន្លោះកៅស៊ូ (៤) ដំណាំគម្របដី ផលិតកម្មជីវម៉ាស់ និងវិធានការគ្រប់គ្រងដំណាំគម្របដី (៥) ទំនាក់ទំនងរវាងការលូតលាស់និងទិន្នផលទៅនឹងអាកាសធាតុ ចង្វាក់ចៀរ d3, d4 និង (៦) ដង់ស៊ីតេដើមកៅស៊ូ។

### ៣.៦.៤ ផ្នែកសរីរសាស្ត្រនិងការយកផលទឹកជ័រ

៣០- ការពិសោធក្នុងផ្នែកនេះ សំដៅកសាងទិន្នន័យក្នុងការយកផលទឹកជ័រសមស្របតាមលក្ខណៈសរីរសាស្ត្រគីមីរបស់ក្លូននីមួយៗ ដើម្បីយកផលទឹកជ័រឱ្យបានសមស្របទៅតាមសក្តានុពលនៃបណ្តាក្លូននីមួយៗ។ សកម្មភាពនិងសមិទ្ធផលសំខាន់ៗ ដែលបានស្រាវជ្រាវ និងអនុវត្តនៅក្នុងផ្នែកនេះរួមមាន៖ (១) សក្តានុពលទិន្នផល (d3, d4) និងប្រព័ន្ធចង្វាក់ចៀរជ័ររម្ងើល (d4, d5, d6) (២) ការវិភាគសរីរៈទឹកជ័រនៅក្នុងមន្ទីរពិសោធគីមី និងសរីរវិទ្យាកៅស៊ូមានដូចជា៖ ការវិភាគលើប៉ារ៉ាម៉ែត្រ Thiols (RSH), Phosphorus, Sucrose និង TSC & DRC (៣)ការបើកមុខចៀរលើទំហំដើមខុសគ្នា។ សំណាកទឹកជ័រនៃចម្ការពិសោធដែលបានធ្វើការវិភាគសរីរសាស្ត្រក្នុងរយៈពេល០៥ឆ្នាំ ចាប់ពីឆ្នាំ២០១៤-២០១៩ ត្រូវបានសង្ខេបក្នុងតារាងដូចខាងក្រោម៖





តារាងទី៤៖ ស្ថិតិសំណាកទឹកជ័រដែលបានវិភាគសរីរសាស្ត្ររយៈពេល៥ឆ្នាំ ២០១៤-២០១៨

| ឆ្នាំ/វិភាគ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | ២០១៩ | សរុប |
|---|---|---|---|---|---|---|---|
| | ៥០០ | ៧៥០ | ៩៨៦ | ៤៦៤ | ៥០០ | ៨៤៨ | ៤ ០៤៨ |

## ៣.៦.៤ ផ្នែកមន្ទីរពិសោធជាតិយថាប្រភេទ

៣១- មន្ទីរពិសោធជាតិយថាប្រភេទមានភារកិច្ចរៀបចំនូវបទដ្ឋានយថាប្រភេទកៅស៊ូ ទទួលខុសត្រូវលើស្តង់ដារកៅស៊ូជាតិ វិភាគគុណភាពយថាប្រភេទកៅស៊ូ បណ្តុះបណ្តាលដល់អ្នកបច្ចេកវិទ្យាកៅស៊ូនៃបណ្តារោងចក្រកែច្នៃកៅស៊ូ ផ្តល់នូវការទទួលស្គាល់ និងការអនុញ្ញាតប្រើប្រាស់នូវស្លាកសញ្ញាកៅស៊ូកម្ពុជា ដើម្បីលើកគុណតម្លៃកៅស៊ូជាតិនៅលើទីផ្សារអន្តរជាតិ។ បទដ្ឋានយថាប្រភេទកៅស៊ូកម្ពុជា (CSR) ត្រូវបានរៀបចំ និងដាក់ប្រើប្រាស់តាមរយៈប្រកាសលេខ០៨៦ប្រក.កសក ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៤។ លំដាប់ថ្នាក់កៅស៊ូ CSR ត្រូវបានកំណត់តាមយថាប្រភេទដូចមានក្នុងតារាងខាងក្រោម៖

តារាងទី៥៖ បទដ្ឋានកំណត់យថាប្រភេទកៅស៊ូកម្ពុជា(CSR)

| ប៉ារ៉ាម៉ែត្រ Parameters | CSR CV | CSR 3L | CSR L | CSR 5 | CSR 10 | CSR 20 |
|---|---|---|---|---|---|---|
| | Green | Green | Green | Green | Brown | Red |
| | Latex | | | | Field coagula | |
| Dirt content (% wt, max) | 0.05 | 0.03 | 0.05 | 0.05 | 0.1 | 0.2 |
| Initial plasticity, $P_0$ (min) | - | 35 | 30 | 30 | 30 | 30 |
| Plasticity retention index, PRI (%, min) | 60 | 60 | 60 | 60 | 50 | 40 |
| Nitrogen content (% wt, max) | 0.6 | 0.6 | 0.6 | 0.6 | 0.6 | 0.6 |
| Volatile matter content (% wt, max) | 0.8 | 0.8 | 0.8 | 0.8 | 0.8 | 0.8 |
| Ash content (%wt, max) | 0.6 | 0.5 | 0.6 | 0.6 | 0.75 | 1 |
| Colour index (max) | - | 6 (2*) | 6 | - | - | - |
| Mooney viscosity ML (1+4) $100^0$C | 60 ± 5** | - | - | - | - | - |

៣២- សកម្មភាពនិងសមិទ្ធផលសំខាន់ៗនៅក្នុងផ្នែកនេះរួមមាន៖ (១) ការធ្វើតេស្តអន្តរមន្ទីរពិសោធ(Round Robin Crosscheck) (២) ការធ្វើតេស្តប្រៀបធៀបជាមួយបណ្តាមន្ទីរពិសោធមូលដ្ឋាន (Parallel test) ក្នុងការ ពង្រឹងគុណភាពកៅស៊ូ CSR នៃបណ្តារោងចក្រនិងមន្ទីរពិសោធ (៣) កិច្ចបញ្ជិការរោងចក្រកែច្នៃកៅស៊ូCSR និងមន្ទីរពិសោធមូលដ្ឋាន ហើយនិងការចុះពិនិត្យរោងចក្រនិងមន្ទីរពិសោធCSR សំដៅតម្រង់ទិសនិងកែលម្អចំណុចខ្វះខាត ដើម្បីលើកកម្ពស់គុណភាពផលិតផលកៅស៊ូ និង(៤) ទទួលធ្វើសវនកម្មផ្ទៃក្នុងនិងក្រៅពីការិយាល័យទទួលស្គាល់អន្តរជាតិ។ ភាគសំណាកកៅស៊ូCSR ដែលបានធ្វើការវិភាគរយៈពេល១០ឆ្នាំ ចាប់ពីឆ្នាំ២០០៩-២០១៨ ត្រូវបានសង្ខេបក្នុងតារាងទី៦។





តារាងទី៦៖ ចំនួនគាគសំណាកកៅស៊ូ CSR (២០១០-២០១៩)

| ឆ្នាំ | វិភាគទូទៅ | តេស្តប្រៀបធៀប/មន្ទីរពិសោធមូលដ្ឋាន | តេស្តអន្តរមន្ទីរពិសោធ (Round Robin) | សរុប |
|---|---|---|---|---|
| ២០១០ | ២៥២ | ៤ | ២ | ២៥៨ |
| ២០១១ | ២៨៩ | ៤ | ២ | ២៩៥ |
| ២០១២ | ១៩០ | ៤ | ២ | ១៩៦ |
| ២០១៣ | ២២៩ | ៤ | ២ | ២៣៥ |
| ២០១៤ | ៣២៥ | ៤ | ២ | ៣៣១ |
| ២០១៥ | ៣៧៤ | ៤ | ២ | ៣៨០ |
| ២០១៦ | ៣៧០ | ៤ | ២ | ៣៧៦ |
| ២០១៧ | ៦៥១ | ៤ | ២ | ៦៥៧ |
| ២០១៨ | ៣៤៥ | ២ | ២ | ៣៤៩ |
| ២០១៩ | ៣៦៨ | ៥ | ២ | ៣៧៥ |
| សរុប | ៣ ៣៩៣ | ៣៩ | ២០ | ៣ ៤៥២ |

### ៣.៦.៦ ចម្ការពិសោធ

៣៣- អាស្រ័យដោយវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា អស់សក្តានុពលដីក្នុងការរៀបចំចម្ការពិសោធ និងការពង្រីកវិសាលភាពនូវទិន្នន័យពាក់ព័ន្ធនឹងដំណាំកៅស៊ូទៅកាន់តំបន់ផ្សេងទៀត ដែលមានសក្តានុ-ពលផ្នែកដំណាំកៅស៊ូរបស់ខ្លួន ចាប់ពីឆ្នាំ២០០៩-២០១៩ ដោយសហការជាមួយវិស័យឯកជន ចម្ការពិសោធត្រូវបានពង្រីងវិសាលភាពទៅកាន់តំបន់ផ្សេងៗទៀតក្រៅពីស្ថានីយពិសោធមានដូចជា៖ នៅក្រុមហ៊ុនចម្ការកៅស៊ូក្រែកខេមបូឌាក្នុងខេត្តសៀមរាប ក្រុមហ៊ុនចម្ការកៅស៊ូ Socfin KCD ខេត្តមណ្ឌលគីរី និងចម្ការកៅស៊ូបឹងទន្លេម្រេចខេត្តព្រះវិហារ ដែលនាំឱ្យចម្ការពិសោធបានកើនឡើងចំនួន៣០បន្ថែមទៀត លើចម្ការពិសោធចាស់ដែលមានចំនួន ៤៣ ក្នុងនោះមានចម្ការពិសោធចំនួន ០២ មានទិន្នន័យមិនល្អ ហើយត្រូវបានដកចេញពីបញ្ជីចម្ការពិសោធ និងបង្វិលទៅជាចម្ការកៅស៊ូឧស្សាហកម្មវិញ។ នៅដើមឆ្នាំ២០១៦ ចម្ការពិសោធក្លូនទ្រង់ទ្រាយធំ SRAA01 នៅក្រុមហ៊ុនក្រែកខេមបូឌា ស្ថិតនៅស្រុកស្វាយលើ ខេត្តសៀមរាបត្រូវបានភ្លើងឆេះនិងបានដកចេញពីការពិសោធ។ នៅចុងឆ្នាំ២០១៦ មានពិសោធន៍ចំនួន ០៨ផ្សេងទៀតត្រូវបានបញ្ចប់ ដូចនេះនៅមានចម្ការពិសោធចំនួន៦២ ដែលត្រូវបានរក្សានិងបន្តការតាមដានទិន្នន័យមកដល់ឆ្នាំ២០១៩។ ស្ថិតិលម្អិតចម្ការពិសោធបង្ហាញជូននៅក្នុងតារាងឧបសម្ព័ន្ធ៣។

## ៣.៧ ការបណ្តុះបណ្តាលនិងផ្ទេរបច្ចេកវិទ្យា

៣៤- ធនធានមនុស្សជាកត្តាយ៉ាងសំខាន់ ក្នុងការរួមចំណែកធ្វើឱ្យប្រសើរឡើងនូវការអភិវឌ្ឍអនុវិស័យកៅស៊ូនៅកម្ពុជា។ ការបណ្តុះបណ្តាលធនធានមនុស្សលើជំនាញពាក់ព័ន្ធនឹងអនុវិស័យកៅស៊ូត្រូវបានយកចិត្តទុកដាក់យ៉ាងខ្លាំង ក្នុងនោះមានការបណ្តុះបណ្តាលនិស្សិតនៅតាមបណ្តាគ្រឹះស្ថានសិក្សា ជនបង្គោលនៅតាមបណ្តាខេត្ត ស្រុក ឃុំ បុគ្គលិកក្រុមហ៊ុននិងរោងចក្រកែច្នៃ និងកសិករកៅស៊ូគ្រួសារ





ព្រមជាមួយគ្នានោះដែរ ការបណ្ដុះបណ្ដាលមន្ត្រី ក៏ត្រូវបានយកចិត្តទុកដាក់ សំដៅបង្កើនសមត្ថភាពក្នុងការបម្រើសេវាកម្មដល់ប្រជាពលរដ្ឋបានកាន់តែប្រសើរ និងមានប្រសិទ្ធភាព (ឧបសម្ព័ន្ធទី៤)។

## ៣.៨ កម្លាំងពលកម្ម

៣៥- កម្លាំងពលកម្មក្នុងអនុវិស័យកៅស៊ូក្នុងរយៈពេល១០ឆ្នាំកន្លងនេះ មានការកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ ជាពិសេសក្នុងរយៈពេល៣ឆ្នាំចុងក្រោយនេះ ទោះបីជាថ្លៃកៅស៊ូនៅលើទីផ្សារមានការធ្លាក់ចុះក៏ដោយ ក៏ប៉ុន្តែដោយសារផ្ទៃដីយកផលបានកើនឡើង ជាហេតុនាំឱ្យតម្រូវការកម្លាំងពលកម្មចៀរជ័រមានការកើនឡើងជាបន្តបន្ទាប់ផងដែរ។




រូបភាពទី៦៖ កម្លាំងពលកម្មក្នុងអនុវិស័យកៅស៊ូឆ្នាំ២០១០-២០១៩ (ពាន់នាក់)

## ៣.៩ កិច្ចសហប្រតិបត្តិការរវាងវិស័យសាធារណៈ ឯកជន និងដៃគូអភិវឌ្ឍន៍

៣៦- កិច្ចសហប្រតិបត្តិការរវាងវិស័យសាធារណៈ ឯកជន និងដៃគូអភិវឌ្ឍន៍ ជាយន្តការមួយដែលមានទំនាក់ទំនងជាអន្តរសកម្មភាព ដើម្បីរួមសហការគ្នាក្នុងដំណើរការប្រតិបត្តិខ្សែច្រវាក់តម្លៃកៅស៊ូ ដើម្បីអភិវឌ្ឍអនុវិស័យកៅស៊ូឱ្យមានលក្ខណៈប្រកួតប្រជែង បរិយាប័ន្ន និងប្រសិទ្ធភាពខ្ពស់ សំដៅជួយលើកស្ទួយដល់កំណើនសេដ្ឋកិច្ចជាតិនិងកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។ កិច្ចសហប្រតិបត្តិការរវាងវិស័យសាធារណៈ ឯកជន និងដៃគូអភិវឌ្ឍន៍ ក្នុងអនុវិស័យកៅស៊ូនៅកម្ពុជា រួមមាន៖

❖ **ដៃគូក្នុងស្រុក៖**

- ក្រុមហ៊ុនចម្ការកៅស៊ូកសិឧស្សាហកម្ម (អតីតចម្ការកៅស៊ូរដ្ឋនិងក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច)
- ម្ចាស់ចម្ការកៅស៊ូគ្រួសារ
- សមាគមអភិវឌ្ឍន៍កៅស៊ូកម្ពុជា
- សហគមន៍កសិកម្មកៅស៊ូគ្រួសារ





- រោងចក្រ សិប្បកម្មកែច្នៃផលិតផលកៅស៊ូ
- មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត
- សាកលវិទ្យាល័យភូមិន្ទកសិកម្ម
- សាកលវិទ្យាល័យ ជា ស៊ីម កំចាយមា
- សាកលវិទ្យាល័យស្វាយរៀង
- វិទ្យាស្ថានជាតិកសិកម្មកំពង់ចាម
- វិទ្យាស្ថានជាតិកសិកម្មព្រែកលៀប និង
- គ្រឹះស្ថានសិក្សាអប់រំផ្សេងៗទៀត។

❖ **ដៃគូក្រៅស្រុក៖**

- ទីភ្នាក់ងារបារាំងសម្រាប់ការអភិវឌ្ឍ (AFD)
- មជ្ឈមណ្ឌលសហប្រតិបត្តិការអន្តរជាតិស្រាវជ្រាវកសិកម្ម សម្រាប់ការអភិវឌ្ឍ (CIRAD)
- បណ្ឌិតសភាវិទ្យាសាស្ត្រកសិកម្មត្រូពិកចិន (CATAS)
- សមាគមកៅស៊ូអន្តរជាតិ (IRA)
- ក្រុមប្រឹក្សាស្រាវជ្រាវនិងអភិវឌ្ឍន៍កៅស៊ូអន្តរជាតិ (IRRDB)
- សមាគមបណ្តាប្រទេសផលិតកៅស៊ូធម្មជាតិ (ANRPC)
- អង្គការស្បៀងអាហារនិងកសិកម្មសហប្រជាជាតិ (FAO)
- ក្រុមប្រឹក្សាកៅស៊ូត្រីភាគគីអន្តរជាតិ (ITRC)
- ក្រុមសិក្សាកៅស៊ូអន្តរជាតិ (IRSG)
- ក្រុមប្រឹក្សាធុរកិច្ចកៅស៊ូអាស៊ាន (ARBC)។

# ៤ បញ្ហាប្រឈមនិងកត្តាអំណោយផល

## ៤.១ ការវិភាគ SWOT

៣៧- ទន្ទឹមនឹងការរីកចម្រើននៃអនុវិស័យកៅស៊ូទាំងលើផ្ទៃដីដាំដុះ ទាំងផលិតផល និងកំណើនសេដ្ឋកិច្ចនៅពេលបច្ចុប្បន្ននិងអនាគត អនុវិស័យកៅស៊ូបាននិងអាចទទួលរងនូវឥទ្ធិពលនៃកត្តាមួយចំនួនដែលទាំងអស់នេះចាំបាច់ត្រូវសិក្សា ពិចារណារៀបចំ និងដាក់ចេញនូវវិធានការនានា ដើម្បីត្រៀមដោះស្រាយ។ កត្តាទាំងនោះចែកចេញជាកត្តាខាងក្នុងនិងកត្តាខាងក្រៅ។ កត្តាខាងក្នុងដែលកំពុងឬនឹងមានឥទ្ធិពលដល់អនុវិស័យកៅស៊ូនាពេលអនាគត រួមមាន៖ ភាពខ្លាំងនិងភាពខ្សោយ។ ចំណែកកត្តាខាងក្រៅ រួមមាន៖ កាលានុវត្តភាពនិងភាពគំរាមកំហែង។ ក្នុងនោះភាពខ្សោយនិងភាពគំរាមកំហែងជាបញ្ហាប្រឈម រីឯភាពខ្លាំងនិងកាលានុវត្តភាពជាកត្តាអំណោយផល។ ក្នុងការបង្ហាញ វិភាគ និងដោះស្រាយបញ្ហានានាដែលកើតមានក្នុងដំណើរការអភិវឌ្ឍវិស័យនានា SWOTជាវិធីសាស្ត្រមួយដែលគេនិយមប្រើសម្រាប់ធ្វើការវិភាគ។







### ៤.១.១ កត្តាខាងក្នុង (Internal factor)

**ក. ភាពខ្លាំង (Strengths)**

S1. ផ្ទៃដីកៅស៊ូយកផលបានបន្តកើនឡើង

S2. ផលិតផលកៅស៊ូនឹងបន្តកើនឡើង

S3. ភូមិសាស្ត្រ-អាកាសធាតុសមស្របសម្រាប់ផលិតកម្មកៅស៊ូ

S4. ជំងឺរាតត្បាតកៅស៊ូមានកម្រិតទាប

S5. សក្តានុពលក្នុងការបង្កើនទិន្នផលកៅស៊ូ

S6. សក្តានុពលក្នុងការបង្កើនតម្លៃបន្ថែមទាំងកៅស៊ូនិងឈើកៅស៊ូ។

**ខ. ភាពខ្សោយ** (Weakness)

W1. ផលិតភាពនៅទាប

W2. ការប្រកួតប្រជែងពលកម្មពីវិស័យដទៃ

W3. កសិករកៅស៊ូគ្រួសារភាគច្រើនជាមនុស្សចាស់

W4. ការស្រាវជ្រាវបច្ចេកវិទ្យាកៅស៊ូនិងចំនួនអ្នកជំនាញនៅមានកម្រិត

W5. ការផ្តល់និងការទទួលយកបច្ចេកទេសសមស្របនៃដំណាំកៅស៊ូរបស់កសិករកៅស៊ូនៅមានកម្រិត

W6. ថ្លៃដើមផលិតផលកៅស៊ូខ្ពស់ តែលក់បានតម្លៃទាប

W7. សមត្ថភាពរបស់អង្គភាពជំនាញទទួលបន្ទុក សមាគម និងសហគមន៍នៅមានកម្រិត

W8. កង្វះផ្នែកកៅស៊ូលំហូរខាងក្រោម (downstream)។

### ៤.១.២ កត្តាខាងក្រៅ (External factor)

**ក. កាលានុវត្តភាព (Opportunities)**

O1. សន្តិភាពនិងស្ថិរភាពនាំឱ្យមានកំណើនសេដ្ឋកិច្ចល្អ

O2. រដ្ឋាភិបាលបាននឹងកំពុងយកចិត្តទុកដាក់ក្នុងការអភិវឌ្ឍកៅស៊ូគ្រួសារ

O3. វត្តមាននៃគោលនយោបាយ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍នានា (RS, NSDP, IDP, ASDP)

O4. ភាពប្រសើរឡើងនៃនីតិវិធីធ្វើពាណិជ្ជកម្ម

O5. កៅស៊ូធម្មជាតិនៅតែជាតម្រូវការចាំបាច់សម្រាប់វិស័យឧស្សាហកម្មយានយន្ត សុខាភិបាល កីឡា និងផ្លូវថ្នល់។ល។

O6. ភាពទំនាក់ទំនងកាន់តែប្រសើរជាមួយប្រទេសចិន ដែលជាប្រទេសនាំចូលកៅស៊ូធំជាងគេលើពិភពលោក

O7. លទ្ធភាពនៃការបង្កើតផ្នែកកៅស៊ូលំហូរខាងក្រោម (ការងារ តម្លៃបន្ថែម និងកាត់បន្ថយការនាំចូល)

O8. វត្តមាននៃកិច្ចសហប្រតិបត្តិការជាមួយអង្គការដៃគូនិងសមាគមកៅស៊ូអន្តរជាតិកាន់តែទូលំទូលាយ។

**ខ. ភាពគំរាមកំហែង (Threats)**

T1. ការប្រកួតប្រជែងពីដំណាំផ្សេងៗ វិស័យឧស្សាហកម្ម និងសំណង់

T2. ការពង្រីកផ្ទៃដីនិងផលិតផលកៅស៊ូរបស់បណ្តាប្រទេសដទៃ

T3. ចំណូលចិត្តអ្នកជំនាន់ក្រោយចំពោះមុខរបរកៅស៊ូធ្លាក់ចុះ





T4. កង្វះលិខិតគតិយុត្តផ្នែកកៅស៊ូនិងការអនុវត្តនៅមានកម្រិត

T5. លំហូរកៅស៊ូមិនទាន់កែច្នៃទៅបរទេសក្រៅផ្លូវការ

T6. ការគាំទ្រផ្នែកបច្ចេកទេស មធ្យោបាយ ថវិកា និងឥណទាន របស់រដ្ឋនិងដៃគូនានានៅមានកម្រិត

T7. ការប្រែប្រួលអាកាសធាតុនិងគ្រោះមហន្តរាយធម្មជាតិ

T8. វិបត្តិសេដ្ឋកិច្ចនិងសង្គ្រាមពាណិជ្ជកម្ម។

## ៥. និន្នាការវិវត្តនៃកៅស៊ូធម្មជាតិ

៣៨- យោងតាមការរីកចម្រើនសេដ្ឋកិច្ចជាតិនិងពិភពលោក និងដោយវិភាគលើភាពខ្លាំង ភាពខ្សោយ កាលានុវត្តភាព និងភាពគគំរាមកំហែង និន្នាការវិវត្តនៃកៅស៊ូធម្មជាតិនឹងអាចវិវត្ត ដូចខាងក្រោម៖

- ការផ្គត់ផ្គង់កៅស៊ូធម្មជាតិមានកំណើនខ្ពស់ បើធៀបនឹងតម្រូវការ ដែលជះឥទ្ធិពលជាអវិជ្ជមានដល់ថ្លៃកៅស៊ូ
- ថ្លៃកម្លាំងពលកម្មក្នុងអនុវិស័យកៅស៊ូនឹងកើនឡើងទៅតាមភាពរីកចម្រើននៃសេដ្ឋកិច្ច និងតម្លៃជីវភាពរស់នៅ ដែលនាំឱ្យថ្លៃដើមកើនឡើង និងខ្វះពលកម្ម
- ចម្ការកៅស៊ូកសិឧស្សាហកម្មនឹងថយចុះ ដោយសារការលំបាកក្នុងការស្វែងរកកម្លាំងពលកម្មដែលត្រូវការយ៉ាងច្រើននិងចាំបាច់របស់ខ្លួន
- ការកើនឡើងនូវលក្ខខណ្ឌតម្រូវពីអ្នកបញ្ជាទិញ ដែលទាមទារឱ្យអ្នកផលិតត្រូវសិក្សា និងត្រៀមខ្លួនជាមុន ដើម្បីឆ្លើយតបទាន់ពេលវេលាទៅនឹងលក្ខខណ្ឌដែលអ្នកបញ្ជាទិញទាមទារ និងតម្រូវ
- ការរីកចម្រើននៃបច្ចេកវិទ្យាកៅស៊ូទំនើប ដែលនាំមកនូវផលិតផលកៅស៊ូថ្មីៗ សម្រាប់ជាវត្ថុធាតុដើម ដូចជាក្នុងវិស័យសាធារណៈការ (ផ្លូវថ្នល់)
- តម្រូវការប្រើប្រាស់ផលិតផលកៅស៊ូក្នុងស្រុកអាចនឹងកើតមានឡើង នៅពេលមានផ្នែកកៅស៊ូលំហូរខាងក្រោម(ឧស្សាហកម្មកែច្នៃផលិតផលសម្រេចពីកៅស៊ូ)។

## ៦. សន្និដ្ឋាន

៣៩- ឧស្សាហកម្មកៅស៊ូធម្មជាតិបានដើរតួនាទីយ៉ាងសំខាន់ ក្នុងការជួយបង្កើនប្រាក់ចំណូលទៀងទាត់ដល់អ្នកដាំកៅស៊ូ ដល់សេដ្ឋកិច្ចជាតិ ការបង្កើតអាជីពនៅជនបទ ចូលរួមចំណែកដល់ការកាត់បន្ថយភាពក្រីក្រ និងការគ្រប់គ្រងធនធានធម្មជាតិនៅកម្ពុជាប្រកបដោយនិរន្តរភាព។

៤០- ផ្អែកលើសមិទ្ធផលដែលទទួលបានក្នុងរយៈពេល១០ឆ្នាំកន្លងមកនេះ អាចវាយតម្លៃបានថា ទោះបីជាមានការលំបាកនិងជួបប្រទះបញ្ហាប្រឈមមួយចំនួនក៏ដោយ តែដោយឈរលើស្មារតីសាមគ្គីភាព ឯកភាពផ្ទៃក្នុងរវាងថ្នាក់ដឹកនាំ និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ ដែលបានខិតខំអស់ពីកម្លាំងកាយចិត្ត និងមានការជួយតម្រង់ទិសពីថ្នាក់ដឹកនាំក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ព្រមទាំងគួបផ្សំនឹងការចូលរួមយ៉ាងសកម្មពីកសិករកៅស៊ូគ្រួសារនិងវិស័យឯកជន និងការរួមចំណែកពីដៃគូអភិវឌ្ឍន៍ផងនោះ បានជំរុញឱ្យកៅស៊ូធម្មជាតិកម្ពុជាទទួលបានលទ្ធផលជាផ្លែផ្កា និងមានការរីកចម្រើនគួរជាទីមោទកភាព។






# ផ្នែកទី២
# ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍កៅស៊ូធម្មជាតិឆ្ពោះទៅឆ្នាំ២០៣០

## ១. សេចក្តីផ្តើម

៤១- **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** តែងតែបានរំឭកអំពីការរីកចម្រើននិងសក្តានុពលនៃកៅស៊ូធម្មជាតិនៅកម្ពុជា ដោយហេតុថាដំណាំនេះបានផ្តល់ផលប្រយោជន៍ដល់សេដ្ឋកិច្ចជាតិ សង្គម ជាពិសេសបានផ្តល់នូវចំណូលសម្រាប់បង្កើននូវជីវភាពរស់នៅនិងការបង្កើតការងារនៅតាមមូលដ្ឋានជនបទ។ លើសពីនេះទៅទៀត កៅស៊ូធម្មជាតិក៏បានចូលរួមចំណែកយ៉ាងសកម្មនៅក្នុងការការពារបរិស្ថានប្រកបដោយចីរភាព បង្កើតជាគម្របបៃតង រក្សាលំនឹងធម្មជាតិ និងការពារការហូរច្រោះដី។ អាស្រ័យហេតុនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានយកចិត្តទុកដាក់ខ្ពស់ជំរុញការអភិវឌ្ឍឧស្សាហកម្មកៅស៊ូធម្មជាតិ ឱ្យកាន់តែមានថាមភាពខ្លាំងនិងភាពប្រកួតប្រជែងបន្ថែមទៀត តាមរយៈការដាក់បញ្ចូលទៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ២០១៩-២០២៣ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម២០១៩-២០២៣ និងផែនការមេអភិវឌ្ឍន៍វិស័យកសិកម្មឆ្នាំ២០៣០ ដើម្បីជំរុញអនុវត្តឱ្យបានសម្រេចជោគជ័យតាមគោលដៅ និងសូចនាករ ដែលបានគ្រោងទុក។

៤២- ទន្ទឹមនឹងភាពជោគជ័យនៃអនុវិស័យកៅស៊ូដែលសម្រេចបាន ក៏នៅមានបញ្ហាប្រឈមមួយចំនួនដែលចាំបាច់ត្រូវសិក្សាស្វែងយល់និងកំណត់ឱ្យបានច្បាស់ ដើម្បីដោះស្រាយនិងតម្រង់ទិសនៃការអភិវឌ្ឍកៅស៊ូកម្ពុជា ឱ្យក្លាយជាអនុវិស័យឈានមុខមួយក្នុងចំណោមដំណាំយុទ្ធសាស្ត្រសំខាន់ៗដទៃទៀត ដើម្បីរួមចំណែកពិពិធភាវូបនីយកម្ម ពាណិជ្ជូបនីយកម្ម និងចូលរួមបង្កើនផលចំណូលដល់កសិករ ឈានទៅទ្រទ្រង់ដល់កំណើនសេដ្ឋកិច្ចជាតិ។

៤៣- ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍កៅស៊ូធម្មជាតិឆ្ពោះទៅឆ្នាំ២០៣០ ត្រូវបានរៀបចំឡើងដើម្បីឆ្លើយតបទៅនឹងទិសដៅយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលកម្ពុជា ពិសេសយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ២០១៩-២០២៣ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម២០១៩-២០២៣ និងផែនការមេអភិវឌ្ឍន៍វិស័យកសិកម្មឆ្នាំ២០៣០។

## ២. ចក្ខុវិស័យ

៤៤- ដើម្បីរួមចំណែកសម្រេចបាននូវទិសដៅយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលកម្ពុជា ការអភិវឌ្ឍកៅស៊ូកម្ពុជាត្រូវបានរៀបចំឡើងដោយមានចក្ខុវិស័យចំបងដូចខាងក្រោម៖

> **“កៅស៊ូធម្មជាតិកម្ពុជា ជាអនុវិស័យមានលក្ខណៈបរិយាប័ន្ននិងប្រកួតប្រជែង ដែលផ្តល់ផលប្រយោជន៍ប្រកបដោយនិរន្តរភាពដល់គ្រប់ភាគីពាក់ព័ន្ធទាំងអស់”។**





## ៣. បេសកកម្ម

៤៥- ដើម្បីចូលរួមសម្រេចឱ្យបាននូវចក្ខុវិស័យខាងលើនេះភាគីពាក់ព័ន្ធទាំងអស់នឹងត្រូវបំពេញបេសកកម្មៈ

**“ធ្វើឱ្យប្រសើរឡើងនូវខ្សែច្រវាក់តម្លៃផលិតផលកៅស៊ូ ឱ្យមានលក្ខណៈអាចជឿទុកចិត្តបានទាំងបរិមាណ ទាំងគុណភាព និងមានភាពប្រកួតប្រជែង”។**

## ៤. គោលបំណងនិងគោលដៅ

### ៤.១ គោលបំណង

៤៦- ដើម្បីចូលរួមសម្រេចឱ្យបាននូវចក្ខុវិស័យនិងបេសកកម្មខាងលើ គោលបំណងរួមសម្រាប់អនុវត្ត មានដូចខាងក្រោមៈ

- បង្កើនផ្ទៃដីកៅស៊ូយកផលក្នុងអត្រាកំណើនសមាសប្រចាំឆ្នាំក្នុងរង្វង់២%
- បង្កើនផលិតផលកៅស៊ូក្នុងអត្រាកំណើនសមាសប្រចាំឆ្នាំក្នុងរង្វង់៤% និង
- បង្កើនផលចំណូលសរុបពីផលិតផលកៅស៊ូក្នុងអត្រាកំណើនសមាសប្រចាំឆ្នាំក្នុងរង្វង់៨%។

### ៤.២ គោលដៅ

៤៧- ដើម្បីឆ្លើយតបទៅនឹងគោលបំណងដែលបានកំណត់ខាងលើ គោលដៅឆ្ពោះទៅឆ្នាំ២០៣០ ដែលត្រូវសម្រេច រួមមានៈ

- បង្កើនផ្ទៃដីកៅស៊ូយកផលឱ្យបានចំនួនប្រមាណ ៣៣១ពាន់ហិកតា
- បង្កើនទិន្នផលឱ្យបានចំនួនប្រមាណ ១ ៤០០គ.ក្រ./ហិកតា/ឆ្នាំ
- បង្កើនផលិតផលកៅស៊ូឱ្យបានចំនួនប្រមាណ ៤៦៣ពាន់តោន
- បង្កើនការនាំចេញកៅស៊ូឱ្យបានចំនួនប្រមាណ ៤៤៩ពាន់តោន និង
- បង្កើនផលចំណូលសរុបពីផលិតផលកៅស៊ូឱ្យបានចំនួនប្រមាណ ៩៦១លានដុល្លារអាម៉េរិក។

## ៥. ក្របខណ្ឌយុទ្ធសាស្ត្រ

### ៥.១ ការវិភាគ TOWS

៤៨- ការវិភាគTOWS នឹងផ្តោតលើភាពខ្លាំងនិងកាលានុវត្តន៍ភាពនៃអនុវិស័យកៅស៊ូកម្ពុជា សម្រាប់ចូលរួមបង្កើតជាយន្តការដោះស្រាយបញ្ហាប្រឈមនិងហានីភ័យ (ភាពខ្សោយនិងភាពគំរាមកំហែង) ដែលអាចកើតមានឡើងចំពោះអនុវិស័យកៅស៊ូកម្ពុជា នៅពេលបច្ចុប្បន្ននិងនាពេលអនាគត។





តារាងទី៧៖ ការវិភាគម៉ាទ្រីកTOWS សម្រាប់យុទ្ធសាស្ត្រដោះស្រាយភាពខ្សោយនិងភាពគំរាមកំហែង

<table>
<tr><td colspan="2" rowspan="3">TOWS MATRIX<br>នៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍កៅស៊ូធម្មជាតិឆ្ពោះទៅឆ្នាំ២០៣០</td><td colspan="2">កត្តាខាងក្នុង</td></tr>
<tr><td>ភាពខ្លាំង (Strengths: S)</td><td>ភាពខ្សោយ (Weakness: W)</td></tr>
<tr><td>S1. ផ្ទៃដីកៅស៊ូយកផលបានបន្តកើនឡើង<br>S2. ផលិតផលកៅស៊ូនឹងបន្តកើនឡើង<br>S3. កេរ្យត្រ-អាកាសធាតុសមស្របសម្រាប់ផលិតកម្មកៅស៊ូធម្មជាតិ<br>S4. ជំងឺរាតត្បាតកៅស៊ូមានកម្រិតទាប<br>S5. សក្តានុពលក្នុងការបង្កើនទិន្នផលកៅស៊ូ<br>S6. សក្តានុពលក្នុងការបង្កើនតម្លៃបន្ថែមទាំងកៅស៊ូនិងឈើកៅស៊ូ</td><td>W1. ផលិតភាពនៅទាប<br>W2. ការប្រកួតប្រជែងពលកម្មពីវិស័យដទៃ<br>W3. កសិករកៅស៊ូគ្រួសារភាគច្រើនជាមនុស្សចាស់<br>W4. ការស្រាវជ្រាវបច្ចេកវិទ្យាកៅស៊ូនិងចំនួនអ្នកជំនាញនៅមានកម្រិត<br>W5. ការផ្តល់និងការទទួលយកបច្ចេកទេសសមស្របនៃដំណាំកៅស៊ូរបស់កសិករនៅមានកម្រិត<br>W6. ថ្លៃដើមផលិតផលកៅស៊ូខ្ពស់តែលក់បានតម្លៃទាប<br>W7. សមត្ថភាពអង្គភាពជំនាញ ទទួលបន្ទុក សមាគម និង សហគមន៍នៅមានកម្រិត<br>W8. កង្វះផ្នែកកៅស៊ូលំហូរខាងក្រោម</td></tr>
<tr><td rowspan="2">កត្តាខាងក្រៅ</td><td>កាលានុវត្តន៍ភាព<br>(Opportunities: O)</td><td>ភាពខ្លាំងនិង<br>កាលានុវត្តន៍ភាព (SO)</td><td>ភាពខ្សោយនិង<br>កាលានុវត្តន៍ភាព (WO)</td></tr>
<tr><td>O1. សន្តិភាពនិងស្ថេរភាពនាំឱ្យមានកំណើនសេដ្ឋកិច្ចល្អ<br>O2. រដ្ឋាភិបាលបាននិងកំពុងយកចិត្តទុកដាក់ក្នុងការអភិវឌ្ឍកៅស៊ូគ្រួសារ<br>O3. វត្តមាននៃគោលនយោបាយ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍</td><td>(S1, S2, O1, O2, O3, O8)<br>ជំរុញការផ្សព្វផ្សាយ បណ្តុះបណ្តាល បច្ចេកវិទ្យាកៅស៊ូសមស្របឱ្យសកម្ម ដើម្បីបង្កើនផលិតភាពកៅស៊ូ។<br>(S2, S6, O1, O2, O3, O8)<br>បង្កើនអំណាចចរចារបស់កសិករកៅស៊ូគ្រួសារជាមួយនឹងអ្នកទិញផលិតផលកៅស៊ូនិងអ្នកលក់ធាតុចូលសម្រាប់ដំណាំកៅស៊ូលើថ្លៃផលិតផលកៅស៊ូនិងធាតុចូល។</td><td>(W1,W2, W4, W5, W6, O1, O2, O3)<br>អង្គភាពរដ្ឋាភិបាលបន្តគាំទ្រនិងបង្កើនសកម្មភាពផ្សព្វផ្សាយ បណ្តុះបណ្តាល។<br>(W1, W2, W3, W6, W7, O1,O2, O3, O8)<br>អង្គភាពរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍បង្កើត គាំទ្រ និងពង្រឹងក្រុមកសិករកៅស៊ូគ្រួសារនិងក្រុមអ្នកចម្ការកៅស៊ូកសិឧស្សាហកម្ម។</td></tr>
</table>





| | | | |
|---|---|---|---|
| | នានា (RS, NSDP, IDP, ASDP)<br>O4. ភាពប្រសើរឡើងនៃនីតិវិធីធ្វើពាណិជ្ជកម្ម<br>O5. កៅស៊ូធម្មជាតិនៅតែជាតម្រូវការចាំបាច់សម្រាប់វិស័យឧស្សាហកម្ម (យានយន្ត សុខាភិបាល កីឡា និងផ្លូវ ថ្នល់ ។ល។)<br>O6. ភាពទំនាក់ទំនងកាន់តែប្រសើរជាមួយប្រទេសចិនដែលជាប្រទេសនាំចូលកៅស៊ូធំជាងគេលើពិភពលោក<br>O7. លទ្ធភាពនៃការបង្កើតផ្នែកកៅស៊ូលំហូរខាងក្រោម(ការងារ តម្លៃបន្ថែម និងកាត់បន្ថយការនាំចូល)<br>O8. វត្តមាននៃកិច្ចសហប្រតិបត្តិការជាមួយអង្គការដៃគូនិងសមាគមកៅស៊ូអន្តរជាតិកាន់តែទូលំទូលាយ | (S1, S2, S3, S4, O1, O2, O3, O8)<br>ពង្រឹងកម្មវិធីពិសោធ ស្រាវជ្រាវក្នុងការបង្កើតបច្ចេកវិទ្យាកៅស៊ូជឿនលឿននិងក្លូនកៅស៊ូមានទឹកជ័រច្រើន ដើមធំ ធន់នឹងការប្រែប្រួលអាកាសធាតុ ដើម្បីធានាកំណើនទិន្នផលខ្ពស់។<br>(S1, S2, S6, O3, O4, O5, O6, O8)<br>ការស្រាវជ្រាវ អភិវឌ្ឍន៍និងពង្រឹងគុណភាពកៅស៊ូ ដើម្បីរក្សាទីផ្សារដែលកំពុងមាននិងពង្រីកទីផ្សារសម្រាប់ដៃគូថ្មី ក្នុងគោលបំណងបង្កើនតម្លៃបន្ថែម។<br>(S2, S6, O1, O3, O5, O6, O7,O8)<br>ការស្រាវជ្រាវនិងអភិវឌ្ឍន៍ ផលិតផលកៅស៊ូថ្មីនិងជំរុញការប្រើប្រាស់ក្នុងប្រទេស។ | (W6, W7, O1, O2, O3, O8)<br>អង្គភាពរដ្ឋាភិបាលបង្កើតមជ្ឈមណ្ឌលកែច្នៃកៅស៊ូរួម ទីផ្សារកណ្ដាលកៅស៊ូសម្រាប់កសិករកៅស៊ូគ្រួសារ។<br>(W6, W8, O1, O3, O4, O5, O6, O7, O8)<br>អង្គភាពរដ្ឋាភិបាលបន្តជំរុញចង្អោមសកម្មភាពនៃគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មដែលពាក់ព័ន្ធនឹងអនុវិស័យកៅស៊ូ ឱ្យពិតជាបានដំណើរការនិងមានប្រសិទ្ធភាពដើម្បីបង្កើតរោងចក្រ សិប្បកម្មផលិតផលិតផលកៅស៊ូសម្រេច។ |
| | **ភាពគំរាមកំហែង**<br>(Threats: T) | **ភាពខ្លាំងនិង**<br>**ភាពគំរាមកំហែង** (ST) | **ភាពខ្សោយនិង**<br>**ភាពគំរាមកំហែង** (WT) |
| | T1. ការប្រកួតប្រជែងពីដំណាំផ្សេងៗ វិស័យឧស្សាហកម្ម និងសំណង់<br>T2. ការពង្រីកផ្ទៃដីនិងផលិតផលកៅស៊ូរបស់បណ្ដាប្រទេសដទៃ<br>T3. ចំណូលចិត្តអ្នកជំនាន់ក្រោយចំពោះមុខរបរកៅស៊ូធ្លាក់ចុះ | (S5, S6, T1, T2, T3, T8)<br>ជំរុញការផលិតមានគុណភាពនិងប្រសិទ្ធភាពសេដ្ឋកិច្ច ការធ្វើពិពិធកម្មកសិកម្ម ការសម្រួលបន្ថយពន្ធ អគ្គិសនី ឡូជីស្ទីក ដើម្បីជម្នះការប្រកួតប្រជែងពីខាងក្រៅ។<br>(S1, S2, S6, T3, T4, T5, T6, T8)<br>ជំរុញនិងពង្រឹងការអនុវត្តគោលនយោបាយ ផែនការ យុទ្ធសាស្ត្រអភិវឌ្ឍន៍កៅស៊ូ។ | (W1, W2, W3, W4, W5, W6, W7, W8, T1, T2, T3, T6, T7, T8)<br>បង្កើតមូលនិធិអភិវឌ្ឍន៍អនុ វិស័យកៅស៊ូ (CESS) ដើម្បីគាំទ្រនិងដោះស្រាយ។<br>(W7, T4, T5)<br>បង្កើតច្បាប់និងលិខិតគតិយុត្តក្រោមច្បាប់កៅស៊ូ និងពង្រឹង ការអនុវត្តលិខិតគតិយុត្តកៅស៊ូ។<br>(W7, W8, T1, T2, T3, T4, T5, T6, T7, T8) |





| | | | |
|---|---|---|---|
| | T4. កង្វះលិខិតគតិយុត្តផ្នែកកៅស៊ូនិងការអនុវត្តនៅមានកម្រិត<br>T5. លំហូរកៅស៊ូមិនទាន់កែច្នៃទៅបរទេសក្រៅផ្លូវការ<br>T6. ការគាំទ្រផ្នែកបច្ចេកទេស មធ្យោបាយ ថវិកា និងឥណទានរបស់រដ្ឋនិងដៃគូនានានៅមានកម្រិត<br>T7. ការប្រែប្រួលអាកាសធាតុនិងគ្រោះមហន្តរាយធម្ម-ជាតិ<br>T8. វិបត្តិសេដ្ឋកិច្ចនិងសង្គ្រាមពាណិជ្ជកម្ម | | បង្កើតក្រុមប្រឹក្សាអភិវឌ្ឍន៍កៅស៊ូដើម្បីបង្កើនលទ្ធភាព ប្រសិទ្ធភាពក្នុងការគ្រប់គ្រងនិងអភិវឌ្ឍអនុវិស័យកៅស៊ូប្រកបដោយនិរន្តរភាព។ |

## ៥.២ ស្នូលយុទ្ធសាស្ត្រ

៤៩- ផ្អែកលើការវិភាគ TOWS ខាងលើ ដើម្បីបង្កើតយន្តការជម្នះបញ្ហាប្រឈមនៅពេលបច្ចុប្បន្ននិងនាពេលអនាគត និងសម្រេចបានបេសកកម្មនិងគោលបំណងនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍កៅស៊ូធម្មជាតិនេះ ស្នូលយុទ្ធសាស្ត្រចំនួន០៤ ត្រូវបានដាក់ឡើងដើម្បីអនុវត្ត៖

**១. ការពង្រីកនិងការធ្វើឱ្យប្រសើរឡើងនូវខ្សែច្រវាក់ផលិតកម្មកៅស៊ូ។**
**២. ការលើកកម្ពស់ការងារពិសោធនិងការស្រាវជ្រាវកៅស៊ូ។**
**៣. ការពង្រឹងសេវាគាំទ្រនិងអន្តរភាព។**
**៤. ការជំរុញវិនិយោគនិងហិរញ្ញប្បទានតាមរយៈដៃគូក្នុងការអភិវឌ្ឍកៅស៊ូធម្មជាតិ។**

៥០- តារាងខាងក្រោមបង្ហាញពីស្នូលយុទ្ធសាស្ត្រអភិវឌ្ឍន៍កៅស៊ូធម្មជាតិ ដែលចូលរួមដោះស្រាយភាពខ្សោយនិងភាពគំរាមកំហែង ដែលកៅស៊ូធម្មជាតិកម្ពុជាបាននឹងប្រឈម នៅពេលបច្ចុប្បន្ននិងនាពេលអនាគត។





តារាងទី៨៖ ស្ទួលយុទ្ធសាស្ត្រសម្រាប់ដោះស្រាយបញ្ហាប្រឈម

| ល.រ | បញ្ហាប្រឈម (ភាពខ្សោយនិងភាពគំរាមកំហែង) | ស្ទួលយុទ្ធសាស្ត្រ | | | |
|---|---|---|---|---|---|
| | | ១ | ២ | ៣ | ៤ |
| ១ | W1. ផលិតភាពនៅទាប | + | + | + | + |
| ២ | W2. ការប្រកួតប្រជែងពលកម្មពីវិស័យដទៃ | + | + | + | + |
| ៣ | W3. កសិករកៅស៊ូគ្រួសារភាគច្រើនជាមនុស្សចាស់ | + | + | + | + |
| ៤ | W4. ការស្រាវជ្រាវបច្ចេកវិទ្យាកៅស៊ូនិងចំនួនអ្នកជំនាញនៅមានកម្រិត | | + | + | + |
| ៥ | W5. ការផ្តល់និងការទទួលយកបច្ចេកទេសសមស្របនៃដំណាំកៅស៊ូរបស់កសិករនៅមានកម្រិត | + | + | + | + |
| ៦ | W6. ថ្លៃដើមផលិតផលកៅស៊ូខ្ពស់ តែលក់បានតម្លៃទាប | + | + | + | + |
| ៧ | W7. សមត្ថភាពអង្គភាពជំនាញទទួលបន្ទុកសមាគមនិងសហគមន៍នៅមានកម្រិត | | | + | + |
| ៨ | W8. កង្វះផ្នែកកៅស៊ូលំហូរខាងក្រោម | | + | + | + |
| ៩ | T1. ការប្រកួតប្រជែងពីដំណាំផ្សេងៗ វិស័យឧស្សាហកម្ម និងសំណង់ | + | + | + | + |
| ១០ | T2. ការពង្រីកផ្ទៃដីនិងផលិតផលកៅស៊ូរបស់បណ្តាប្រទេសដទៃ | + | + | + | + |
| ១១ | T3. ចំណូលចិត្តអ្នកជំនាន់ក្រោយចំពោះមុខរបរកៅស៊ូធ្លាក់ចុះ | + | + | + | + |
| ១២ | T4. កង្វះលិខិតគតិយុត្តផ្នែកកៅស៊ូនិងការអនុវត្តនៅមានកម្រិត | | | + | + |
| ១៣ | T5. លំហូរកៅស៊ូមិនទាន់កែច្នៃទៅបរទេសក្រៅផ្លូវការ | + | | + | + |
| ១៤ | T6. ការគាំទ្រផ្នែកបច្ចេកទេស មធ្យោបាយ ថវិកា និងឥណទានរបស់រដ្ឋនិងដៃគូនានា នៅមានកម្រិត | | | + | + |
| ១៥ | T7. ការប្រែប្រួលអាកាសធាតុនិងគ្រោះមហន្តរាយធម្មជាតិ | + | + | + | + |
| ១៦ | T8. វិបត្តិសេដ្ឋកិច្ចនិងសង្គ្រាមពាណិជ្ជកម្ម | + | + | + | + |








រូបភាពទី៧៖ ក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍កៅស៊ូធម្មជាតិឆ្ពោះទៅឆ្នាំ២០៣០

## ៥.២.១ សូចនាករសមិទ្ធកម្ម

៥១- ប្រសិនបើស្នូលយុទ្ធសាស្ត្រដែលបានដាក់ចេញក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍កៅស៊ូធម្មជាតិឆ្ពោះទៅឆ្នាំ២០៣០ ត្រូវបានអនុវត្តសម្រេច នោះរំពឹងទុកថានឹងទទួលបាននូវលទ្ធផលចុងក្រោយសំខាន់ៗ ដូចខាងក្រោម៖

១. ផ្ទៃដីកៅស៊ូយកផលនឹងកើនដល់ប្រមាណ ៣៣១ពាន់ហិកតានៅឆ្នាំ២០៣០ បើធៀបនឹងឆ្នាំ២០១៩ ដែលមានចំនួនប្រមាណ ២៥០ពាន់ហិកតា គឺមានការកើនឡើងប្រមាណ ៦៩ពាន់ហិកតា ស្មើនឹងអត្រាកំណើន ៣២,៤០%។





២. ផលិតផលកៅស៊ូនឹងកើនដល់ប្រមាណ ៤៦៣ពាន់តោននៅឆ្នាំ២០៣០។ បើធៀបនឹងឆ្នាំ២០១៩ ដែលមានចំនួនប្រមាណ ២៨៨ពាន់តោន គឺមានការកើនឡើងប្រមាណ ១៧៥ពាន់តោន ស្មើនឹងអត្រាកំណើន ៦០,៧៦%។
៣. ផលចំណូលសរុបពីផលិតផលកៅស៊ូ នឹងកើនដល់ប្រមាណ ៩៦១លានដុល្លារអាម៉េរិកនៅឆ្នាំ២០៣០ បើធៀបនឹងឆ្នាំ២០១៩ ដែលមានចំនួនប្រមាណ ៣៩៧លានដុល្លារអាម៉េរិក គឺមានការកើនឡើងប្រមាណ ៥៦៤លានដុល្លារអាម៉េរិក ស្មើនឹងអត្រាកំណើន ១៤២,០៧%។ ក្នុងនោះ ផលចំណូលពីការនាំចេញកៅស៊ូ នឹងកើនដល់ប្រមាណ ៨៩៩លានដុល្លារអាម៉េរិកនៅឆ្នាំ២០៣០ បើធៀបនឹងឆ្នាំ២០១៩ ដែលមានចំនួនប្រមាណ ៣៧៧លានដុល្លារអាម៉េរិកគឺមានការកើនឡើងប្រមាណ ៥២២លានដុល្លារអាម៉េរិក ស្មើនឹងអត្រាកំណើន ១៣៨,៤៦% និងផលចំណូលពីការនាំចេញឈើកៅស៊ូ នឹងកើនដល់ប្រមាណ ៣៣លានដុល្លារអាម៉េរិកនៅឆ្នាំ២០៣០ បើធៀបនឹងឆ្នាំ២០១៩ ដែលមានចំនួនប្រមាណ ១៤លានដុល្លារអាម៉េរិក គឺមានការកើនឡើងប្រមាណ ១៩លានដុល្លារអាម៉េរិក ស្មើនឹងអត្រាកំណើន ១៣៥,៧១%។
៤. តម្លៃបន្ថែមដែលបានពីការកែច្នៃផលិតផលធៀបនឹងការមិនបានកែច្នៃផលិតផល មានចន្លោះពី ១២១លានដុល្លារអាម៉េរិកទៅ ១៥៦លានដុល្លារអាម៉េរិក និងមានអត្រាចន្លោះពី ១៦,០៨%ទៅ ៤៣,៥៤%។ ក្នុងនោះតម្លៃបន្ថែមបានពីឈើកៅស៊ូកែច្នៃនាំចេញ មានចន្លោះពី ០,៦៩%ទៅ ១៨,៧៩%។ នេះបញ្ជាក់ឱ្យឃើញច្បាស់ថា តម្លៃនៃការកែច្នៃមានសារសំខាន់ក្នុងការបង្កើនចំណូលបន្ថែមក្នុងផលិតកម្មកៅស៊ូធម្មជាតិ ដែលទាំងនេះមិនបានគិតបញ្ចូលតម្លៃបន្ថែមពីការផលិតផលិតផលកៅស៊ូសម្រេច(សំបកកង់យានយន្ត ស្រោមដៃ គ្រឿងសង្ហារឹម។ល។)។
៥. ជាមួយនឹងកំណើននៃផ្ទៃដីកៅស៊ូយកផលនិងផលិតផល អនុវិស័យកៅស៊ូក៏នឹងអាចផ្តល់ការងារជាអចិន្ត្រៃយ៍ប្រមាណ ១៥៥ពាន់ការងារនៅឆ្នាំ២០៣០។ បើធៀបនឹងឆ្នាំ២០១៩ ដែលមានចំនួនប្រមាណ ១៣៧ពាន់ការងារ ឃើញថានឹងមានការកើនឡើងប្រមាណ ១៨ពាន់ការងារ ស្មើនឹងអត្រាកំណើន ១៣,១៤%បន្ថែមទៀត ដែលរួមចំណែកដល់ការបង្កើតការងារនៅជនបទ ការកាត់បន្ថយនូវការធ្វើចំណាកស្រុក និងភាពក្រីក្រ (តារាងទី៩)។








តារាងទី៩៖ ចំណុចដៅនៃសមិទ្ធកម្មផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍កៅស៊ូធម្មជាតិឆ្ពោះទៅឆ្នាំ២០៣០

| **សូចនាករ/ឆ្នាំ** | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ | ២០២៤ | ២០២៥ | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ការបង្កើតការងារ (ពាន់ការងារ) | ១៣៧ | ១៤៧ | ១៥១ | ១៥៣ | ១៥៤ | ១៥៥ | ១៥៥ | ១៥៥ | ១៥៥ | ១៥៥ | ១៥៥ | ១៥៥ |
| ផ្ទៃដីកៅស៊ូសរុប (ពាន់ហ.ត.) | ៤០៦ | ៤០៦ | ៤០៧ | ៤០៧ | ៤០៧ | ៤០៨ | ៤០៨ | ៤០៨ | ៤០៨ | ៤០៨ | ៤០៩ | ៤០៩ |
| ផ្ទៃដីកៅស៊ូយកផល (ពាន់ហ.ត.) | ២៥០ | ៣០២ | ៣១៨ | ៣៣១ | ៣៣៥ | ៣៣៥ | ៣៣៦ | ៣៣៦ | ៣៣៥ | ៣៣៤ | ៣៣៣ | ៣៣១ |
| ទិន្នផល (គ.ក្រ./ហ.ត./ឆ្នាំ) | ១ ១៤៨ | ១ ១៦៩ | ១ ១៩០ | ១ ២១២ | ១ ២៣៤ | ១ ២៥៦ | ១ ២៧៩ | ១ ៣០៣ | ១ ៣២៦ | ១ ៣៥០ | ១ ៣៧៥ | ១ ៤០០ |
| ផលិតផលកៅស៊ូ (ពាន់តោន) | ២៨៨ | ៣៥៣ | ៣៧៨ | ៤០១ | ៤១៣ | ៤២១ | ៤៣០ | ៤៣៨ | ៤៤៤ | ៤៥១ | ៤៥៨ | ៤៦៣ |
| ការនាំចេញកៅស៊ូ (ពាន់តោន) | ២៨២ | ៣៤៣ | ៣៦៧ | ៣៨៩ | ៤០១ | ៤០៨ | ៤១៧ | ៤២៥ | ៤៣១ | ៤៣៧ | ៤៤៤ | ៤៤៩ |
| ចំណូលពីការនាំចេញកៅស៊ូ(លានដុល្លារ) | ៣៧៧ | ៤៥៧ | ៤៩០ | ៥១៩ | ៥៣៥ | ៥៤៥ | ៥៩៥ | ៦៤៩ | ៧០៥ | ៧៦៤ | ៨៣១ | ៨៩៩ |
| ចំណូលសរុបពីផលិតផលកៅស៊ូ (លានដុល្លារ) | ៣៩៧ | ៤៨៥ | ៥០៦ | ៥៣៧ | ៥៥៣ | ៥៧១ | ៦២៧ | ៦៩០ | ៧៥២ | ៨១៥ | ៨៨៣ | ៩៦១ |












តារាងទី១០៖ អត្រាកំណើននៃសូចនាករសំខាន់ៗ (%)

| សូចនាករ | ឆ្នាំ | | | | | | | | | | | | អត្រាកំណើនសមាសប្រចាំឆ្នាំ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ | ២០២៤ | ២០២៥ | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ | |
| ផ្ទៃដីកៅស៊ូយកផល | ២៣,៧៦ | ២០,៨០ | ៥,៣០ | ៤,០៩ | ១,២១ | ០,០០ | ០,៣០ | ០,០០ | -០,៣០ | -០,៣០ | -០,៣០ | -០,៦ | ២,៥៨ |
| ទិន្នផល | ៤,៤៦ | ១,៨៣ | ១,៨០ | ១,៨៥ | ១,៨២ | ១,៧៨ | ១,៨៣ | ១,៨៨ | ១,៧៧ | ១,៨១ | ១,៨៥ | ១,៨២ | ១,៨២ |
| ផលិតផលកៅស៊ូ | ២៩,៧៣ | ២២,៥៧ | ៧,០៨ | ៦,០៨ | ២,៩៩ | ១,៩៤ | ២,១៤ | ១,៨៦ | ១,៣៧ | ១,៥៨ | ១,៥៥ | ១,០៩ | ៤,៤១ |
| ចំណូលសរុបពីផលិតផលកៅស៊ូ | ៣៨,៦៨ | ២១,៨៦ | ៤,៣៣ | ៦,១៣ | ២,៩៨ | ៣,២៥ | ៩,៨១ | ១០,០៥ | ៨,៩៩ | ៨,៣៨ | ៨,៣៤ | ៨,៨៣ | ៨,៣៤ |












៤.២.២ យុទ្ធសាស្ត្រទី១៖ ការពង្រីកនិងការធ្វើឱ្យប្រសើរឡើងនូវខ្សែច្រវ៉ាក់ផលិតកម្មកៅស៊ូ

**ក. គោលបំណង**

បង្កើនផលិតភាពកៅស៊ូធម្មជាតិ សំដៅជួយបង្កើនប្រាក់ចំណូលដល់អ្នកដាំកៅស៊ូនិងសេដ្ឋកិច្ចជាតិ។

**ខ. កម្មវិធី/គម្រោង**

ដើម្បីសម្រេចបាននូវគោលបំណងខាងលើ កម្មវិធី/គម្រោងគាំទ្រចំនួន៧ត្រូវបានលើកឡើង ដើម្បីអនុវត្តៈ

តារាងទី១១៖ គម្រោងចំណាយលើយុទ្ធសាស្ត្រទី១ ការពង្រីកនិងការធ្វើឱ្យប្រសើរឡើងនូវខ្សែច្រវ៉ាក់ផលិតកម្មកៅស៊ូ

| យុទ្ធសាស្ត្រទី១ | កម្មវិធី/គម្រោង | ថវិកា | | ស្ថាប័ន/អង្គភាពអនុវត្ត | ពេលវេលាអនុវត្ត |
|---|---|---|---|---|---|
| | | ចំនួន (លានរៀល) | ប្រភព | | |
| ការពង្រីកនិងការធ្វើឱ្យប្រសើរឡើងនូវខ្សែច្រវ៉ាក់ផលិតកម្មកៅស៊ូ | ១.១ ការផ្ទេរបច្ចេកវិទ្យាដំណាំកៅស៊ូសមស្រប | ៥ ៣៣១ | ថវិកាជាតិ | ក.ស.ក.រ.ន./អ.ក.(ន.អ.ក) | ២០១៩-២០៣០ |
| | ១.២ ការអភិវឌ្ឍសហគមន៍កសិកម្មកៅស៊ូគ្រួសារ | ៤ ០៧៧ | ថវិកាជាតិ | ក.ស.ក.រ.ន./អ.ក.(ន.អ.ក និង ន.ទ.ស.អ) | ២០១៩-២០៣០ |
| | ១.៣ ការជំរុញទទួលយកបច្ចេកវិទ្យាកៅស៊ូធន់នឹងការប្រែប្រួលអាកាសធាតុ | ១ ៤៦៥ | ថវិកាជាតិ | ក.ស.ក.រ.ន./អ.ក.(ន.អ.ក) | ២០២១-២០៣០ |
| | ១.៤ ការធ្វើពិពិធកម្មកសិកម្ម | ១ ២២៨ | ថវិកាជាតិ | ក.ស.ក.រ.ន./អ.ក.(ន.អ.ក) | ២០២១-២០៣០ |
| | ១.៥ និរន្តរភាពកៅស៊ូធម្មជាតិ | ១ ៧២៥ | ថវិកាជាតិ | ក.ស.ក.រ.ន./អ.ក.(ន.អ.ក) | ២០២១-២០៣០ |
| | ១.៦ ការផ្សព្វផ្សាយ ការបណ្ដុះបណ្ដាលពីបច្ចេកវិទ្យាកែច្នៃ និងការគ្រប់គ្រងរោងចក្រ សិប្បកម្មកែច្នៃកៅស៊ូនិងឈើកៅស៊ូ | ២ ២៨៦ | ថវិកាជាតិ | ក.ស.ក.រ.ន./អ.ក.(ន.ក.ផ.ក) | ២០១៩-២០៣០ |
| | ១.៧ ការពង្រឹងតម្លៃផលិតផលកៅស៊ូ | ៤ ១០៨ | ថវិកាជាតិ | ក.ស.ក.រ.ន./អ.ក.(ន.ទ.ស.អ) | ២០១៩-២០៣០ |












**១. កម្មវិធី/គម្រោងទី១.១** ៖ការផ្ទេរបច្ចេកវិទ្យាដំណាំកៅស៊ូសមស្រប

**គោលបំណង** ៖បង្កើនចំណេះដឹងបច្ចេកទេសដំណាំកៅស៊ូដល់មន្ត្រីបង្គោល និងកសិករកៅស៊ូគ្រួសារ ព្រមទាំងគ្រប់គ្រងទិន្នន័យកៅស៊ូគ្រួសារ សំដៅជួយបង្កើនប្រាក់ចំណូលដល់កសិករ និងសេដ្ឋកិច្ចជាតិ។

តារាងទី១២៖ សូចនាករនិងគោលដៅនៃកម្មវិធី/គម្រោងទី១.១ នៃយុទ្ធសាស្ត្រទី១

| បរិយាយ | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ | ២០២៤ | ២០២៥ | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ | សរុប |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| កម្មវិធី/គម្រោង | ការផ្ទេរបច្ចេកវិទ្យាដំណាំកៅស៊ូសមស្រប | | | | | | | | | | | | |
| សូចនាករ | ១. ចំនួនកសិករទទួលបានចំណេះដឹងជំនាញចៀរជ័រ (នាក់)<br>២. ចំនួនមន្ត្រីបង្គោលទទួលបានបច្ចេកវិទ្យាកៅស៊ូ (នាក់) | | | | | | | | | | | | |
| ចំណុចដៅ១ | ៣១៥ | ៤៨០ | ៤៨០ | ៦០០ | ៦០០ | ៦០០ | ៦០០ | ៣៦០ | ៣៦០ | ៣៦០ | ៣០០ | ៣០០ | ៥ ៣៥៥ |
| ចំណុចដៅ២ | ៤០ | ៦០ | ៨០ | ៨០ | ៨០ | ៨០ | ៨០ | ៨០ | ៨០ | ៨០ | ៨០ | ៨០ | ៩០០ |
| ថវិកា (លានរៀល) | ២៥២ | ២៩៥ | ៦៨៣ | ៦១៧ | ៤៦០ | ៤០៨ | ៤១៣ | ៣៦៧ | ៥៨២ | ៥៥៣ | ៣៨០ | ៣២២ | ៥ ៣៣១ |

ដើម្បីសម្រេចបាននូវគោលបំណងខាងលើ សកម្មភាពមួយចំនួនត្រូវបានដាក់ឱ្យអនុវត្ត ដូចខាងក្រោម៖

- ការផ្ទេរបច្ចេកវិទ្យាដំណាំកៅស៊ូសមស្របដល់មន្ត្រីបង្គោល
- ការបណ្តុះបណ្តាល និងវាយតម្លៃបច្ចេកទេសការធ្វើថ្នាលពូជនិងថ្នាលបណ្តុះកូន
- ការបណ្តុះបណ្តាលជំនាញចៀរជ័រដល់កសិករកៅស៊ូគ្រួសារ
- ការស្រង់ស្ថិតិ និងការសិក្សាលក្ខណៈសម្បត្តិ (Profile) កៅស៊ូគ្រួសារ។

**២. កម្មវិធី/គម្រោងទី១.២** ៖ ការអភិវឌ្ឍសហគមន៍កសិកម្មកៅស៊ូគ្រួសារ

**គោលបំណង** ៖ ធ្វើឱ្យប្រសើរឡើងនូវលក្ខខណ្ឌនៃមុខរបរចម្បងរបស់សមាជិកសហគមន៍កសិកម្មកៅស៊ូគ្រួសារ និងរួមចំណែកក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។












តារាងទី១៣៖ សូចនាករ និងគោលដៅសម្រាប់ការអនុវត្តកម្មវិធី/គម្រោងទី១.២ នៃយុទ្ធសាស្ត្រទី១

| បរិយាយ | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ | ២០២៤ | ២០២៥ | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ | សរុប |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| កម្មវិធី/គម្រោង | ការអភិវឌ្ឍសហគមន៍កសិកម្មកៅស៊ូគ្រួសារ | | | | | | | | | | | | |
| សូចនាករ | ១. ចំនួនសហគមន៍ដែលបានចងក្រង<br>២. ចំនួនសហគមន៍ដែលបានពង្រឹង | | | | | | | | | | | | |
| ចំណុចដៅ១ | ២ | ១ | ៤ | ៥ | ៥ | ៥ | ៥ | ៥ | ៥ | ៥ | ៦ | ៦ | ៥៤ |
| ចំណុចដៅ២ | ៨ | ៨ | ៩ | ៩ | ១០ | ១៤ | ១៥ | ១៥ | ១៥ | ១៥ | ១៥ | ១៦ | ៥៤ |
| ថវិកា (លានរៀល) | ១៤៩ | ១២៧ | ២៧១ | ៣២២ | ៣៣៩ | ៣៧៩ | ៣៩០ | ៤០៤ | ៣៩៩ | ៤០៣ | ៤៣៨ | ៤៥៥ | ៤ ០៧៧ |

ដើម្បីសម្រេចបាននូវគោលបំណងខាងលើ សកម្មភាពមួយចំនួនត្រូវបានដាក់ឱ្យអនុវត្ត ដូចខាងក្រោម៖

- ការចងក្រងសហគមន៍កសិកម្មកៅស៊ូគ្រួសារ
- ការពង្រឹងសមត្ថភាពសហគមន៍កសិកម្មកៅស៊ូគ្រួសារ
- ការរៀបចំកិច្ចសម្របសម្រួលការធ្វើធុរៈកិច្ចកៅស៊ូ។

**៣. កម្មវិធី/គម្រោងទី១.៣** ៖ ការជំរុញនូវការទទួលយកបច្ចេកវិទ្យាកៅស៊ូធន់នឹងការប្រែប្រួលអាកាសធាតុ

**គោលបំណង** ៖ បង្កើនការទទួលយកបច្ចេកទេសកៅស៊ូវៃឆ្លាតខាងអាកាសធាតុរបស់កសិករកៅស៊ូគ្រួសារ ដោយការអនុវត្តកសិកម្មល្អ (GAP) ដើម្បីបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ។










តារាងទី១៨៖ សូចនាករ និងគោលដៅសម្រាប់ការអនុវត្តកម្មវិធី/គម្រោងទី១.៣ នៃយុទ្ធសាស្ត្រទី១

| បរិយាយ | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ | ២០២៤ | ២០២៥ | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ | សរុប |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| កម្មវិធី/គម្រោង | ការជំរុញនូវការទទួលយកបច្ចេកវិទ្យាកៅស៊ូធន់នឹងការប្រែប្រួលអាកាសធាតុ | | | | | | | | | | | | |
| សូចនាករ | ១. ចំនួនសិក្ខាកាម(នាក់)<br>២. ចំនួនចម្ការបង្ហាញ | | | | | | | | | | | | |
| ចំណុចដៅ១ | | | ៣០០ | ៣០០ | ៤០០ | ៤០០ | ៤០០ | ៤០០ | ៤០០ | ៤០០ | ៤០០ | ៤០០ | ៣ ៨០០ |
| ចំណុចដៅ២ | | | | ២ | ៤ | ៦ | ៨ | ៨ | ៨ | ៨ | ៨ | ៨ | ៨ |
| ថវិកា (លានរៀល) | | | ៥១ | ៧៧ | ១៣១ | ១៥៧ | ១៨២ | ១៨២ | ១៨១ | ១៧២ | ១៦៨ | ១៦៤ | ១ ៤៦៥ |

ដើម្បីសម្រេចបាននូវគោលបំណងខាងលើ សកម្មភាពមួយចំនួនត្រូវបានដាក់ឱ្យអនុវត្ត ដូចខាងក្រោម៖

- ការបណ្តុះបណ្តាលបច្ចេកទេសកសិកម្មវៃឆ្លាតខាងអាកាសធាតុនៃដំណាំកៅស៊ូតាមរយៈការអនុវត្តកសិកម្មល្អ(GAP)ដល់កសិករកៅស៊ូគ្រួសារ
- ការគាំទ្ររៀបចំចម្ការកៅស៊ូបង្ហាញ (Rubber demonstration plantation) ដោយប្រើប្រាស់បច្ចេកទេសការអនុវត្តកសិកម្មល្អ
- ការត្រួតពិនិត្យនិងវាយតម្លៃការអនុវត្តបច្ចេកទេសរបស់កសិករកៅស៊ូគ្រួសារ។

**៤ កម្មវិធី/គម្រោងទី១.៤៖** ការធ្វើពិពិធកម្មកសិកម្ម

**គោលបំណង** ៖ រក្សានិងបង្កើនចំណូលដល់កសិករកៅស៊ូគ្រួសារឱ្យមាននិរន្តរភាព នៅពេលមានបញ្ហាប្រឈមពីភាពមិនប្រាកដប្រជានៃទីផ្សារ ការឡើងចុះនៃថ្លៃកៅស៊ូ និងហានិភ័យនៃការប្រែប្រួលអាកាសធាតុ ដោយមិនពឹងអាស្រ័យដំណាំកៅស៊ូតែមួយមុខ។












តារាងទី១៥៖ សូចនាករ និងគោលដៅសម្រាប់ការអនុវត្តកម្មវិធី/គម្រោងទី១.៤ នៃយុទ្ធសាស្ត្រទី១

| **បរិយាយ** | **២០១៩** | **២០២០** | **២០២១** | **២០២២** | **២០២៣** | **២០២៤** | **២០២៥** | **២០២៦** | **២០២៧** | **២០២៨** | **២០២៩** | **២០៣០** | **សរុប** |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| កម្មវិធី/គម្រោង | ការធ្វើពិពិធកម្មកសិកម្ម | | | | | | | | | | | | |
| សូចនាករ | ១. ចំនួនសិក្ខាកាម(នាក់)<br>២. ចំនួនចម្ការ | | | | | | | | | | | | |
| ចំណុចដៅ១ | | | ៤៨០ | ៤៨០ | ៤៨០ | ៤៨០ | ៤៨០ | ៤៨០ | ៤៨០ | ៤៨០ | ៤៨០ | ៤៨០ | ៤ ៨០០ |
| ចំណុចដៅ២ | | | ២ | ២ | ២ | ២ | ២ | ២ | ២ | ២ | ២ | ២ | ២០ |
| ថវិកា (លានរៀល) | | | ១៨៦ | ១៤១ | ១៤២ | ១៤៥ | ១៤៨ | ៩៤ | ៩៣ | ៩៣ | ៩៤ | ៩២ | ១ ២២៨ |

ដើម្បីសម្រេចបាននូវគោលបំណងខាងលើ សកម្មភាពមួយចំនួនត្រូវបានដាក់ឱ្យអនុវត្ត ដូចខាងក្រោម៖

- ការសិក្សានិងរៀបចំម៉ូឌែលពិពិធកម្មកសិកម្មដំណាំកៅស៊ូឱ្យសមស្របទៅតាមក្សេត្រ-បរិស្ថាន
- ការគាំទ្ររៀបចំការចិញ្ចឹមឃ្មុំក្នុងសហគមន៍កសិកម្មកៅស៊ូគ្រួសារ
- ការផ្សព្វផ្សាយបច្ចេកទេសពិពិធកម្មកសិកម្មដំណាំកៅស៊ូ។

**៥ កម្មវិធី/គម្រោងទី១.៥៖** និរន្តរភាពកៅស៊ូធម្មជាតិ

**គោលបំណង** ៖ អភិវឌ្ឍកៅស៊ូធម្មជាតិប្រកបដោយនិរន្តរភាព តាមរយៈការបង្កើនផលិតភាពដំណាំកៅស៊ូ ប្រកបដោយភាតរបរិស្ថាន និងរក្សាសិទ្ធិការងារ។














តារាងទី១៦៖ សូចនាករ និងគោលដៅសម្រាប់ការអនុវត្តកម្មវិធី/គម្រោងទី១.៥ នៃយុទ្ធសាស្ត្រទី១

| **បរិយាយ** | **២០១៩** | **២០២០** | **២០២១** | **២០២២** | **២០២៣** | **២០២៤** | **២០២៥** | **២០២៦** | **២០២៧** | **២០២៨** | **២០២៩** | **២០៣០** | **សរុប** |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| កម្មវិធី/គម្រោង | និរន្តរភាពកៅស៊ូធម្មជាតិ | | | | | | | | | | | | |
| សូចនាករ | ១. ចំនួនក្រុមហ៊ុន<br>២. ចំនួនសិក្ខាកាម (នាក់) | | | | | | | | | | | | |
| ចំណុចដៅ១ | | | | | ១០ | ១០ | ១០ | ២០ | ២០ | ២០ | ២០ | ២០ | ១៣០ |
| ចំណុចដៅ២ | | | ៣០០ | ៣០០ | ៣០០ | ៣០០ | ៣០០ | ៣០០ | ៣០០ | ៣០០ | ៣០០ | ៣០០ | ៣ ០០០ |
| ថវិកា (លានរៀល) | | | ៥៩ | ១៤២ | ១៤៤ | ១៤៥ | ១៤៦ | ២២៩ | ២២៩ | ២៣០ | ២៣១ | ២៣៣ | ១ ៧២៥ |

ដើម្បីសម្រេចបាននូវគោលបំណងខាងលើ សកម្មភាពមួយចំនួនត្រូវបានដាក់ឱ្យអនុវត្ត ដូចខាងក្រោម៖

- ការបណ្តុះបណ្តាលការអនុវត្តកសិកម្មល្អ (GAP)
- ការសម្របសម្រួលក្នុងការទទួលបានវិញ្ញាបនបត្របញ្ជាក់និរន្តរភាពកៅស៊ូធម្មជាតិ។

**៦.កម្មវិធី/គម្រោង១.៦** ៖ ការផ្សព្វផ្សាយ ការបណ្តុះបណ្តាលពីបច្ចេកវិទ្យាកែច្នៃ និងការគ្រប់គ្រងរោងចក្រសិប្បកម្មកែច្នៃកៅស៊ូ និងឈើកៅស៊ូ

**គោលបំណង** ៖ ពង្រឹងគុណភាពផលិតផលកៅស៊ូនិងឈើកៅស៊ូ តាមស្តង់ដារ តម្រូវការទីផ្សារ និងរក្សាអត្តសញ្ញាណកៅស៊ូកម្ពុជា។

តារាងទី១៧៖ សូចនាករ និងគោលដៅសម្រាប់ការអនុវត្តកម្មវិធី/គម្រោងទី១.៦ នៃយុទ្ធសាស្ត្រទី១

| **បរិយាយ** | **២០១៩** | **២០២០** | **២០២១** | **២០២២** | **២០២៣** | **២០២៤** | **២០២៥** | **២០២៦** | **២០២៧** | **២០២៨** | **២០២៩** | **២០៣០** | **សរុប** |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| កម្មវិធី/គម្រោង | ការផ្សព្វផ្សាយ ការបណ្តុះបណ្តាលពីបច្ចេកវិទ្យាកែច្នៃ និងការគ្រប់គ្រងរោងចក្រសិប្បកម្មកែច្នៃជ័រកៅស៊ូ និងឈើកៅស៊ូ | | | | | | | | | | | | |
| សូចនាករ | ១. ចំនួនសិក្ខាកាម(នាក់)<br>២. ចំនួនចុះ(លើក)<br>៣. ចំនួនរោងចក្រសិប្បកម្ម | | | | | | | | | | | | |









| បរិយាយ | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ | ២០២៤ | ២០២៥ | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ | សរុប |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ចំណុចដៅ១ | ៦៦០ | ៦៥៥ | ៨០៥ | ៩០៨ | ៩៤៦ | ៩៦៥ | ៩៧៦ | ៩៨៩ | ៩៩៩ | ១ ០២៨ | ១ ០៣៧ | ១ ០៩៧ | ១១ ០៦៥ |
| ចំណុចដៅ២ | | | ៤ | ៨ | ៨ | ៨ | ៨ | ៨ | ៨ | ៨ | ៨ | ៨ | ៧៦ |
| ចំណុចដៅ៣ | | | ១៩០ | ២១៨ | ២៣៦ | ២៤១ | ២៤២ | ២៤៦ | ២៥២ | ២៥៦ | ២៦៥ | ២៦៩ | ២៦៩ |
| ថវិកា (លានរៀល) | ៩៤ | ៩៤ | ១៧៤ | ១៩៣ | ២០០ | ២០១ | ២០៥ | ២១០ | ២១៤ | ២២៦ | ២៣៣ | ២៤១ | ២ ២៨៦ |

ដើម្បីសម្រេចបាននូវគោលបំណងខាងលើ សកម្មភាពមួយចំនួនត្រូវបានដាក់ឱ្យអនុវត្ត ដូចខាងក្រោម៖

- ការផ្សព្វផ្សាយបច្ចេកទេសកែច្នៃនិងសាងសង់មណ្ឌលកែច្នៃដល់សហគមន៍កៅស៊ូគ្រួសារ
- ការផ្សព្វផ្សាយនិងបណ្តុះបណ្តាលបច្ចេកវិទ្យាការកែច្នៃល្អ (GPP) ដល់ម្ចាស់រោងចក្រ សិប្បកម្មកែច្នៃកៅស៊ូ និងឈើកៅស៊ូ
- ការចុះពិនិត្យនិងការណែនាំគោលការណ៍បច្ចេកទេសពាក់ព័ន្ធនឹងការកែច្នៃកៅស៊ូ និងឈើកៅស៊ូ។

**៧. កម្មវិធី/គម្រោងទី១.៧** ៖ ការពង្រឹងតម្លៃផលិតផលកៅស៊ូ

**គោលបំណង** ៖ បង្កើនការយល់ដឹងនិងពង្រឹងសមត្ថភាពប្រតិបត្តិករកៅស៊ូអំពីព័ត៌មានទីផ្សារកៅស៊ូ សំដៅឱ្យមានមូលដ្ឋានដាក់លាក់ក្នុងការចរចាថ្លៃ និងទទួលបានថ្លៃលក់បានល្អប្រសើរ។

តារាងទី១៨៖ សូចនាករ និងគោលដៅសម្រាប់ការអនុវត្តកម្មវិធី/គម្រោងទី១.៧ នៃយុទ្ធសាស្ត្រទី១

| បរិយាយ | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ | ២០២៤ | ២០២៥ | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ | សរុប |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| កម្មវិធី/គម្រោង | ការពង្រឹងតម្លៃផលិតផលកៅស៊ូ | | | | | | | | | | | | |
| សូចនាករ | ១. អត្រាថ្លៃលក់កៅស៊ូរបស់កសិករ (%)<br>២. ចំនួនកសិករ (នាក់) | | | | | | | | | | | | |








| បរិយាយ | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ | ២០២៤ | ២០២៥ | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ | សរុប |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ចំណុចដៅ១ | ៦៨ | ៦៨ | ៦៩ | ៦៩ | ៧០ | ៧១ | ៧២ | ៧២ | ៧៣ | ៧៤ | ៧៥ | ៧៥ | ៧៥ |
| ចំណុចដៅ២ | ៣៥០ | ៣៥០ | ៣៥០ | ៤៣០ | ៤៥០ | ៥០០ | ៥៣០ | ៥០០ | ៥០០ | ៥៣០ | ៥០០ | ៥៣០ | ៥ ៥២០ |
| ថវិកា (លានរៀល) | ១១០ | ១៧០ | ២៥២ | ២៧៦ | ២៨៧ | ៣៣៧ | ៣៧៧ | ៤៣៨ | ៣៨៩ | ៤៨៣ | ៤៤៣ | ៥៤៧ | ៤ ១០៨ |

ដើម្បីសម្រេចបាននូវគោលបំណងខាងលើ សកម្មភាពមួយចំនួនត្រូវបានដាក់ឱ្យអនុវត្ត ដូចខាងក្រោម៖

- ការផ្សព្វផ្សាយព័ត៌មានទីផ្សារកៅស៊ូ
- ការរៀបចំនិងការថែទាំប្រព័ន្ធផ្សព្វផ្សាយព័ត៌មានកៅស៊ូតាមអេឡិចត្រូនិច
- ការផ្សព្វផ្សាយផលិតផលកៅស៊ូ
- ការពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិក្នុងអនុវិស័យកៅស៊ូ។










### ៥.២.៣ យុទ្ធសាស្ត្រទី២៖ ការលើកកម្ពស់ការងារពិសោធនិងការស្រាវជ្រាវកៅស៊ូ

**ក. គោលបំណង**

កសាងបណ្តាញទិន្នន័យសម្រាប់ផ្សព្វផ្សាយ និងផ្ទេរបច្ចេកវិទ្យាដល់អ្នកដាំកៅស៊ូ ដើម្បីបង្កើនគុណភាពចម្ការ និងផលិតភាពដំណាំកៅស៊ូ សំដៅបង្កើននូវចំណូល ធ្វើឱ្យមាននិរន្តរភាព និងវឌ្ឍនភាពសេដ្ឋកិច្ច ដល់អ្នកដាំកៅស៊ូ និងនិរន្តរភាពបរិស្ថាន។

**ខ. កម្មវិធី/គម្រោង**

ដើម្បីសម្រេចបាននូវគោលបំណងខាងលើ កម្មវិធី/គម្រោងគាំទ្រចំនួន៣ត្រូវបានលើកឡើង ដើម្បីអនុវត្ត៖

តារាងទី១៩៖ គម្រោងចំណាយលើយុទ្ធសាស្ត្រទី២ ការលើកកម្ពស់ការពិសោធនិងការស្រាវជ្រាវកៅស៊ូ

| យុទ្ធសាស្ត្រទី២ | កម្មវិធី/គម្រោង | ថវិកា | | ស្ថាប័ន/អង្គភាពអនុវត្ត | ពេលវេលាអនុវត្ត |
|---|---|---|---|---|---|
| | | ចំនួន (លានរៀល) | ប្រភព | | |
| ការលើកកម្ពស់ការពិសោធន៍ និងការស្រាវជ្រាវកៅស៊ូ | ២.១ ការពង្រឹងការពិសោធន៍ និងការស្រាវជ្រាវដំណាំកៅស៊ូ | ១០ ០៣៥ | ថវិកាជាតិ | ក.ស.ក.រ.ន./អ.ក.(វ.ស.ក.ក) | ២០២០-២០៣០ |
| | ២.២ ការពង្រឹងគុណភាពផលិតផលកៅស៊ូកម្ពុជាស្របទៅតាមស្តង់ដារអន្តរជាតិ | ៦ ០២២ | ថវិកាជាតិ | ក.ស.ក.រ.ន./អ.ក.(វ.ស.ក.ក) | ២០២០-២០៣០ |
| | ២.៣ ការពង្រឹងយន្តការទ្រទ្រង់ដល់ការស្រាវជ្រាវដំណាំកៅស៊ូ និងកែលម្អគុណភាពហេដ្ឋារចនាសម្ព័ន្ធរូបវន្ត | ២៦ ៧៣៥ | ថវិកាជាតិ | ក.ស.ក.រ.ន./អ.ក.(វ.ស.ក.ក) | ២០២០-២០៣០ |









**១. កម្មវិធី/ គម្រោងទី២.១៖** ការពង្រឹងនូវការពិសោធនិងការស្រាវជ្រាវដំណាំកៅស៊ូ

**គោលបំណង** ៖ កសាងទិន្នន័យជាសារវន្ត ដើម្បីរៀបចំជាមគ្គុទ្ទេសនិងផ្សព្វផ្សាយដល់អ្នកដាំកៅស៊ូ សំដៅដល់ការបង្កើនផលចំណូលដល់អ្នកដាំកៅស៊ូ ហើយនិងការលើកស្ទួយសេដ្ឋកិច្ចគ្រួសារ និងសេដ្ឋកិច្ចជាតិ។

តារាងទី២០៖ សូចនាករ និងគោលដៅសម្រាប់ការអនុវត្តកម្មវិធី/គម្រោងទី២.១ នៃយុទ្ធសាស្ត្រទី២

| **បរិយាយ** | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ | ២០២៤ | ២០២៥ | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ | **សរុប** |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| កម្មវិធី/គម្រោង | ការពង្រឹងនូវការពិសោធនិងការស្រាវជ្រាវដំណាំកៅស៊ូ | | | | | | | | | | | | |
| សូចនាករ | ១. ចំនួនក្លូនកៅស៊ូ (ក្លូន)<br>២. ចំនួនសំណាកទឹកជ័រត្រូវវិភាគ (សំណាក) | | | | | | | | | | | | |
| ចំណុចដៅ១ | ៧៤ | ៧៤ | ៧៦ | ៧៦ | ៧៨ | ៧៨ | ៨០ | ៨០ | ៨២ | ៨២ | ៨៥ | ៨៥ | ៨៥ |
| ចំណុចដៅ២ | ៥២០ | ៥៥០ | ៥៨០ | ៦០០ | ៦២០ | ៦៥០ | ៦៧០ | ៦៨០ | ៧០០ | ៧២០ | ៧៥០ | ៧៧៥ | ៧ ៨១៥ |
| ថវិកា (លានរៀល) | ៦០០ | ៦៤០ | ៦៩០ | ៧៣៥ | ៧៨៥ | ៨១៥ | ៨៦៥ | ៨៩០ | ៩៤៥ | ៩៨០ | ១ ០២០ | ១ ០៧០ | ១០ ០៣៥ |

ដើម្បីសម្រេចបាននូវគោលបំណងខាងលើ សកម្មភាពមួយចំនួនត្រូវបានដាក់ឱ្យអនុវត្ត ដូចខាងក្រោម៖

- ការបង្កើត ការគ្រប់គ្រង និងស្រង់ទិន្នន័យចម្ការពិសោធ
- ការអភិវឌ្ឍនិងការគ្រប់គ្រងក្លូនកៅស៊ូ ការគ្រប់គ្រងច្បារពូជកៅស៊ូ និងរុក្ខសម្ភារ
- ការវិភាគសរីរៈទឹកជ័រ។

**២. កម្មវិធី/ គម្រោងទី២.២ ៖** ការពង្រឹងគុណភាពផលិតផលកៅស៊ូកម្ពុជាស្របទៅតាមស្តង់ដារអន្តរជាតិ

**គោលបំណង** ៖ សំដៅធ្វើប្រសើរឡើងនូវខ្សែច្រវាក់តម្លៃកៅស៊ូកម្ពុជា និងកិត្យានុភាពផលិតផលកៅស៊ូកម្ពុជាលើទីផ្សារអន្តរជាតិ ដើម្បីបង្កើននូវតម្លៃបន្ថែម ជំរុញនូវកំណើនសេដ្ឋកិច្ចសង្គមជាតិ និងនិរន្តរភាពផលិតកម្មកៅស៊ូ។







តារាងទី២១៖ សូចនាករ និងគោលដៅសម្រាប់ការអនុវត្តកម្មវិធី/គម្រោងទី២.២ នៃយុទ្ធសាស្ត្រទី២

| **បរិយាយ** | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ | ២០២៤ | ២០២៥ | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ | **សរុប** |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| កម្មវិធី/គម្រោង | ការពង្រឹងគុណភាពផលិតផលកៅស៊ូកម្ពុជាស្របទៅតាមស្តង់ដារអន្តរជាតិ | | | | | | | | | | | | |
| សូចនាករ | ១.ចំនួនតេស្តអន្តរមន្ទីរពិសោធន៍ (ដង)<br>២.ចំនួនមន្ទីរពិសោធន៍មូលដ្ឋានចុះបញ្ជិកា និងចុះបញ្ជិការោងចក្រ | | | | | | | | | | | | |
| ចំណុចដៅ១ | ៦ | ៦ | ៦ | ៦ | ៦ | ៦ | ៦ | ៦ | ៦ | ៦ | ៦ | ៦ | ៧២ |
| ចំណុចដៅ២ | ៣ | ៣ | ៣ | ៣ | ៣ | ៣ | ៣ | ៣ | ៣ | ៤ | ៤ | ៤ | ៣៩ |
| ថវិកា (លានរៀល) | ២៥៥ | ២៧៧ | ៣២០ | ៣៧០ | ៤០០ | ៤៧០ | ៥១០ | ៥៧០ | ៦២០ | ៦៨០ | ៧៥០ | ៨០០ | ៦ ០២២ |

ដើម្បីសម្រេចបាននូវគោលបំណងខាងលើ សកម្មភាពមួយចំនួនត្រូវបានដាក់ឱ្យអនុវត្ត ដូចខាងក្រោម៖

- ការពង្រឹងមន្ទីរពិសោធន៍ជាតិ មន្ទីរពិសោធន៍មូលដ្ឋាន និងរោងចក្រកែច្នៃកៅស៊ូ
- ការចុះបញ្ជិការរោងចក្រនិងមន្ទីរពិសោធន៍មូលដ្ឋានសម្រាប់ការទទួលស្គាល់និងសិទ្ធប្រើប្រាស់ ស្លាកសញ្ញា CSR។

**៣. កម្មវិធី/ គម្រោងទី២.៣** ៖ ការពង្រឹងយន្តការទ្រទ្រង់ដល់ការស្រាវជ្រាវដំណាំកៅស៊ូ និងកែលម្អគុណភាពហេដ្ឋារចនាសម្ព័ន្ធរូបវន្ត

**គោលបំណង** ៖ អភិបាលកិច្ចល្អក្នុងការងារពិសោធន៍ស្រាវជ្រាវ ការធ្វើសមាហរណកម្មវិស័យស្រាវជ្រាវ ជាមួយនិងអន្តរជាតិ ការផ្ទេរបច្ចេកវិទ្យានិងបណ្តុះបណ្តាលធនធានមនុស្ស ការកែលម្អ ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ការទ្រទ្រង់សុខមាលភាពនិងសុវត្ថិភាពពលកម្ម សំដៅបង្កើនប្រសិទ្ធិភាពស្រាវជ្រាវ ដើម្បីរួមចំណែកនិងជំរុញការអភិវឌ្ឍដំណាំកៅស៊ូប្រកបដោយប្រសិទ្ធភាពនិងចីរភាព។






តារាងទី២២៖ សូចនាករ និងគោលដៅសម្រាប់ការអនុវត្តកម្មវិធី/គម្រោងទី២.៣ នៃយុទ្ធសាស្ត្រទី២

| បរិយាយ | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ | ២០២៤ | ២០២៥ | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ | សរុប |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| កម្មវិធី/គម្រោង | ការពង្រឹងយន្តការទ្រទ្រង់ដល់ការស្រាវជ្រាវដំណាំកៅស៊ូ និងកែលម្អគុណភាពហេដ្ឋារចនាសម្ព័ន្ធរូបវន្ត | | | | | | | | | | | | |
| សូចនាករ | ១.ចំនួនផ្ទះកម្មករដែលត្រូវកែលម្អ<br>២.ចំនួនសិក្ខាកាម | | | | | | | | | | | | |
| ចំណុចដៅ១ | ២៥ | ២៥ | ១០ | ២០ | ២០ | ១៩ | ១៩ | ១៩ | ១៩ | ៨ | ៨ | ៨ | ២០០ |
| ចំណុចដៅ២ | ៣៥ | ៧៥ | ៧៥ | ៧៥ | ៧៥ | ៧៥ | ៧៥ | ៧៥ | ៧៥ | ៧៥ | ៧៥ | ៧៥ | ១ ៥៣៣ |
| ថវិកា (លានរៀល) | ១ ០១៥ | ១ ៦៥០ | ១ ៨៥០ | ១ ៩៧០ | ២ ២០០ | ២ ៣៥០ | ២ ៥៥០ | ២ ៧៥០ | ២ ៩៥០ | ២ ៣០០ | ២ ៤៥០ | ២ ៧០០ | ២៦ ៧៣៥ |

ដើម្បីសម្រេចបាននូវគោលបំណងខាងលើ សកម្មភាពមួយចំនួនត្រូវបានដាក់ឱ្យអនុវត្ត ដូចខាងក្រោម៖

- ការកែលម្អហេដ្ឋារចនាសម្ព័ន្ធរូបវន្ត
- ការបណ្តុះបណ្តាលធនធានមនុស្សនិងផ្ទេរបច្ចេកវិទ្យា
- ការចូលរួមដៃគូស្រាវជ្រាវជាមួយភាគីអន្តរជាតិ
- ការងារគ្រប់គ្រងរដ្ឋបាល។






### ៥.២.៤ យុទ្ធសាស្ត្រទី៣៖ ការពង្រឹងសេវាគាំទ្រនិងអង្គភាព

**ក. គោលបំណង**

ពង្រឹងកិច្ចដំណើរការនិងសមត្ថភាពគ្រប់គ្រងរបស់អង្គភាព ដើម្បីធានានិរន្តរភាពអនុវិស័យកៅស៊ូ។

**ខ. កម្មវិធី/គម្រោង**

ដើម្បីសម្រេចបាននូវគោលបំណងខាងលើ កម្មវិធី/គម្រោងគាំទ្រចំនួន៤ត្រូវបានលើកឡើង ដើម្បីអនុវត្ត៖

តារាងទី២៣៖ គម្រោងចំណាយលើយុទ្ធសាស្ត្រទី៣ ការពង្រឹងសេវាគាំទ្រនិងអង្គភាព

| **យុទ្ធសាស្ត្រទី៣** | **កម្មវិធី/គម្រោង** | **ថវិកា** | | **ស្ថាប័ន/អង្គភាពអនុវត្ត** | **ពេលវេលាអនុវត្ត** |
|---|---|---|---|---|---|
| | | **ចំនួន** (លានរៀល) | **ប្រភព** | | |
| ការពង្រឹងសេវាគាំទ្រនិងអង្គភាព | ៣.១ ការរៀបចំ ការអនុវត្តផែនការ និងការគ្រប់គ្រងថវិកាកម្មវិធី | ៥៧ ២១៩ | ថវិកាជាតិ | ក.ស.ក.រ.ន./អ.ក.(ន.ផ.ហ.ស) | ២០១៩-២០៣០ |
| | ៣.២ ការកសាង និងការអនុវត្តផែនការ គោលនយោបាយ អភិវឌ្ឍកៅស៊ូធម្មជាតិ | ១ ៥៦៦ | ថវិកាជាតិ | ក.ស.ក.រ.ន./អ.ក.(ន.ផ.ហ.ស) | ២០១៩-២០៣០ |
| | ៣.៣ ការពង្រឹងប្រព័ន្ធព័ត៌មានស្ថិតិកៅស៊ូធម្មជាតិ | ១ ៧៧៤ | ថវិកាជាតិ | ក.ស.ក.រ.ន./អ.ក.(ន.ផ.ហ.ស) | ២០១៩-២០៣០ |
| | ៣.៤ ការកសាងនិងការអនុវត្តលិខិតុករណ៍គតិយុត្តនិងអភិវឌ្ឍន៍ធនធានមនុស្ស | ២ ៥១៧ | ថវិកាជាតិ | ក.ស.ក.រ.ន./អ.ក.(ន.រ.ន) | ២០១៩-២០៣០ |








**១. កម្មវិធី/គម្រោងទី៣.១** ៖ការរៀបចំ ការអនុវត្តផែនការ និងការគ្រប់គ្រងថវិកាកម្មវិធី

**គោលបំណង** ៖បង្កើនប្រសិទ្ធភាពនិងភាពស័ក្តសិទ្ធ នៃការរៀបចំ និងការអនុវត្តថវិកាកម្មវិធី

តារាងទី២៤៖ សូចនាករ និងគោលដៅសម្រាប់ការអនុវត្តកម្មវិធី/គម្រោងទី៣.១ នៃយុទ្ធសាស្ត្រទី៣

| បរិយាយ | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ | ២០២៤ | ២០២៥ | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ | សរុប |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| កម្មវិធី/គម្រោង | ការរៀបចំ ការអនុវត្តផែនការ និងការគ្រប់គ្រងថវិកាកម្មវិធី | | | | | | | | | | | | |
| សូចនាករ | ១. អត្រាថវិកាត្រូវបានអនុវត្ត(%)<br>២. របាយការណ៍សមិទ្ធកម្ម | | | | | | | | | | | | |
| ចំណុចដៅ១ | ៩៥ | ៩៥ | ៩៥ | ៩៥ | ៩៥ | ៩៦ | ៩៦ | ៩៦ | ៩៦ | ៩៦ | ៩៦ | ៩៦ | ៩៦ |
| ចំណុចដៅ២ | ១ | ១ | ១ | ១ | ១ | ១ | ១ | ១ | ១ | ១ | ១ | ១ | ១២ |
| ថវិកា (លានរៀល) | ៣ ៤៨៩ | ៣ ៧៣០ | ៣ ៩៥៤ | ៤ ១៨៧ | ៤ ៣៩៤ | ៤ ៦១៣ | ៤ ៦១៣ | ៥ ០៨០ | ៥ ៣៤៩ | ៥ ៦៣០ | ៥ ៩៣១ | ៦ ២៥០ | ៥៧ ២១៩ |

ដើម្បីសម្រេចបាននូវគោលបំណងខាងលើ សកម្មភាពមួយចំនួនត្រូវបានដាក់ឱ្យអនុវត្ត ដូចខាងក្រោម៖

- ការរៀបចំនិងអនុវត្តថវិកាកម្មវិធី
- ការរៀបចំកិច្ចប្រជុំប្រចាំឆ្នាំលើការងារកៅស៊ូធម្មជាតិ
- ការគាំទ្រនិងសម្របសម្រួលអង្គភាព។

**២. កម្មវិធី/គម្រោងទី៣.២** ៖ការកសាង និងការអនុវត្តផែនការ គោលនយោបាយ អភិវឌ្ឍកៅស៊ូធម្មជាតិ

**គោលបំណង** ៖ជំរុញការអភិវឌ្ឍកៅស៊ូធម្មជាតិប្រកបដោយនិរន្តរភាព។










តារាងទី២៥៖ សូចនាករ និងគោលដៅសម្រាប់ការអនុវត្តកម្មវិធី/គម្រោងទី៣.២ នៃយុទ្ធសាស្ត្រទី៣

| បរិយាយ | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ | ២០២៤ | ២០២៥ | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ | សរុប |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| កម្មវិធី/គម្រោង | ការកសាង និងការអនុវត្តផែនការ គោលនយោបាយ អភិវឌ្ឍកៅស៊ូធម្មជាតិ | | | | | | | | | | | | |
| សូចនាករ | ១. ចំនួនផែនការយុទ្ធសាស្ត្រ<br>២. ចំនួនប្រជុំតាមដាន | | | | | | | | | | | | |
| ចំណុចដៅ១ | | | ១ | | | ១ | | | | | | | ២ |
| ចំណុចដៅ២ | | | ៥ | ៥ | ៥ | ៥ | ៥ | ៥ | ៥ | ៥ | ៥ | ៥ | ៥០ |
| ថវិកា (លានរៀល) | ៥ | ៣៨ | ៨៩ | ៣២០ | ១៣៣ | ១៤២ | ១២៦ | ១២៦ | ១២៧ | ១២៧ | ១៥០ | ១៨២ | ១ ៥៦៦ |

ដើម្បីសម្រេចបាននូវគោលបំណងខាងលើ សកម្មភាពមួយចំនួនត្រូវបានដាក់ឱ្យអនុវត្ត ដូចខាងក្រោម៖

- ការរៀបចំនិងតាមដានការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍កៅស៊ូធម្មជាតិ
- ការរៀបចំនិងតាមដានការអនុវត្តគោលនយោបាយសម្រាប់អនុវិស័យកៅស៊ូ។

**៣. កម្មវិធី/គម្រោងទី៣.៣** ៖ការពង្រឹងប្រព័ន្ធព័ត៌មានស្ថិតិកៅស៊ូធម្មជាតិ

**គោលបំណង** ៖ទទួលបានទិន្នន័យកៅស៊ូគ្រប់គ្រាន់និងជាក់លាក់ ស្របតាមវិធីសាស្ត្រស្ថិតិវិទ្យា សម្រាប់ជាធាតុចូលក្នុងការរៀបចំផែនការយុទ្ធសាស្ត្រនិងគោលនយោបាយអភិវឌ្ឍន៍កៅស៊ូធម្មជាតិ។

តារាងទី២៦៖ សូចនាករ និងគោលដៅសម្រាប់ការអនុវត្តកម្មវិធី/គម្រោងទី៣.៣ នៃយុទ្ធសាស្ត្រទី៣

| បរិយាយ | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ | ២០២៤ | ២០២៥ | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ | សរុប |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| កម្មវិធី/គម្រោង | ការពង្រឹងប្រព័ន្ធព័ត៌មានស្ថិតិកៅស៊ូធម្មជាតិ | | | | | | | | | | | | |
| សូចនាករ | ១. ចំនួនសិក្ខាកាម (នាក់)<br>២. ចំនួនចុះតាមដាន (លើក) | | | | | | | | | | | | |







| បរិយាយ | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ | ២០២៤ | ២០២៥ | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ | សរុប |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ចំណុចដៅ១ | | | | | ១៩០ | | ១៩០ | | ១៩០ | | ១៩០ | | ៧៦០ |
| ចំណុចដៅ២ | ១០ | ៩ | ៩ | ៩ | ៩ | ៩ | ៩ | ៩ | ៩ | ៩ | ៩ | ៩ | ១០៩ |
| ថវិកា (លានរៀល) | ៨៥ | ៧៥ | ១០១ | ៣១១ | ២០៥ | ១១៧ | ១៧៨ | ៩៥ | ២០៥ | ៩៨ | ១៨៣ | ១២២ | ១ ៧៧៤ |

ដើម្បីសម្រេចបាននូវគោលបំណងខាងលើ សកម្មភាពមួយចំនួនត្រូវបានដាក់ឱ្យអនុវត្ត ដូចខាងក្រោម៖

- ការរៀបចំបង្កើតប្រព័ន្ធព័ត៌មានស្ថិតិកៅស៊ូ
- ការតាមដាននិងវាយតម្លៃការអនុវត្តកម្មវិធីវិនិយោគសម្បទានដីសេដ្ឋកិច្ចលើដំណាំកៅស៊ូ
- ការចុះពិនិត្យនិងការវាយតម្លៃស្នាក់ការប្រមូលទិញជ័រកៅស៊ូគ្រួសារ។

៤. **កម្មវិធី/គម្រោងទី៣.៤** ៖ការកសាងនិងការអនុវត្តលិខិតុករណ៍គតិយុត្ត និងអភិវឌ្ឍន៍ធនធានមនុស្ស

**គោលបំណង** ៖លើកកម្ពស់និងពង្រឹងការអនុវត្តលិខិតគតិយុត្ត និងអភិវឌ្ឍធនធានមនុស្ស សំដៅគ្រប់គ្រងអនុវិស័យកៅស៊ូប្រកបដោយប្រសិទ្ធភាពនិងនិរន្តរភាព។

តារាងទី២៧៖ សូចនាករ និងគោលដៅសម្រាប់ការអនុវត្តកម្មវិធី/គម្រោងទី៣.៤ នៃយុទ្ធសាស្ត្រទី៣

| បរិយាយ | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ | ២០២៤ | ២០២៥ | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ | សរុប |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| កម្មវិធី/គម្រោង | ការកសាងនិងការអនុវត្តលិខិតុករណ៍គតិយុត្ត និងអភិវឌ្ឍន៍ធនធានមនុស្ស | | | | | | | | | | | | |
| សូចនាករ | ១. ចំនួនសេចក្តីព្រាងលិខិតគតិយុត្ត(ច្បាប់)<br>២. ចំនួនប្រតិបត្តិករ (នាក់) | | | | | | | | | | | | |
| ចំណុចដៅ១ | ២ | ១ | ២ | ៣ | ៣ | ៣ | ៣ | ៣ | ៣ | ៣ | ៣ | ៣ | ៣២ |
| ចំណុចដៅ២ | ៤៩៥ | ៥២០ | ៥៨០ | ៥៩០ | ៦៤០ | ៦៤០ | ៦៥០ | ៦៥០ | ៦៥០ | ៦៥០ | ៦៥០ | ៦៥០ | ៧ ៣៦៥ |
| ថវិកា(លានរៀល) | ១០៣ | ១០៣ | ១៦៩ | ២៥៧ | ៣០៣ | ២២៨ | ២២៤ | ២៣០ | ២២៤ | ២៣០ | ២២៤ | ២២១ | ២ ៥១៧ |








ដើម្បីសម្រេចបាននូវគោលបំណងខាងលើ សកម្មភាពមួយចំនួនត្រូវបានដាក់ឱ្យអនុវត្ត ដូចខាងក្រោម៖

- ការកសាងលិខិតុករណ៍គតិយុត្តពាក់ព័ន្ធអនុវិស័យកៅស៊ូ
- ការផ្សព្វផ្សាយលិខិតុករណ៍គតិយុត្តពាក់ព័ន្ធនឹងអនុវិស័យកៅស៊ូ
- ការបណ្តុះបណ្តាលសមត្ថភាពជំនាញគ្រប់គ្រងដល់មន្ត្រីរាជការ។

### ៤.២.៤ យុទ្ធសាស្ត្រទី៤៖ ការជំរុញវិនិយោគនិងហិរញ្ញប្បទានតាមរយៈដៃគូក្នុងការអភិវឌ្ឍកៅស៊ូធម្មជាតិ

ក. គោលបំណង៖ ពង្រឹងភាពជាដៃគូនិងស្វែងរកប្រភពហិរញ្ញប្បទានពីដៃគូនានា ដើម្បីរួមចំណែកគាំទ្រដល់ការអភិវឌ្ឍកៅស៊ូធម្មជាតិប្រកបដោយនិរន្តរភាព។

**ខ. កម្មវិធី/គម្រោង**

កម្មវិធី/គម្រោងគាំទ្រចំនួន៩ត្រូវបានលើកឡើង ដែលត្រូវស្វែងរកដៃគូនានា ដើម្បីគាំទ្រថវិកាវិនិយោគឬហិរញ្ញប្បទាន។

តារាងទី២៨៖ គម្រោងចំណាយលើយុទ្ធសាស្ត្រទី៤ ការជំរុញវិនិយោគ និងហិរញ្ញប្បទានតាមរយៈដៃគូក្នុងការអភិវឌ្ឍកៅស៊ូ

| **យុទ្ធសាស្ត្រទី៤** | **កម្មវិធី/គម្រោង** | **ថវិកា** | | **ស្ថាប័ន/អង្គភាពអនុវត្ត** | **ពេលវេលាអនុវត្ត** |
|---|---|---|---|---|---|
| | | **ចំនួន** (លានរៀល) | **ប្រភព** | | |
| ការជំរុញវិនិយោគ និងហិរញ្ញប្បទានតាមរយៈដៃគូក្នុងការអភិវឌ្ឍកៅស៊ូ | ៤.១ ការសិក្សាសក្តានុពលទីតាំង ដែលមានលក្ខណៈសម្បត្តិសមស្របនឹងដំណាំកៅស៊ូ | ១ ២៤៤ | ដៃគូអភិវឌ្ឍន៍ | ក.ស.ក.រ.ន./អ.ក.(ន.អ.ក) | ២០២៤-២០២៧ |
| | ៤.២ ការអភិវឌ្ឍដំណាំកៅស៊ូគ្រួសារ | ៦៥ ១៩២ | ដៃគូអភិវឌ្ឍន៍ | ក.ស.ក.រ.ន./អ.ក.(ន.អ.ក) | ២០២២-២០២៨ |
| | ៤.៣ ប្រព័ន្ធតាមដានចម្ការកៅស៊ូគ្រួសារក្នុងប្រទេសកម្ពុជា | ៣ ៨៨៦ | ដៃគូអភិវឌ្ឍន៍ | ក.ស.ក.រ.ន./អ.ក.(ន.អ.ក) | ២០២១-២០២៦ |
| | ៤.៤ ការសាងសង់មជ្ឈមណ្ឌលកែច្នៃកៅស៊ូសន្លឹក នៅក្នុងសហគមន៍កសិកម្មកៅស៊ូគ្រួសារ | ១៦ ៥៨០ | ដៃគូអភិវឌ្ឍន៍ | ក.ស.ក.រ.ន./អ.ក.(ន.ក.ផ.ក) | ២០២១-២០៣០ |








| យុទ្ធសាស្ត្រទី៤ | កម្មវិធី/គម្រោង | ថវិកា | | ស្ថាប័ន/អង្គភាពអនុវត្ត | ពេលវេលាអនុវត្ត |
|---|---|---|---|---|---|
| | | ចំនួន (លានរៀល) | ប្រភព | | |
| | ៤.៥ ការរៀបចំបង្កើតមណ្ឌលទីផ្សារកៅស៊ូ | ២ ៣០៩ | ដៃគូអភិវឌ្ឍន៍ | ក.ស.ក.រ.ន./អ.ក.(ន.ទ.ស.អ) | ២០២៣-២០៣០ |
| | ៤.៦ ការគ្រប់គ្រងទិន្នន័យកៅស៊ូតាមប្រព័ន្ធព័ត៌មានភូមិសាស្ត្រ(GIS) | ១ ២៧៣ | ដៃគូអភិវឌ្ឍន៍ | ក.ស.ក.រ.ន./អ.ក.(ន.អ.ក និងន.ផ.ហ.ស) | ២០២៧-២០៣០ |
| | ៤.៧ ការគាំទ្រសមាគមអភិវឌ្ឍន៍កៅស៊ូកម្ពុជា | ៦៧៣ | ដៃគូអភិវឌ្ឍន៍ | ក.ស.ក.រ.ន./អ.ក.(ន.អ.ក) | ២០២៣-២០២៦ |
| | ៤.៨ ការអភិវឌ្ឍធនធានមនុស្សក្នុងអនុវិស័យកៅស៊ូ | ១ ១៦៥ | ដៃគូអភិវឌ្ឍន៍ | ក.ស.ក.រ.ន./អ.ក.(ន.រ.ន) | ២០២១-២០៣០ |
| | ៤.៩ ការសិក្សាទីតាំងបង្កើតទីក្រុងកៅស៊ូ | ៥៦ | ដៃគូអភិវឌ្ឍន៍ | ក.ស.ក.រ.ន./អ.ក.(ន.ក.ផ.កនិង ន.ទ.ស.អ) | ២០២៤-២០២៥ |

១. **កម្មវិធី/គម្រោងទី៤.១** ៖ការសិក្សាសក្តានុពលទីតាំងដែលមានលក្ខណៈសម្បត្តិសមស្របនឹងដំណាំកៅស៊ូ

**គោលបំណង** ៖កំណត់ប្រភេទនិងដីជាតិដី តាមទីតាំងភូមិសាស្ត្រដែលមានលក្ខណៈសមស្របសម្រាប់ដំណាំកៅស៊ូ សំដៅផ្តល់អនុសាសន៍ក្នុងការដាំដុះនិងការប្រើប្រាស់ដីបានត្រឹមត្រូវ រួមចំណែកកាត់បន្ថយថ្លៃដើម និងបង្កើនប្រាក់ចំណូលដល់អ្នកដាំកៅស៊ូ។

តារាងទី២៩៖ សូចនាករ និងគោលដៅសម្រាប់ការអនុវត្តកម្មវិធី/គម្រោងទី៤.១ នៃយុទ្ធសាស្ត្រទី៤

| បរិយាយ | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ | ២០២៤ | ២០២៥ | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ | សរុប |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| កម្មវិធី/គម្រោង | ការសិក្សាសក្តានុពលទីតាំងដែលមានលក្ខណៈសម្បត្តិសមស្របនឹងដំណាំកៅស៊ូ | | | | | | | | | | | | |
| សូចនាករ | ១. វត្ថុផ្សព្វផ្សាយ<br>២. សំណាកដី | | | | | | | | | | | | |








| បរិយាយ | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ | ២០២៤ | ២០២៥ | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ | សរុប |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ចំណុចដៅ១ | | | | | | | | ៤ | ៤ | | | | ៨ |
| ចំណុចដៅ២ | | | | | | ៨០០ | ៨០០ | | | | | | ១ ៦០០ |
| ថវិកា (លានរៀល) | | | | | | ៥២៤ | ៥០៣ | ១៥០ | ៦៧ | | | | ១ ២៤៤ |

ដើម្បីសម្រេចបាននូវគោលបំណងខាងលើ សកម្មភាពមួយចំនួនត្រូវបានដាក់ឱ្យអនុវត្ត ដូចខាងក្រោម៖

- ការសិក្សាភូមិសាស្ត្រនិងវិភាគសំណាកដី
- ការរៀបចំប្រព័ន្ធផ្សព្វផ្សាយឌីជីថលស្តីពីបច្ចេកវិទ្យាដំណាំកៅស៊ូ
- សិក្ខាសាលាផ្សព្វផ្សាយពីប្រព័ន្ធផ្សព្វផ្សាយឌីជីថល។

**២. កម្មវិធី/គម្រោងទី៤.២** ៖ ការអភិវឌ្ឍដំណាំកៅស៊ូគ្រួសារ

**គោលបំណង** ៖លើកកម្ពស់ជីវភាពរបស់ប្រជាពលរដ្ឋមូលដ្ឋាននៅតាមតំបន់ជនបទ តាមរយៈការគាំទ្រការអភិវឌ្ឍកៅស៊ូគ្រួសារ និងជំរុញទំនាក់ទំនងរវាងសហគមន៍កសិកម្មកៅស៊ូគ្រួសារ អ្នកកែច្នៃ និងអ្នកនាំចេញ។

តារាងទី៣០៖ សូចនាករ និងគោលដៅសម្រាប់ការអនុវត្តកម្មវិធី/គម្រោងទី៤.២ នៃយុទ្ធសាស្ត្រទី៤

| បរិយាយ | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ | ២០២៤ | ២០២៥ | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ | សរុប |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| កម្មវិធី/គម្រោង | ការអភិវឌ្ឍដំណាំកៅស៊ូគ្រួសារ | | | | | | | | | | | | |
| សូចនាករ | ១. ផ្ទៃដីដាដុះ (ហិកតា)<br>២. ចំនួនសហគមន៍ | | | | | | | | | | | | |
| ចំណុចដៅ១ | | | | | ១ ៣០០ | ២ ៣០០ | ២ ៤០០ | ៦ ០០០ | ៦ ០០០ | ៦ ០០០ | - | - | ៦ ០០០ |
| ចំណុចដៅ២ | | | | ១៥ | ១៥ | ១៥ | ១៥ | ១៥ | ១៥ | ១៥ | | | ១០៥ |
| ថវិកា (លានរៀល) | | | | ៣ ៩៦៣ | ៦ ២៦៧ | ១០ ៤៣៦ | ១៤ ៣៨៤ | ៩ ៦៦៨ | ៩ ៤២៤ | ១១ ០៥០ | | | ៦៥ ១៩២ |










ដើម្បីសម្រេចបាននូវគោលបំណងខាងលើ សកម្មភាពមួយចំនួនត្រូវបានដាក់ឱ្យអនុវត្ត ដូចខាងក្រោម៖

- ការផ្តល់ឥណទានដល់កសិករសម្រាប់ធ្វើការដាំដុះកៅស៊ូ
- ការជួយគាំទ្រជំនួយការបច្ចេកទេសដំណាំកៅស៊ូ និងការកែច្នៃដល់សហគមន៍កសិកម្មកៅស៊ូគ្រួសារ
- ការជួយគាំទ្រដល់សហគមន៍កសិកម្មកៅស៊ូគ្រួសារ
- ការគ្រប់គ្រងគម្រោងនិងការគាំទ្រអនុវិស័យកៅស៊ូ។

**៣ កម្មវិធី/គម្រោងទី៤.៣** ៖ប្រព័ន្ធតាមដានចម្ការកៅស៊ូគ្រួសារក្នុងប្រទេសកម្ពុជា

**គោលបំណង** ៖ទទួលបានព័ត៌មាននិងទិន្នន័យជាក់លាក់សម្រាប់ជាធាតុចូលក្នុងរៀបចំ ការវិនិយោគ គោលនយោបាយ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍កៅស៊ូធម្មជាតិ។

តារាងទី៣១៖ សូចនាករ និងគោលដៅសម្រាប់ការអនុវត្តកម្មវិធី/គម្រោងទី៤.៣ នៃយុទ្ធសាស្ត្រទី៤

| បរិយាយ | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ | ២០២៤ | ២០២៥ | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ | សរុប |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| កម្មវិធី/គម្រោង | ប្រព័ន្ធតាមដានចម្ការកៅស៊ូគ្រួសារក្នុងប្រទេសកម្ពុជា | | | | | | | | | | | | |
| សូចនាករ | ១. ចំនួនសិក្ខាកាម (នាក់)<br>២. ចំនួនសំណាកសម្ភាសន៍ | | | | | | | | | | | | |
| ចំណុចដៅ១ | | | ២២០ | ៤០ | ១៤០ | ១៤០ | ១៤០ | | | | | | ៦៨០ |
| ចំណុចដៅ២ | | | ២ ០០០ | ៤០០ | ៤០០ | ៤០០ | ២ ០០០ | | | | | | ៥ ២០០ |
| ថវិកា (លានរៀល) | | | ១ ៣៤០ | ៥៤៩ | ៦៦៦ | ៦៦៦ | ៦៦៦ | | | | | | ៣ ៨៨៦ |

ដើម្បីសម្រេចបាននូវគោលបំណងខាងលើ សកម្មភាពមួយចំនួនត្រូវបានដាក់ឱ្យអនុវត្ត ដូចខាងក្រោម៖

- ការប្រមូលព័ត៌មានពីកសិករកៅស៊ូគ្រួសារ
- ការបណ្តុះបណ្តាលកសិករនិងមន្ត្រីជំនាញលើការវិភាគនិងត្រួតពិនិត្យចម្ការកៅស៊ូគ្រួសារ
- សិក្ខាសាលាផ្សព្វផ្សាយព័ត៌មានអំពីចម្ការកៅស៊ូគ្រួសារនិងកសិករកៅស៊ូគ្រួសារ។










**៤. កម្មវិធី/គម្រោងទី៤.៤** ៖ ការសាងសង់មជ្ឈមណ្ឌលកែច្នៃកៅស៊ូសន្លឹក នៅក្នុងសហគមន៍កសិកម្មកៅស៊ូគ្រួសារ

**គោលបំណង** ៖ បង្ហាញនិងជំរុញកសិករឱ្យទទួលយកបច្ចេកទេសកែច្នៃកៅស៊ូសន្លឹក សំដៅបង្កើនតម្លៃបន្ថែម លើកកម្ពស់កម្រិតជីវភាពដល់កសិករក្នុងសហគមន៍កសិកម្មកៅស៊ូគ្រួសារ។

តារាងទី៣២៖ សូចនាករ និងគោលដៅសម្រាប់ការអនុវត្តកម្មវិធី/គម្រោងទី៤.៤ នៃយុទ្ធសាស្ត្រទី៤

| **បរិយាយ** | **២០១៩** | **២០២០** | **២០២១** | **២០២២** | **២០២៣** | **២០២៤** | **២០២៥** | **២០២៦** | **២០២៧** | **២០២៨** | **២០២៩** | **២០៣០** | **សរុប** |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| កម្មវិធី/គម្រោង | ការសាងសង់មជ្ឈមណ្ឌលកែច្នៃកៅស៊ូសន្លឹក នៅក្នុងសហគមន៍កសិកម្មកៅស៊ូគ្រួសារ | | | | | | | | | | | | |
| សូចនាករ | ១. ចំនួនមជ្ឈមណ្ឌល<br>២. ចំនួនចុះ (លើក) | | | | | | | | | | | | |
| ចំណុចដៅ១ | | | ១ | ២ | ២ | ២ | ២ | ២ | ២ | ២ | ២ | ២ | ១៩ |
| ចំណុចដៅ២ | | | ៤ | ៨ | ៨ | ៨ | ៨ | ៨ | ៨ | ៨ | ៨ | ៨ | ៧៦ |
| ថវិកា (លានរៀល) | | | ៨២៣ | ១ ៣០៨ | ១ ៣២៦ | ១ ៦៦១ | ១ ៦៦៣ | ១ ៦៧៤ | ១ ៣៧១ | ២ ២៤៧ | ២ ២៤៨ | ២ ២៦០ | ១៦ ៥៨០ |

ដើម្បីសម្រេចបាននូវគោលបំណងខាងលើ សកម្មភាពមួយចំនួនត្រូវបានដាក់ឱ្យអនុវត្ត ដូចខាងក្រោម៖

- ការសាងសង់មជ្ឈមបណ្ឌលកែច្នៃកៅស៊ូសន្លឹក
- ការសម្របសម្រួលក្នុងការផ្តល់ជំនួយបច្ចេកទេសកែច្នៃ។

**៥. កម្មវិធី/គម្រោងទី៤.៥** ៖ ការរៀបចំបង្កើតមណ្ឌលទីផ្សារកៅស៊ូ

**គោលបំណង** ៖ ធ្វើឱ្យប្រសើរឡើងនូវការធ្វើធុរកិច្ចកៅស៊ូក្នុងស្រុករបស់កសិករកៅស៊ូគ្រួសារ មានទីផ្សារជាក់លាក់ បង្កើនថ្លៃកៅស៊ូនៅចម្ការរបស់កសិករ ទទួលបានថ្លៃកៅស៊ូខ្ពស់សមស្របតាមថ្លៃនៅលើទីផ្សារកៅស៊ូពិភពលោក និងប្រាក់ចំណូលកើនឡើង។










តារាងទី៣៣៖ សូចនាករ និងគោលដៅសម្រាប់ការអនុវត្តកម្មវិធី/គម្រោងទី៤.៥ នៃយុទ្ធសាស្ត្រទី៤

| បរិយាយ | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ | ២០២៤ | ២០២៥ | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ | សរុប |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| កម្មវិធី/គម្រោង | ការរៀបចំបង្កើតមណ្ឌលទីផ្សារកៅស៊ូ | | | | | | | | | | | | |
| សូចនាករ | ១. ចំនួនមណ្ឌល(ទីតាំង)<br>២. ចំនួនដេញថ្លៃ (ដង) | | | | | | | | | | | | |
| ចំណុចដៅ១ | | | | | | | ១ | ១ | ១ | ១ | | | ៤ |
| ចំណុចដៅ២ | | | | | | | ៤០ | ៤០ | ៤០ | ៤០ | ៤០ | ៤០ | ២៤០ |
| ថវិកា (លានរៀល) | | | | | ៥២៧ | ២៦៥ | ៣៥៦ | ៣៥៤ | ៣៥១ | ៣៥១ | ១៩ | ៨៧ | ២ ៣០៩ |

ដើម្បីសម្រេចបាននូវគោលបំណងខាងលើ សកម្មភាពមួយចំនួនត្រូវបានដាក់ឱ្យអនុវត្ត ដូចខាងក្រោម៖

- ការចុះសិក្សាលទ្ធភាពបង្កើតមណ្ឌលទីផ្សារក្នុងស្រុកតាមតំបន់
- ការបង្កើតមណ្ឌលទីផ្សារកៅស៊ូក្នុងស្រុកតាមតំបន់
- ការសិក្សាស្រាវជ្រាវនិងរៀបចំចងក្រងឯកសារបង្កើតមជ្ឈមណ្ឌលទីផ្សារកៅស៊ូ។

៦. **កម្មវិធី/គម្រោងទី៤.៦** ៖ការគ្រប់គ្រងទិន្នន័យកៅស៊ូតាមប្រព័ន្ធព័ត៌មានភូមិសាស្ត្រ (GIS)

**គោលបំណង** ៖លើកកម្ពស់ការគ្រប់គ្រងទិន្នន័យកៅស៊ូគ្រួសារ និងកៅស៊ូកសិឧស្សាហកម្ម ដោយប្រើប្រាស់ប្រព័ន្ធព័ត៌មានភូមិសាស្ត្រ (Geographic Information System: GIS) សម្រាប់រៀបចំគោលនយោបាយ ផែនការអភិវឌ្ឍន៍ឱ្យមានប្រសិទ្ធភាពខ្ពស់ និងផ្តល់អនុសាសន៍បច្ចេកទេសដំណាំកៅស៊ូដល់អ្នកដាំ។










តារាងទី៣៨៖ សូចនាករ និងគោលដៅសម្រាប់ការអនុវត្តកម្មវិធី/គម្រោងទី៤.៦ នៃយុទ្ធសាស្ត្រទី៤

| **បរិយាយ** | **២០១៩** | **២០២០** | **២០២១** | **២០២២** | **២០២៣** | **២០២៤** | **២០២៥** | **២០២៦** | **២០២៧** | **២០២៨** | **២០២៩** | **២០៣០** | **សរុប** |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| កម្មវិធី/គម្រោង | ការគ្រប់គ្រងទិន្នន័យកៅស៊ូតាមប្រព័ន្ធព័ត៌មានភូមិសាស្ត្រ (GIS) | | | | | | | | | | | | |
| សូចនាករ | ១. ចំនួនខេត្ត<br>២. ចំនួនសិក្ខាកាម (នាក់) | | | | | | | | | | | | |
| ចំណុចដៅ១ | | | | | | | | | ៥ | ៥ | ៥ | ៥ | ២០ |
| ចំណុចដៅ២ | | | | | | | | | ៥០ | ៥០ | ៥០ | ៥០ | ២០០ |
| ថវិកា (លានរៀល) | | | | | | | | | ៤០០ | ២៩១ | ២៩១ | ២៩១ | ១ ២៧៣ |

ដើម្បីសម្រេចបាននូវគោលបំណងខាងលើ សកម្មភាពមួយចំនួនត្រូវបានដាក់ឱ្យអនុវត្ត ដូចខាងក្រោម៖

- ការបណ្តុះបណ្តាលធនធានមនុស្សអំពីប្រព័ន្ធព័ត៌មានភូមិសាស្ត្រ (GIS)
- ការចុះប្រមូល វិភាគនិងចងក្រងទិន្នន័យព័ត៌មានកៅស៊ូគ្រួសារនិងកៅស៊ូកសិឧស្សាហកម្ម។

**៧. កម្មវិធី/គម្រោងទី៤.៧** ៖ ការគាំទ្រសមាគមអភិវឌ្ឍន៍កៅស៊ូកម្ពុជា

**គោលបំណង** ៖ បង្កើនប្រសិទ្ធភាពនិងធានានិរន្តរភាពការងាររបស់សមាគម តាមរយៈការលើកកម្ពស់កិច្ចសហប្រតិបត្តិការរវាងស្ថាប័នរដ្ឋនិងផ្នែកឯកជន។

តារាងទី៣៨៖ សូចនាករ និងគោលដៅសម្រាប់ការអនុវត្តកម្មវិធី/គម្រោងទី៤.៧ នៃយុទ្ធសាស្ត្រទី៤

| **បរិយាយ** | **២០១៩** | **២០២០** | **២០២១** | **២០២២** | **២០២៣** | **២០២៤** | **២០២៥** | **២០២៦** | **២០២៧** | **២០២៨** | **២០២៩** | **២០៣០** | **សរុប** |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| កម្មវិធី/គម្រោង | ការគាំទ្រសមាគមអភិវឌ្ឍន៍កៅស៊ូកម្ពុជា | | | | | | | | | | | | |
| សូចនាករ | ១. ចំនួនប្រជុំ (លើក)<br>២. ចំនួនសិក្ខាកាម (នាក់) | | | | | | | | | | | | |










| បរិយាយ | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ | ២០២៤ | ២០២៥ | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ | សរុប |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ចំណុចដៅ១ | | | | | ២ | ២ | ២ | ២ | | | | | ៨ |
| ចំណុចដៅ២ | | | | | ១៥០ | ១៥០ | ១៥០ | ១៥០ | | | | | ៦០០ |
| ថវិកា (លានរៀល) | | | | | ១៦៨ | ១៦៨ | ១៦៨ | ១៦៨ | | | | | ៦៧៣ |

ដើម្បីសម្រេចបាននូវគោលបំណងខាងលើ សកម្មភាពមួយចំនួនត្រូវបានដាក់ឱ្យអនុវត្ត ដូចខាងក្រោម៖

- ការពង្រឹងតួនាទី ភារកិច្ចរបស់សមាគមអភិវឌ្ឍន៍កៅស៊ូកម្ពុជា
- ការរៀបចំសិក្ខាសាលាជំរុញការវិនិយោគកៅស៊ូ
- ការចូលរួមសម្របសម្រួលរៀបចំសន្និបាតរបស់សមាគម
- ការសម្របសម្រួលសមាគមបានចូលរួមកិច្ចប្រជុំ Rubber Dinner, ANRPC, IRRDB, ARBC, GRC, IRSG, …។

**៨. កម្មវិធី/គម្រោងទី៤.៨** ៖ ការអភិវឌ្ឍធនធានមនុស្សក្នុងអនុវិស័យកៅស៊ូ។

**គោលបំណង** ៖ បង្កើនសមត្ថភាព ចំណេះដឹង ជំនាញ ដល់មន្ត្រីរាជការ ធានាលើកកម្ពស់ប្រសិទ្ធភាពការងារ ជំរុញការអភិវឌ្ឍប្រទេសជាតិ។

តារាងទី៣៦៖ សូចនាករ និងគោលដៅសម្រាប់ការអនុវត្តកម្មវិធី/គម្រោងទី៤.៨ នៃយុទ្ធសាស្ត្រទី៤

| បរិយាយ | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ | ២០២៤ | ២០២៥ | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ | សរុប |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| កម្មវិធី/គម្រោង | ការអភិវឌ្ឍធនធានមនុស្សក្នុងវិស័យកៅស៊ូ | | | | | | | | | | | | |
| សូចនាករ | ១. ចំនួនសិក្ខាកាម (នាក់) | | | | | | | | | | | | |
| ចំណុចដៅ១ | - | - | ៨ | ៨ | ៨ | ៨ | ៨ | ៨ | ៨ | ៨ | ៨ | ៨ | ៨០ |
| ថវិកា(លានរៀល) | - | - | ១១៦ | ១១៦ | ១១៦ | ១១៦ | ១១៦ | ១១៦ | ១១៦ | ១១៦ | ១១៦ | ១១៦ | ១ ១៦៥ |










ដើម្បីសម្រេចបាននូវគោលបំណងខាងលើ សកម្មភាពមួយចំនួនត្រូវបានដាក់ឱ្យអនុវត្ត ដូចខាងក្រោម៖

- ការអភិវឌ្ឍធនធានមនុស្សក្នុងអនុវិស័យកៅស៊ូ។

**៩. កម្មវិធី/គម្រោងទី៤.៩** ៖ការសិក្សាទីតាំងបង្កើតទីក្រុងកៅស៊ូ

**គោលបំណង** ៖កំណត់ទីតាំងដែលមានសក្តានុពលអាចទាក់ទាញវិនិយោគគិន ដែលមានបំណងបង្កើតរោងចក្រឧស្សាហកម្មកម្មន្តសាលផលិតផលិតផលសម្រេចពីកៅស៊ូ សំដៅជំរុញការប្រើប្រាស់ផលិតផលកៅស៊ូក្នុងស្រុកនិងបង្កើនប្រាក់ចំណូលដល់អ្នកពាក់ព័ន្ធក្នុងអនុវិស័យកៅស៊ូ។

តារាងទី៣៧៖ សូចនាករ និងគោលដៅសម្រាប់ការអនុវត្តកម្មវិធី/គម្រោងទី៤.៩ នៃយុទ្ធសាស្ត្រទី៤

| បរិយាយ | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ | ២០២៤ | ២០២៥ | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ | សរុប |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| កម្មវិធី/គម្រោង | ការសិក្សាទីតាំងបង្កើតទីក្រុងកៅស៊ូ | | | | | | | | | | | | |
| សូចនាករ | ១. ចំនួនសិក្ខាកាម (នាក់)<br>២. ចំនួនចុះ (លើក) | | | | | | | | | | | | |
| ចំណុចដៅ១ | | | | | | | ១៥០ | | | | | | ១៥០ |
| ចំណុចដៅ២ | | | | | | ៣ | ៣ | | | | | | ៦ |
| ថវិកា (លានរៀល) | | | | | | ១៣ | ៤២ | | | | | | ៥៦ |

ដើម្បីសម្រេចបាននូវគោលបំណងខាងលើ សកម្មភាពមួយចំនួនត្រូវបានដាក់ឱ្យអនុវត្ត ដូចខាងក្រោម៖

- ការសិក្សានិងកំណត់ទីតាំងបង្កើតទីក្រុងកៅស៊ូ
- ការផ្សព្វផ្សាយទីក្រុងកៅស៊ូ។







# ៦. រចនាសម្ព័ន្ធនៃការអនុវត្ត ការតាមដានត្រួតពិនិត្យ និងការវាយតម្លៃ ផែនការយុទ្ធសាស្ត្រ

## ៦.១ រចនាសម្ព័ន្ធនៃការអនុវត្ត

| ១១ | **ផលប៉ះពាល់បរិស្ថាន៖**<br>- មិនមានផលប៉ះពាល់បរិស្ថាន<br>- ជួយរក្សាស្ថិរភាពដល់បរិស្ថានផងដែរ។ |
| ១២ | **ផលប៉ះពាល់សង្គម៖**<br>- មិនមានផលប៉ះពាល់សង្គម<br>- ផលិតករកៅស៊ូទទួលបាននូវតម្លៃសមស្រប និងមានផលចំណូលកើនឡើង ដែលនឹងរួម ចំណែកនៅក្នុងការអភិវឌ្ឍសេដ្ឋកិច្ចសង្គម។ |

**យុទ្ធសាស្ត្រទី២៖ ការលើកកម្ពស់ការងារពិសោធនិងការស្រាវជ្រាវកៅស៊ូ**

**២.៣ កម្មវិធី/គម្រោង៖ ការពង្រឹងយន្តការទ្រទ្រង់ដល់ការស្រាវជ្រាវដំណាំកៅស៊ូ និងកែលម្អគុណភាពហេដ្ឋារចនាសម្ព័ន្ធរូបវន្ត**

| **លរ** | **បរិយាយ** | **លេខកូដ**<br>Pj2.3 |
|---|---|---|
| ១ | **គោលបំណង៖** អភិបាលកិច្ចល្អក្នុងការងារពិសោធន៍ស្រាវជ្រាវការធ្វើសមាហរណកម្មវិស័យស្រាវជ្រាវ ជាមួយនិងអន្តរជាតិ ការផ្ទេរបច្ចេកវិទ្យានិងបណ្តុះបណ្តាលធនធានមនុស្ស ការកែលម្អហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ការទ្រទ្រង់ សុខមាលភាពនិងសុវត្ថិភាពពលកម្មសំដៅបង្កើនប្រសិទ្ធិភាពស្រាវជ្រាវ ដើម្បីរួមចំណែកនិងជំរុញការអភិវឌ្ឍដំណាំកៅស៊ូប្រកបដោយប្រសិទ្ធភាពនិងចីរភាព។ | |
| ២ | **សនិទានភាព៖** ការស្រាវជ្រាវរបស់ វ.ស.ក.ក. នៅតែជួបនឹងឧបសគ្គជាច្រើនដោយសារកំណើននៃការងារស្រាវជ្រាវ ផ្ទុយទៅវិញ ផ្នែកទ្រទ្រង់មានកង្វះខាតដូចជា៖ កង្វះធនធានមនុស្ស ហិរញ្ញវត្ថុ និងហេដ្ឋារចនាសម្ព័ន្ធ...។ល។ រំហូរចេញនូវធនធានមនុស្សពី វ.ស.ក.ក. ដោយមន្ត្រីចាស់ៗបានចូលនិវត្តន៍ និងមួយចំនួនទៀតបានផ្លាស់ប្តូរទីកន្លែង ការងារដោយសារការប្តូរទីតាំងរបស់ វ.ស.ក.ក.។ រីឯហេដ្ឋារចនាសម្ព័ន្ធសម្រាប់បម្រើឲ្យការស្រាវជ្រាវនៅស្ថានីយ៍ពិសោធន៍ដូចជា៖ អគារមន្ទីរពិសោធន៍ ផ្ទះស្នាក់នៅរបស់មន្ត្រីស្រាវជ្រាវ និងផ្ទះនិយោជិតក្នុងភូមិ៣២ អគារនិងផ្ទះ គឺជាសំណង់ចាស់ដែលមានសភាពទ្រុឌទ្រោម។ ចំណែកឯផ្លូវថ្នល់វិញមានការខូចខាតច្រើនអន្លើទាំងក្នុងបរិវេណ ស្ថានីយ៍ទាំងក្នុងចំការពិសោធន៍ដែលបណ្តាលឲ្យមានការលំបាកនៅក្នុងប្រតិបត្តិការស្រង់ទិន្នន័យពិសោធន៍និងការដឹក ផលពីចម្ការពិសោធន៍យកទៅកែច្នៃនៅក្នុងបរិវេណស្ថានីយ៍។ កត្តាមួយចំនួនសម្រាប់យន្តការគាំទ្រដល់ការស្រាវជ្រាវ មានកំណត់ រួមមាន៖ ការទ្រទ្រង់ថវិកាមធ្យោបាយ សម្ភារៈឧបករណ៍ពិសោធន៍ ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ការកសាងធនធានមនុស្ស និងកិច្ចសហការជាមួយដៃគូ។ល។ ក្នុងបរិបទនេះ កត្តាចម្បងដែលចាំបាច់ត្រូវដោះស្រាយឲ្យបានទាន់ពេលវេលាគឺ៖ ការខិតខំដោះស្រាយថវិកាឲ្យបានទាន់ពេលវេលាការជួសជុលនិង កែលម្អហេដ្ឋារចនាសម្ព័ន្ធដែលទ្រុឌទ្រោមខូចខាតខ្លាំងដើម្បីផ្តល់សេចក្តីសុខនិងសុវត្ថិភាពដល់ការរស់នៅរបស់កម្មករ និងនិយោជិតហើយនិងការជួសជុសមន្ទីរពិសោធន៍ និងបំពាក់បន្ថែមនូវឧបករណ៍សម្ភារៈដែលខ្វះខាត។ ការផ្តល់បន្ថែមនូវធនធានមនុស្សក្នុងការបំពេញចន្លោះប្រហោង ដោយការចូលនិវត្តន៍និងការផ្ទេរចេញរបស់មន្ត្រីស្រាវជ្រាវ ហើយនិងតម្រូវការសម្រាប់ដាក់ឲ្យដំណើរការមន្ទីរពិសោធន៍ ក្សេត្រសាស្ត្រផ្នែកវិភាគដី វិភាគជំងឺ និងវិភាគស្លឹកកៅស៊ូរួមនិងជំនាញផ្សេងទៀតដែលនឹងត្រូវអភិវឌ្ឍនៅពេល ខាងមុខ។ | |
| ៣ | **ការពិពណ៌នា៖** ដើម្បីសម្រេចបានគោលបំណងខាងលើ សកម្មភាពចំនួន ៤ត្រូវបានលើកឡើង រួមមាន៖ (១) ការកែលម្អហេដ្ឋារចនាសម្ព័ន្ធរូបវន្ត (២) ការបណ្តុះបណ្តាលធនធានមនុស្សនិងផ្ទេរបច្ចេកវិទ្យា (៣) ការចូលរួមដៃគូស្រាវជ្រាវជាមួយភាគីអន្តរជាតិ និង (៤) ការងារគ្រប់គ្រងរដ្ឋបាល។ | |
| ៤ | **លទ្ធផលក្នុងឆ្នាំ និងពេលវេលា៖**<br>គម្រោងនេះអនុវត្តចាប់ពីឆ្នាំ២០១៩ ដល់ឆ្នាំ២០៣០ដែលមានលទ្ធផលក្នុងឆ្នាំ៖<br>- ទីជម្រកកម្មករនិយោជិតក្នុងរង្វង់២៥ផ្ទះ/ឆ្នាំ ត្រូវបានជួសជុល<br>- ផ្លូវក្នុងបរិវេណស្នាក់ការស្ថានីយអនុវត្តប្រវែងប្រមាណ ៥គ.ម ត្រូវបានជួសជុលថែទាំ<br>- មន្ត្រីនិងជនបង្គោលចំនួនពី៣៥ ទៅ៧៥នាក់ ត្រូវបានបណ្តុះបណ្តាល<br>- ការអនុវត្តគម្រោងមានរយៈពេល ១២ឆ្នាំ។ | |

| | |
|---|---|
| ៥ | **មុំនៃគោលនយោបាយក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ដែលគម្រោងស្ថិតនៅ៖**<br>៤.១ ការលើកស្ទួយវិស័យកសិកម្មនិងការអភិវឌ្ឍជនបទ។ |
| ៦ | **លទ្ធផលចុងក្រោយ៖**<br>- ធនធានមនុស្សមានគ្រប់គ្រាន់ឆ្លើយតបទៅតាមតម្រូវការនៃការពិសោធន៍ស្រាវជ្រាវ<br>- ហេដ្ឋារចនាសម្ព័ន្ធរូបវន្តត្រូវបានកែលម្អកម្មកររស់នៅប្រកបដោយភាពសុខដុមរមនា បរិយាកាសការងារមានអំណោយផល ការស្រាវជ្រាវនិងពិសោធន៍ត្រូវបានពង្រឹងនិងលើកកម្ពស់ ព្រមទាំងទទួលបានលទ្ធផលល្អ<br>- ប្រតិបត្តិករកៅស៊ូទទួលបាននូវទំនុកចិត្ត ញ៉ាំងឲ្យការផ្ទេរបច្ចេកវិទ្យានិងការបម្រើសេវារបស់វសកក ដល់ប្រតិបត្តិករកៅស៊ូកម្ពុជាកាន់តែមានប្រសិទ្ធភាពនិងប្រសិទ្ធផល ដែលនឹងញ៉ាំងឲ្យការអភិវឌ្ឍដំណាំកៅស៊ូកាន់តែមានការរីកចម្រើន។ |
| ៧ | **ថវិកាចំណាយ៖** តម្លៃសរុបប្រមាណ **២៦ ៧៣៥**លានរៀល ស្មើនឹងប្រមាណ **៦,៥**លានដុល្លារអាម៉េរិក។ |
| ៨ | **ប្រភពថវិកា៖** ថវិកាជាតិ។ |
| ៩ | **អង្គភាពអនុវត្ត៖** វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា។ |
| ១០ | **អ្នកទទួលផល៖** អ្នកពាក់ព័ន្ធនឹងអនុវិស័យកៅស៊ូ។ |
| ១១ | **ផលប៉ះពាល់បរិស្ថាន៖** រក្សាស្ថិរភាពដល់បរិស្ថាន។ |
| ១២ | **ផលប៉ះពាល់សង្គម៖**<br>- មិនមានផលប៉ះពាល់ដល់សង្គម<br>- រួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ចសង្គម។ |

| យុទ្ធសាស្ត្រទី៣៖ ការពង្រឹងសេវាគាំទ្រនិងអង្គភាព | | |
|---|---|---|
| **កម្មវិធី/គម្រោងទី៣.១៖ ការរៀបចំ ការអនុវត្តផែនការ និងការគ្រប់គ្រងថវិកាកម្មវិធី** | | |
| **ល.រ** | **បរិយាយ** | **លេខកូដ** Pj3.1 |
| ១ | **គោលបំណង៖** បង្កើនប្រសិទ្ធភាពនិងភាពស័ក្តិសិទ្ធ នៃការរៀបចំនិងការអនុវត្តថវិកាកម្មវិធី | |
| ២ | **សនិទានភាព៖** ថវិកាកម្មវិធី គឺជាផ្នែកដ៏សំខាន់មួយនៃកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលជា ការរៀបចំថវិកាដោយផ្អែកលើកម្មវិធីច្បាស់លាស់នូវធាតុចូលជាចំណាយចរន្ត និងចំណាយមូលធន សម្រាប់អនុវត្តសកម្មភាព ដើម្បីឆ្លើយតបទៅនឹងគោលនយោបាយរបស់ក្រសួង និងត្រូវមានសូចនាករសមិទ្ធិកម្មសម្រាប់យន្តការតាមដាន ត្រួតពិនិត្យ វាយតម្លៃ វាស់វែង ធ្វើរបាយការណ៍លទ្ធផលក្នុងឆ្នាំ និងលទ្ធផលចុងក្រោយទៅតាមកម្មវិធីនីមួយៗ។ អគ្គនាយកដ្ឋានកៅស៊ូ បានចាប់ផ្តើមអនុវត្តថវិកាកម្មវិធីសាកល្បងនៅឆ្នាំ២០១០។ លុះដល់ឆ្នាំ២០១៤ ទើបថវិកាកម្មវិធីពេញលេញត្រូវបានដាក់ឱ្យអនុវត្តសាកល្បង ហើយអគ្គនាយកដ្ឋានកៅស៊ូក៏បានអនុវត្តចាប់តាំងពីឆ្នាំ២០១៥ រហូតមកដល់បច្ចុប្បន្ន។ ការអនុវត្តថវិកាកម្មវិធីកន្លងមកមានការខ្វះចន្លោះ មិនទាន់ទទួលបានប្រសិទ្ធភាពពេញលេញ ដោយសារសមត្ថភាពមន្ត្រីរៀបចំនិងអនុវត្តថវិកាកម្មវិធីនៅមានកម្រិត មិនទាន់ឆ្លើយតបបានទៅនឹងការណែនាំ នៃការរៀបចំថវិកាកម្មវិធី។ គម្រោងស្តីអំពី" ការរៀបចំ ការអនុវត្តផែនការ និងការគ្រប់គ្រងថវិកាកម្មវិធី "គឺជាការងារចាំបាច់ដើម្បីក្នុងការបង្កើនប្រសិទ្ធភាពនិងភាពស័ក្តសិទ្ធ នៃការរៀបចំនិងការអនុវត្តថវិកាកម្មវិធី។ | |
| ៣ | **ការពិពណ៌នា៖** ដើម្បីសម្រេចបានគោលបំណងខាងលើ សកម្មភាពចំនួន ៣ត្រូវបានលើកឡើងរួមមាន៖ (១) ការរៀបចំនិងការអនុវត្តថវិកាកម្មវិធី (២) ការរៀបចំកិច្ចប្រជុំប្រចាំឆ្នាំលើការងារកៅស៊ូធម្មជាតិ និង (៣) ការគាំទ្រនិងសម្របសម្រួលអង្គភាព។ | |
| ៤ | **លទ្ធផលក្នុងឆ្នាំនិងពេលវេលា៖**<br>គម្រោងនេះអនុវត្តចាប់ពីឆ្នាំ២០១៩ ដល់ឆ្នាំ២០៣០ ដែលមានលទ្ធផលក្នុងឆ្នាំ៖<br>- សិក្ខាកាមចំនួន ៤០នាក់/ឆ្នាំ ទទួលបានការបណ្តុះបណ្តាលពីការរៀបចំនិងគ្រង់គ្រងថវិកាកម្មវិធី<br>- ចំនួនចុះតាមដាននិងវាយតម្លៃការអនុវត្តចង្កោមសកម្មភាពថវិកាកម្មវិធីពី ៨-១៣ដង/ឆ្នាំ<br>- ចំនួនសិក្ខាកាមចូលរួមកិច្ចប្រជុំប្រចាំឆ្នាំលើការងារកៅស៊ូធម្មជាតិពី ២០០-៥៧០នាក់/ឆ្នាំ<br>- អត្រានៃថវិកាដែលបានអនុវត្ត ៩៥-៩៦%ឆ្នាំ<br>- ការអនុវត្តគម្រោងមានរយៈពេល ១២ឆ្នាំ។ | |
| ៥ | **មុំនៃគោលនយោបាយក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ដែលគម្រោងស្ថិតនៅ៖**<br>៤.១ ការលើកស្ទួយវិស័យកសិកម្មនិងការអភិវឌ្ឍជនបទ។ | |
| ៦ | **លទ្ធផលចុងក្រោយ៖**<br>- អត្រាថវិកាដែលបានអនុវត្ត ៩៦%ធៀបនឹងផែនការ។ | |
| ៧ | **ថវិកាចំណាយ៖** តម្លៃសរុបប្រមាណ ៥៧ ២១៩លានរៀល ស្មើនឹងប្រមាណ ១៤,៣១លានដុល្លារអាម៉េរិក។ | |
| ៨ | **ប្រភពថវិកា៖** ថវិកាជាតិ។ | |
| ៩ | **អង្គភាពអនុវត្ត៖** អគ្គនាយកដ្ឋានកៅស៊ូ (នាយកដ្ឋានផែនការ ហិរញ្ញវត្ថុ និងស្ថិតិ)។ | |
| ១០ | **អ្នកទទួលផល៖** មន្ត្រីនិងប្រតិបត្តិករកៅស៊ូ។ | |

| | |
|---|---|
| ១១ | **ផលប៉ះពាល់បរិស្ថានៈ**<br>- គ្មានផលប៉ះពាល់បរិស្ថាន។ |
| ១២ | **ផលប៉ះពាល់សង្គមៈ**<br>- គ្មានផលប៉ះពាល់សង្គម<br>- ជួយកសិករកៅស៊ូគ្រួសារក្នុងការបង្កើនគុណភាពចម្ការនិងទិន្នផលកៅស៊ូ<br>- ជំរុញបង្កើតសហគមន៍កសិកម្មកៅស៊ូគ្រួសារ ដើម្បីកាត់បន្ថយថ្លៃដើម និងទទួលតម្លៃបន្ថែម<br>- ផ្តល់បច្ចេកទេសកែច្នៃល្អដល់ម្ចាស់រោងចក្រ សិប្បកម្មក្នុងការបង្កើនគុណភាពកៅស៊ូ<br>- ផ្តល់ព័ត៌មានទីផ្សារដល់កសិករកៅស៊ូគ្រួសារ ដើម្បីមានមូលដ្ឋានក្នុងការចរចាតម្លៃ<br>- បង្កើនប្រាក់ចំណូលនិងបង្កើតការងារនៅជនបទ រួមចំណែកដល់ការកាត់បន្ថយភាពក្រីក្រ។ |

**យុទ្ធសាស្ត្រទី៣៖ ការពង្រឹងសេវាគាំទ្រនិងអង្គភាព**

**កម្មវិធី/គម្រោងទី៣.២៖ ការកសាង និងការអនុវត្តផែនការ គោលនយោបាយ អភិវឌ្ឍកៅស៊ូធម្មជាតិ**

| ល.រ | បរិយាយ | លេខកូដ |
|---|---|---|
| | | Pj3.2 |
| ១ | **គោលបំណង៖** ជំរុញការអភិវឌ្ឍកៅស៊ូធម្មជាតិប្រកបដោយនិរន្តរភាព។ | |
| ២ | **សនិទានភាព៖** កៅស៊ូធម្មជាតិ គឺជាដំណាំយុទ្ធសាស្ត្រមួយប្រភេទ ដែលផ្តល់ប្រយោជន៍ជាច្រើនដល់អ្នកដាំ ដល់សេដ្ឋកិច្ចជាតិ ដល់សង្គមទាំងមូល និងបរិស្ថាន។ ផ្ទៃដីដំណាំកៅស៊ូនៅកម្ពុជាមាននិន្នាការរីកចម្រើនគួរឱ្យកត់សម្គាល់ ពោលគឺមានចំនួន១៨១.៤៣៣ហិកតានៅឆ្នាំ២០១០ បានកើនឡើងដល់ចំនួន៤០៥.៦៧១ហិកតានៅឆ្នាំ២០១៩ ស្មើនឹងអត្រាកំណើនសមាសប្រចាំឆ្នាំ៨,៤%។ កត្តានេះបណ្តាលឱ្យផែនការយុទ្ធសាស្ត្រសម្រាប់ការអភិវឌ្ឍកៅស៊ូធម្មជាតិនៅកម្ពុជា ២០១១-២០២០ ដែលបានដាក់ចេញកាលពីឆ្នាំ២០១១ មិនសមស្របទៅនឹងការវិវត្តជាក់ស្តែងនៃស្ថានភាពកៅស៊ូបច្ចុប្បន្ន ក៏ដូចជាគោលដៅនៃយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ២០១៩-២០២៣ ដែលរាជរដ្ឋាភិបាលបានដាក់ចេញ។ ដូច្នេះ គម្រោងស្តីពី "ការកសាង និងការអនុវត្តផែនការ គោលនយោបាយ អភិវឌ្ឍកៅស៊ូធម្មជាតិ" គឺជាកិច្ចការសំខាន់ដែលត្រូវយកចិត្តទុកដាក់សំដៅលើកកម្ពស់សក្តានុពលដំណាំកៅស៊ូនៅកម្ពុជា ទាំងបរិមាណនិងគុណភាព (តាមរយៈការដាំដុះកៅស៊ូប្រកបដោយទិន្នផលខ្ពស់ ដោយផ្តល់អាទិភាពដល់ចម្ការកៅស៊ូគ្រួសារ) ជំរុញការអភិឌ្ឍខ្សែច្រវាក់តម្លៃឱ្យបានល្អប្រសើរ និងប្រកបដោយនិរន្តរភាព ដើម្បីបង្កើនប្រាក់ចំណូលនិងបង្កើតការងារនៅជនបទ រួមចំណែកដល់ការកាត់បន្ថយភាពក្រីក្រនិងការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយនិរន្តរភាព។ | |
| ៣ | **ការពិពណ៌នា៖** ដើម្បីសម្រេចបានគោលបំណងខាងលើ សកម្មភាពចំនួន ២ត្រូវបានលើកឡើងរួមមាន៖ (១) ការរៀបចំនិងតាមដានការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍កៅស៊ូធម្មជាតិ និង (២) ការរៀបចំនិងតាមដានការអនុវត្តគោលនយោបាយសម្រាប់អនុវិស័យកៅស៊ូ។ | |
| ៤ | **លទ្ធផលក្នុងឆ្នាំនិងពេលវេលា៖**<br>គម្រោងនេះអនុវត្តចាប់ពីឆ្នាំ២០១៩ ដល់ឆ្នាំ២០៣០៖<br>- កិច្ចប្រជុំរៀបចំផែនការយុទ្ធសាស្ត្រនិងគោលនយោបាយចំនួនពី ១០-២០ដង/ឆ្នាំ<br>- ការប្រជុំពិនិត្យវឌ្ឍនភាពនៃការអនុវត្តផែនការយុទ្ធសាស្ត្រនិងគោលនយោបាយចំនួនពី ៥-៧ដង/ឆ្នាំ<br>- ការចុះតាមដានការអនុវត្តផែនការយុទ្ធសាស្ត្រនិងគោលនយោបាយចំនួនពី ៤-១២ដង/ឆ្នាំ<br>- ការអនុវត្តគម្រោងមានរយៈពេល ១២ឆ្នាំ។ | |
| ៥ | **មុំនៃគោលនយោបាយក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ដែលគម្រោងស្ថិតនៅ៖**<br>៤.១ ការលើកស្ទួយវិស័យកសិកម្មនិងការអភិវឌ្ឍជនបទ។ | |
| ៦ | **លទ្ធផលចុងក្រោយ៖**<br>- អត្រានៃការអនុវត្តសកម្មភាពរបស់ផែនការយុទ្ធសាស្ត្របាន ៨៥%ធៀបនឹងផែនការ នៅឆ្នាំ២០៣០។ | |
| ៧ | **ថវិកាចំណាយ៖** តម្លៃសរុបប្រមាណ ១ ៥៦៦លានរៀល ស្មើនឹងប្រមាណ ០,៤០លានដុល្លារអាម៉េរិក។ | |
| ៨ | **ប្រភពថវិកា៖** ថវិកាជាតិ។ | |
| ៩ | **អង្គភាពអនុវត្ត៖** អគ្គនាយកដ្ឋានកៅស៊ូ (នាយកដ្ឋានផែនការ ហិរញ្ញវត្ថុ និងស្ថិតិ)។ | |
| ១០ | **អ្នកទទួលផល៖** ប្រតិបត្តិករកៅស៊ូ។ | |

| | |
|---|---|
| ១១ | **ផលប៉ះពាល់បរិស្ថាន៖**<br>- គ្មានផលប៉ះពាល់បរិស្ថាន<br>- ជួយជំនួសព្រៃធម្មជាតិដែលបាត់បង់ និងរក្សាលំនឹងបរិស្ថាន តាមរយៈការដាំដុះកៅស៊ូតាមផែនការវិនិយោគ និងបទដ្ឋានបច្ចេកទេសត្រឹមត្រូវ<br>- ការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយចីរភាព។ |
| ១២ | **ផលប៉ះពាល់សង្គម៖**<br>- គ្មានផលប៉ះពាល់សង្គម<br>- ជួយកសិករកៅស៊ូគ្រួសារក្នុងការបង្កើនគុណភាពចម្ការនិងទិន្នផលកៅស៊ូ<br>- ជំរុញបង្កើតសហគមន៍កសិកម្មកៅស៊ូគ្រួសារ ដើម្បីកាត់បន្ថយថ្លៃដើម និងទទួលតម្លៃបន្ថែម<br>- ផ្តល់បច្ចេកទេសកែច្នៃល្អដល់ម្ចាស់រោងចក្រ សិប្បកម្មក្នុងការបង្កើនគុណភាពកៅស៊ូ<br>- ផ្តល់ព័ត៌មានទីផ្សារដល់កសិករកៅស៊ូគ្រួសារ ដើម្បីមានមូលដ្ឋានក្នុងការចរចាតម្លៃ<br>- បង្កើនប្រាក់ចំណូលនិងបង្កើតការងារនៅជនបទ រួមចំណែកដល់ការកាត់បន្ថយភាពក្រីក្រ។ |

| យុទ្ធសាស្ត្រទី៣៖ ការពង្រឹងសេវាគាំទ្រនិងអង្គភាព | | |
|---|---|---|
| **កម្មវិធី/គម្រោងទី៣.៣៖ ការពង្រឹងប្រព័ន្ធព័ត៌មានស្ថិតិកៅស៊ូធម្មជាតិ** | | |
| **ល.រ** | **បរិយាយ** | **លេខកូដ** Pj3.3 |
| ១ | **គោលបំណង៖** ទទួលបានទិន្នន័យកៅស៊ូគ្រប់គ្រាន់និងជាក់លាក់ ស្របតាមវិធីសាស្ត្រស្ថិតិវិទ្យា សម្រាប់ជាធាតុចូលក្នុងការរៀបចំផែនការយុទ្ធសាស្ត្រនិងគោលនយោបាយអភិវឌ្ឍន៍កៅស៊ូធម្មជាតិ។ | |
| ២ | **សនិទានភាព៖** ដំណាំកៅស៊ូត្រូវបានយកមកដាំនៅប្រទេសកម្ពុជាជាលើកដំបូងនាឆ្នាំ១៩១០ លើផ្ទៃដីចំនួន១៥០ហិកតា ក្នុងស្រុកព្រៃនប់ ខេត្តកំពត(បច្ចុប្បន្នខេត្តព្រះសីហនុ) និងមានការវិវត្តរីកចម្រើនជាបន្តបន្ទាប់ រហូតមកដល់ឆ្នាំ២០១៩ ផ្ទៃដីកៅស៊ូកម្ពុជាមានចំនួន ៤០៥ ៦៧១ហិកតា ដាំដុះលើតំបន់ដីប្រពៃណីនិងតំបន់ដីមិនមែនប្រពៃណី ដែលរាយប៉ាយលើខេត្តចំនួន២០ដោយកសិករគ្រួសារតូចតាច រហូតដល់ក្រុមហ៊ុនធំៗ។ តាមការព្យាកររបស់អគ្គ-នាយកដ្ឋានកៅស៊ូផ្ទៃដីកៅស៊ូនៅកម្ពុជានឹងបន្តកើនឡើងរហូតដល់ ៤៣៣ពាន់ហិកតា នៅឆ្នាំ២០២៥ ដោយសារភាពល្អប្រសើរនៃតម្លៃកៅស៊ូនៅលើពិភពលោក ប្រទេសកម្ពុជាមានសុខសន្តិភាពនិងស្ថេរភាពនយោបាយពេញលេញ និងដីមានសក្តានុពលកបនឹងដំណាំកៅស៊ូ។ល។ ស្របពេលនឹងការរីកចម្រើនយ៉ាងឆាប់រហ័សនៃអនុវិស័យកៅស៊ូ ការប្រមូលទិន្នន័យកៅស៊ូអំពី ការដាំដុះ ការយកផល ការកែច្នៃ និងការនាំចេញផលិតផលកៅស៊ូ មិនទាន់បានពេញលេញ ដែលជាបញ្ហាប្រឈមដល់ការរៀបចំផែនការនិងគោលនយោបាយអភិវឌ្ឍន៍កៅស៊ូ។ ដូច្នេះ គម្រោង "ការពង្រឹងប្រព័ន្ធព័ត៌មានស្ថិតិកៅស៊ូធម្មជាតិ" គឺជាការងារចាំបាច់និងបន្ទាន់ដែលត្រូវយកចិត្តទុកដាក់ ដើម្បីទទួលបានទិន្នន័យកៅស៊ូគ្រប់គ្រាន់និងជាក់លាក់ ស្របតាមវិធីសាស្ត្រស្ថិតិវិទ្យា សម្រាប់ជាធាតុចូលក្នុងការរៀបចំផែនការអភិវឌ្ឍន៍កៅស៊ូធម្មជាតិនិងផ្តល់ជារបាយការណ៍ជាក់លាក់ដល់ស្ថាប័នអន្តរជាតិ។ | |
| ៣ | **ការពិពណ៌នា៖** ដើម្បីសម្រេចបានគោលបំណងខាងលើ សកម្មភាពចំនួន ៣ត្រូវបានលើកឡើងរួមមាន៖ (១) ការរៀបចំបង្កើតប្រព័ន្ធព័ត៌មានស្ថិតិកៅស៊ូ (២) ការតាមដាននិងវាយតម្លៃការអនុវត្តកម្មវិធីវិនិយោគសម្បទានដីសេដ្ឋកិច្ចលើដំណាំកៅស៊ូ និង (៣) ការចុះពិនិត្យនិងការវាយតម្លៃស្នាក់ការប្រមូលទិញជ័រកៅស៊ូគ្រួសារ។ | |
| ៤ | **លទ្ធផលក្នុងឆ្នាំនិងពេលវេលា៖**<br>គម្រោងនេះអនុវត្តចាប់ពីឆ្នាំ២០១៩ ដល់ឆ្នាំ២០៣០៖<br>- មន្ត្រីបង្គោលចំនួន ៥០នាក់/ឆ្នាំ ទទួលបានការបណ្តុះបណ្តាលស្តីពីការរៀបចំប្រព័ន្ធព័ត៌មាន<br>- ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចត្រូវបានចុះពិនិត្យនិងវាយតម្លៃផែនការវិនិយោគចំនួនពី ៩ - ១០លើក/ឆ្នាំ<br>- ស្នាក់ការប្រមូលទិញជ័រកៅស៊ូគ្រួសារចំនួនពី ២-៣ត្រូវបានបង្កើត<br>- ការអនុវត្តគម្រោងមានរយៈពេល ១២ឆ្នាំ។ | |
| ៥ | **មុំនៃគោលនយោបាយក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ដែលគម្រោងស្ថិតនៅ៖**<br>៤.១ ការលើកស្ទួយវិស័យកសិកម្មនិងការអភិវឌ្ឍជនបទ។ | |
| ៦ | **លទ្ធផលចុងក្រោយ៖**<br>- ប្រព័ន្ធគ្រប់គ្រងព័ត៌មានស្ថិតិចំនួន ០១ត្រូវបានបង្កើត<br>- ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចចំនួន ៦០%អនុវត្តតាមកម្មវិធីវិនិយោគនិងលក្ខណៈបច្ចេកទេស។ | |
| ៧ | **ថវិកាចំណាយ៖** តម្លៃសរុបប្រមាណ ១ ៧៧៤លានរៀល ស្មើនឹងប្រមាណ 0,៤៤លានដុល្លារអាម៉េរិក។ | |
| ៨ | **ប្រភពថវិកា៖** ថវិកាជាតិ។ | |
| ៩ | **អង្គភាពអនុវត្ត៖** អគ្គនាយកដ្ឋាកៅស៊ូ (នាយកដ្ឋានផែនការ ហិរញ្ញវត្ថុ និងស្ថិតិ)។ | |

| | |
|---|---|
| ១០ | **អ្នកទទួលផល៖** ប្រតិបត្តិករកៅស៊ូ។ |
| ១១ | **ផលប៉ះពាល់បរិស្ថាន៖**<br>- គ្មានផលប៉ះពាល់បរិស្ថាន<br>- ជួយជំនួសព្រៃធម្មជាតិដែលបាត់បង់ និងរក្សាលំនឹងបរិស្ថាន តាមរយៈការដាំដុះកៅស៊ូតាមផែនការវិនិយោគ និងបទដ្ឋានបច្ចេកទេសត្រឹមត្រូវ។ |
| ១២ | **ផលប៉ះពាល់សង្គម៖**<br>- គ្មានផលប៉ះពាល់សង្គម<br>- បង្កើតមុខរបរ តាមរយៈការប្រមូលទិញកៅស៊ូក្នុងស្រុក<br>- បង្កើនប្រាក់ចំណូលនិងបង្កើតការងារនៅជនបទ រួមចំណែកដល់ការកាត់បន្ថយភាពក្រីក្រ<br>- ប្រាក់ចំណូលរដ្ឋតាមរយៈថ្លៃឈ្នួលដី។ |

| យុទ្ធសាស្ត្រទី៣៖ ការពង្រឹងសេវាគាំទ្រនិងអង្គភាព | | |
|---|---|---|
| **កម្មវិធី/គម្រោងទី៣.៤៖ ការកសាងនិងការពង្រឹងលិខិតុបករណ៍គតិយុត្ត និងអភិវឌ្ឍន៍ធនធានមនុស្ស** | | |
| **ល.រ** | **បរិយាយ** | **លេខកូដ**<br>Pj3.4 |
| ១ | **គោលបំណង៖** លើកកម្ពស់និងពង្រឹងការអនុវត្តលិខិតគតិយុត្ត និងអភិវឌ្ឍធនធានមនុស្ស សំដៅគ្រប់គ្រងអនុវិស័យកៅស៊ូប្រកបដោយប្រសិទ្ធភាពនិងនិរន្តរភាព។ | |
| ២ | **សនិទានភាព៖** ចាប់តាំងពីឆ្នាំ១៩១០ ដែលជាកាលបរិច្ឆេទនៃការដាំដុះកៅស៊ូលើកដំបូងរហូតមកដល់ បច្ចុប្បន្ននេះ អនុវិស័យកៅស៊ូនៅកម្ពុជាមានសន្ទុះឆ្ពោះទៅរកការអភិវឌ្ឍមួយប្រកបដោយថាមភាពនៅក្នុងការដាំដុះនិងប្រមូលផល។ ទន្ទឹមនឹងការរីកចម្រើននេះ ការគ្រប់គ្រងអនុវិស័យកៅស៊ូមានបញ្ហាមួយចំនួន ដូចជាការចូលរួមសហការពីអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធគ្រប់លំដាប់ថ្នាក់ក្នុងការត្រួតពិនិត្យ និងទប់ស្កាត់បទល្មើសផ្សេងៗក្នុងអនុវិស័យកៅស៊ូមិនទាន់បានល្អនៅឡើយ ដែលត្រូវពង្រឹងបន្ថែមឱ្យសមស្របទៅតាមស្ថានភាពរីកចម្រើននៅពេលបច្ចុប្បន្ននិងទៅអនាគត ។ ទាំងអស់នេះ អាចមកពីលិខិតគតិយុត្តនិងធនធានមនុស្សផ្នែកអនុវិស័យហ្នឹងនៅមានកម្រិត ដែលចាំបាច់តម្រូវឱ្យមានច្បាប់គ្រប់គ្រងមួយជាក់លាក់ លិខិតគតិយុត្ត និងធនធានមនុស្សជាច្រើនបន្ថែមទៀត បើទោះជាបច្ចុប្បន្នមានលិខិតបទដ្ឋានគតិយុត្តខ្លះសម្រាប់គ្រប់គ្រងអនុវិស័យកៅស៊ូហើយក្តី ។ ទន្ទឹមនេះ ការបណ្តុះបណ្តាលធនធានមនុស្ស គឺជាកត្តាសំខាន់ដើម្បីពង្រឹងសមត្ថភាព បង្កើនចំណេះដឹងជំនាញដល់មន្ត្រីរាជការ ក្នុងការបំពេញការងារឱ្យស្របតាមការវិវត្តន៍ថ្មីៗនៃបច្ចេកវិទ្យា សំដៅឆ្ពោះទៅរកជោគជ័យរបស់អង្គភាព។ គម្រោងស្តីពី "ការកសាងនិងការពង្រឹងលិខិតុបករណ៍គតិយុត្ត និងអភិវឌ្ឍន៍ធនធានមនុស្ស" គឺជាការងារចាំបាច់ក្នុងការពង្រឹងការគ្រប់គ្រងអនុវិស័យកៅស៊ូនិងអភិវឌ្ឍធនធានមនុស្ស ប្រកបដោយប្រសិទ្ធភាពនិងចីរភាព។ | |
| ៣ | **ការពិពណ៌នា៖** ដើម្បីសម្រេចបានគោលបំណងខាងលើ សកម្មភាពចំនួន ០៣ត្រូវបានលើកឡើងរួមមាន៖ (១) ការកសាងលិខិតុបករណ៍គតិយុត្តពាក់ព័ន្ធអនុវិស័យកៅស៊ូ (២) ការផ្សព្វផ្សាយលិខិតុករណ៍គតិយុត្តពាក់ព័ន្ធនឹងអនុវិស័យកៅស៊ូ និង (៣) ការបណ្តុះបណ្តាលសមត្ថភាពជំនាញគ្រប់គ្រងដល់មន្ត្រីរាជការ។ | |
| ៤ | **លទ្ធផលក្នុងឆ្នាំ និង ពេលវេលា៖**<br>គម្រោងនេះអនុវត្តចាប់ពីឆ្នាំ២០១៩ ដល់ឆ្នាំ២០៣០ ដែលមានលទ្ធផលក្នុងឆ្នាំដូចខាងក្រោម៖<br>- ចំនួនសេចក្តីព្រាងលិខិតគតិយុត្តពី ០១-០៣/ឆ្នាំត្រូវបានរៀបចំ<br>- ចំនួនប្រតិបត្តិករកៅស៊ូពី ៤៥០-៥៥០នាក់/ឆ្នាំបានចូលរួមស្តាប់ការផ្សព្វផ្សាយពីលិខិតគតិយុត្ត<br>- ចំនួនមន្ត្រីរាជការពី ៤៥-១០០នាក់/ឆ្នាំបានទទួលការបណ្តុះបណ្តាលសមត្ថភាពជំនាញគ្រប់គ្រង<br>- ការអនុវត្តគម្រោងមានរយៈពេល ១២ឆ្នាំ។ | |
| ៥ | **មុំនៃគោលនយោបាយក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ដែលគម្រោងស្ថិតនៅ៖**<br>៤.១ ការលើកស្ទួយកសិកម្ម និងការអភិវឌ្ឍជនបទ។ | |
| ៦ | **លទ្ធផលចុងក្រោយ៖**<br>នៅឆ្នាំ២០៣០រំពឹងថា៖<br>- លិខិតបទដ្ឋានគតិយុត្តចំនួន ២៤ត្រូវបានអនុម័ត<br>- មន្ត្រីរាជការចំនួន៩៥% ទទួលបានចំណេះដឹងពីជំនាញគ្រប់គ្រង។ | |
| ៧ | **ថវិកាចំណាយ៖** តម្លៃសរុបប្រមាណ ២ ៥១៧លានរៀល ស្មើនឹងប្រមាណ ០,៦៣លានដុល្លារអាម៉េរិក។ | |

| | |
|---|---|
| ៨ | **ប្រភពថវិកា៖** ថវិកាជាតិ។ |
| ៩ | **អង្គភាពអនុវត្ត៖** អគ្គនាយកដ្ឋានកៅស៊ូ (នាយកដ្ឋានរដ្ឋបាល និងនីតិកម្ម)។ |
| ១០ | **អ្នកទទួលផល៖** ប្រតិបត្តិករកៅស៊ូនិងអ្នកពាក់ព័ន្ធ។ |
| ១១ | **ផលប៉ះពាល់ផ្នែកបរិស្ថាន៖**<br>- គ្មានផលប៉ះពាល់បរិស្ថាន។ |
| ១២ | **ផលប៉ះពាល់ផ្នែកសង្គម៖**<br>- គ្មានផលប៉ះពាល់សង្គម<br>- ការពារបាននូវផលប្រយោជន៍របស់ប្រតិបត្តិករកៅស៊ូ<br>- រួមចំណែកអភិវឌ្ឍន៍ធនធានមនុស្ស។ |

| យុទ្ធសាស្ត្រទី៤៖ ការជំរុញវិនិយោគនិងហិរញ្ញប្បទានតាមរយៈដៃគូក្នុងការអភិវឌ្ឍកៅស៊ូធម្មជាតិ | | |
|---|---|---|
| **កម្មវិធី/គម្រោងទី៤.១ ៖ ការសិក្សាសក្តានុពលទីតាំងដែលមានលក្ខណៈសម្បត្តិសមស្របនឹងដំណាំកៅស៊ូ** | | |
| **ល.រ** | **បរិយាយ** | **លេខកូដ**<br>Pj4.1 |
| ១ | **គោលបំណង** ៖ កំណត់ប្រភេទនិងជីជាតិដី តាមទីតាំងភូមិសាស្ត្រដែលមានលក្ខណៈសមស្របសម្រាប់ដំណាំកៅស៊ូ សំដៅផ្តល់អនុសាសន៍ក្នុងការដាំដុះនិងការប្រើប្រាស់ជីបានត្រឹមត្រូវ រួមចំណែកកាត់បន្ថយថ្លៃដើម និងបង្កើនប្រាក់ចំណូលដល់អ្នកដាំកៅស៊ូ។ | |
| ២ | **សនិទានភាព៖** ឆ្នាំ២០១៩ ផ្ទៃដីកៅស៊ូសរុបនៅកម្ពុជាបានគ្រប់ដណ្តប់លើ ២០ខេត្ត មានផ្ទៃដីជាង ៤០ម៉ឺនហិកតា លើតំបន់ប្រពៃណី និងតំបន់មិនប្រពៃណី (តំបន់មាត់សមុទ្រ តំបន់វាលទំនាប តំបន់ខ្ពង់រាប...) ដែលមានប្រភេទដីខុសៗគ្នាតាមទីតាំងភូមិសាស្ត្រ តំបន់ខ្លះជាប្រភេទដីក្រហម ប្រភេទដីខ្មៅ និងប្រភេទដីល្បាយខ្សាច់ជាដើម។ល។ ដំណាំកៅស៊ូត្រូវបានដាំដុះលូតលាស់លើប្រភេទដី ទាំងនោះ មានការលូតលាស់ខុសៗគ្នា និងផ្តល់ទិន្នផលក៏ខុសៗគ្នាដែរ។ ប្រភេទដីក្រហមជាប្រភេទដីដែលមានលក្ខណៈសមស្របបំផុតសម្រាប់ដំណាំកៅស៊ូនៅកម្ពុជា ព្រោះដីក្រហមសម្បូរសារធាតុចិញ្ចឹម មានទម្រង់ដីល្អ មានវន្ធដីគ្រប់គ្រាន់ និងមានសមត្ថភាពក្នុងការចាប់យកអ៊ីយ៉ុងបានច្រើន។ ប៉ុន្តែជីជាតិដីពីមួយឆ្នាំទៅមួយឆ្នាំ មានការថមថយដោយការស្រូបយកពីដំណាំកៅស៊ូ ការហូរច្រោះដី និងកត្តាផ្សេងៗជាច្រើនទៀត។ ដូច្នេះ ការដាក់ជីដល់ដំណាំកៅស៊ូ គឺមានសារៈសំខាន់ណាស់ ដើម្បីរក្សាតុល្យភាពជីជាតិដី និងបង្កើនផលិតភាពដំណាំកៅស៊ូ។ ការប្រើប្រាស់ជីរបស់កសិករកៅស៊ូគ្រួសារនៅកម្ពុជា មិនទាន់មានភាពត្រឹមត្រូវតាមតម្រូវការលក្ខណៈបច្ចេកទេសដាំដុះដោយផ្អែកទៅលើការវិភាគដីនៅឡើយ ដែលធ្វើឱ្យមានការខាតបង់ថវិកាទៅលើការប្រើប្រាស់ជី។ ដូច្នេះគម្រោង "ការសិក្សាសក្តានុពលទីតាំងដែលមានលក្ខណៈសម្បត្តិសមស្របនឹងដំណាំកៅស៊ូ" គឺជាការងារចាំបាច់ ក្នុងការសិក្សានិងវាយតម្លៃអំពីសក្តានុពលដី ដើម្បីកំណត់ទីតាំងភូមិសាស្ត្រ ប្រភេទដី និងជីជាតិរបស់ដី ក្នុងការជម្រុញអភិវឌ្ឍន៍ដំណាំកៅស៊ូនៅកម្ពុជាប្រកបដោយចីរភាព។ | |
| ៣ | **ការពិពណ៌នា៖** ដើម្បីសម្រេចបានគោលបំណងខាងលើ សកម្មភាពចំនួន ៣ត្រូវបានលើកឡើងរួមមាន៖ (១) ការសិក្សាភូមិសាស្ត្រនិងវិភាគសំណាកដី (២) ការរៀបចំដំណាំកៅស៊ូឌីជីថល និង (៣) ការផ្សព្វផ្សាយដំណាំកៅស៊ូឌីជីថល។ | |
| ៤ | **លទ្ធផលក្នុងឆ្នាំនិងពេលវេលា៖**<br>គម្រោងនេះចាប់អនុវត្តឆ្នាំ២០២៤ ដល់ឆ្នាំ២០២៧ ដែលមានលទ្ធផលក្នុងឆ្នាំ៖<br>- សំណាកដីចំនួន ៨០០សំណាកក្នុងមួយឆ្នាំត្រូវបានប្រមូលនិងវិភាគ<br>- ប្រព័ន្ធឌីជីថលដំណាំកៅស៊ូចំនួន ១ត្រូវបានបង្កើតឡើង<br>- សិក្ខាសាលាចំនួន ៤វគ្គត្រូវធ្វើការផ្សព្វផ្សាយអំពីដំណាំកៅស៊ូឌីជីថល<br>- ការអនុវត្តគម្រោងមានរយៈពេល ០៤ឆ្នាំ។ | |
| ៥ | **ទំនៃគោលនយោបាយក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ដែលគម្រោងស្ថិតនៅ៖**<br>៤.១ ការលើកស្ទួយវិស័យកសិកម្មនិងការអភិវឌ្ឍជនបទ។ | |
| ៦ | **លទ្ធផលចុងក្រោយ៖**<br>- តំបន់ទាំង ៤ត្រូវបានផ្តល់អនុសាសន៍អំពីការប្រើប្រាស់ជីទៅតាមប្រភេទដីសម្រាប់ដំណាំកៅស៊ូ។ | |
| ៧ | **ថវិកាចំណាយ៖** តម្លៃសរុបប្រមាណ ១ ២៤៤លានរៀល ស្មើនឹងប្រមាណ ០,៣១លានដុល្លារអាម៉េរិក។ | |
| ៨ | **ប្រភពថវិកា៖** ថវិកាដៃគូអភិវឌ្ឍន៍។ | |

| | |
|---|---|
| ៩ | **អង្គភាពអនុវត្ត៖** អគ្គនាយកដ្ឋានកៅស៊ូ (នាយកដ្ឋានអភិវឌ្ឍន៍កៅស៊ូ)។ |
| ១០ | **អ្នកទទួលផល៖** អគ្គនាយកដ្ឋានកៅស៊ូ កសិករកៅស៊ូគ្រួសារ និងក្រុមហ៊ុនកៅស៊ូកសិឧស្សាហកម្ម។ |
| ១១ | **ផលប៉ះពាល់ផ្នែកបរិស្ថាន៖**<br>- គ្មានផលប៉ះពាល់បរិស្ថាន។ |
| ១២ | **ផលប៉ះពាល់ផ្នែកសង្គម៖**<br>- គ្មានផលប៉ះពាល់សង្គម<br>- កាត់បន្ថយការធ្វើចំណាកស្រុករបស់ប្រជាជន<br>- បង្កើនប្រាក់ចំណូលដល់កសិករកៅស៊ូគ្រួសារ ដែលនឹងធ្វើឱ្យប្រសើរឡើងនូវជីវភាពរស់នៅរបស់ពួកគេ។ |

| | | |
|---|---|---|
| **យុទ្ធសាស្ត្រទី៤៖ ការជំរុញវិនិយោគនិងហិរញ្ញប្បទានតាមរយៈដៃគូក្នុងការអភិវឌ្ឍកៅស៊ូធម្មជាតិ** | | |
| **កម្មវិធី/គម្រោងទី៤.២៖ ការអភិវឌ្ឍដំណាំកៅស៊ូគ្រួសារ** | | |
| **ល.រ** | **បរិយាយ** | **លេខកូដ**<br>Pj4.2 |
| ១ | **គោលបំណង៖** លើកកម្ពស់ជីវភាពរបស់ប្រជាពលរដ្ឋមូលដ្ឋាននៅតាមតំបន់ជនបទ តាមរយៈការគាំទ្រការអភិវឌ្ឍកៅស៊ូគ្រួសារ និងជំរុញទំនាក់ទំនងរវាងសហគមន៍ កសិកម្មកៅស៊ូគ្រួសារ អ្នកកែច្នៃ និងអ្នកនាំចេញ។ | |
| ២ | **សនិទានភាព៖** ដំណាំកៅស៊ូជាប្រភេទដំណាំយុទ្ធសាស្ត្រមានរយៈពេលវែង ដែលទាមទារពេលវេលា និងដើមទុន វិនិយោគច្រើន។ កសិករភាគច្រើនតាមជនបទមានលទ្ធភាពតិចតួចក្នុងការទាញយកផលប្រយោជន៍ពីដំណាំកៅស៊ូ ដោយសារការខ្វះខាតហិរញ្ញវត្ថុ បច្ចេកទេសដាំដុះ និងការប្រើប្រាស់សម្ភារៈ ដែលជាឧបសគ្គក្នុងការអភិវឌ្ឍន៍ដំណាំកៅស៊ូជាលក្ខណៈគ្រួសារ។ ដូច្នេះ គម្រោងការអភិវឌ្ឍកៅស៊ូគ្រួសារបង្កើតឡើងក្នុងគោលបំណងដើម្បីលើកកម្ពស់កម្រិតជីវភាព និងជួយដោះស្រាយបញ្ហាដែលកសិករកំពុងខ្វះខាត។ ក្រៅពីផ្តល់នូវប្រាក់ចំណូលខ្ពស់ និងទៀងទាត់ដល់ប្រជាកសិករមូលដ្ឋាន ដំណាំកៅស៊ូក៏ផ្តល់នូវអត្ថប្រយោជន៍ផងដែរលើផ្នែកបរិស្ថានយ៉ាងច្រើនដូចជា៖ (១) កៅស៊ូជួយកាត់បន្ថយហានិភ័យទៅលើតំបន់ដែលមានព្រៃសេសសល់ បានជួយចូលរួមចំណែកដល់ផ្នែកអភិរក្ស (២) កៅស៊ូកាត់បន្ថយការហូរច្រោះជីវជាតិដី ទៅជាដំណាំដែលមាននិរន្តរភាពផ្នែកបរិស្ថាន (៣) កៅស៊ូចូលរួមចំណែក ជាពិសេសនៅក្នុងខេត្តបាត់ដំបងនិងខេត្តរតនគិរី (ដីភាគច្រើនរងឥទ្ធិពលដោយការធ្លាក់ចុះនូវជីវជាតិដី) ក្នុងការការពារទីជម្រាលនៅតាមដៃទន្លេ។ ដំណាំកៅស៊ូមានលទ្ធភាពខ្ពស់ក្នុងការស្រូបយកកាបូនឌីអុកស៊ីតផងដែរ។ គម្រោង "ការអភិវឌ្ឍដំណាំកៅស៊ូគ្រួសារ" គឺជាការងារចាំបាច់ ដើម្បីជួយគាំទ្រដល់ការដាំកៅស៊ូរបស់កសិករកៅស៊ូគ្រួសារ ថែមទាំងជួយគាំទ្រដល់ការបង្កើត និងពង្រឹងសហគមន៍កសិកម្មកៅស៊ូគ្រួសារនៅក្នុងតំបន់ដែលមានការដាំដុះកៅស៊ូជាលក្ខណៈគ្រួសារ ដើម្បីសហការជិតស្និទ្ធជាមួយនឹងអ្នកកែច្នៃ អ្នកនាំចេញកៅស៊ូ ដើម្បីឆ្លើយតបនឹងទីផ្សារកៅស៊ូអន្តរជាតិ ដែលជួយបង្កើនលទ្ធភាពប្រកួតប្រជែងខ្សែច្រវ៉ាក់តម្លៃ និងបង្កើនតម្លៃបន្ថែមដល់កសិករកៅស៊ូគ្រួសារ។ | |
| ៣ | **ការពិពណ៌នា៖** ដើម្បីសម្រេចបានគោលបំណងខាងលើ សកម្មភាពចំនួន ៤ត្រូវបានលើកឡើងរួមមាន៖ (១) ការផ្តល់ឥណទានដល់កសិករសម្រាប់ធ្វើការដាំដុះកៅស៊ូ (២) ការជួយគាំទ្រជំនួយការបច្ចេកទេសដំណាំកៅស៊ូនិងការកែច្នៃ ដល់សហគមន៍កសិកម្មកៅស៊ូគ្រួសារ (៣) ការជួយគាំទ្រដល់សហគមន៍កសិកម្មកៅស៊ូគ្រួសារ និង (៤) ការគ្រប់គ្រងគម្រោងនិងការគាំទ្រអនុវិស័យកៅស៊ូ។ | |
| ៤ | **លទ្ធផលក្នុងឆ្នាំនិងពេលវេលា៖**<br>គម្រោងនេះចាប់អនុវត្តឆ្នាំ២០២២ ដល់ឆ្នាំ២០២៨ ដែលមានលទ្ធផលក្នុងឆ្នាំ៖<br>- ផ្ទៃដីចំនួន ៦ ០០០ហិកតាត្រូវបានធ្វើការដាំដុះដំណាំកៅស៊ូនិងថែទាំ<br>- អ្នកបច្ចេកទេសចុះចំនួន ៨ដងក្នុងមួយឆ្នាំ ដើម្បីផ្តល់សេវាបច្ចេកទេស<br>- ចំនួនសហគមន៍ ១៥ ត្រូវបានបង្កើតនិងពង្រឹង<br>- ប្រជុំចំនួន ១០ដងក្នុងមួយឆ្នាំដើម្បីពិនិត្យវឌ្ឍនភាពគម្រោង<br>- ការអនុវត្តគម្រោងមានរយៈពេល ០៧ឆ្នាំ។ | |
| ៥ | **មុំនៃគោលនយោបាយក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ដែលគម្រោងស្ថិតនៅ៖**<br>៤.១ ការលើកស្ទួយវិស័យកសិកម្មនិងការអភិវឌ្ឍជនបទ។ | |

| | |
|---|---|
| ៦ | **លទ្ធផលចុងក្រោយ៖**<br>- ប្រាក់ចំណូលរបស់កសិករកៅស៊ូគ្រួសារកើនឡើង ១៥%។ |
| ៧ | **ថវិកាចំណាយ៖** តម្លៃសរុបប្រមាណ ៦៥ ១៩២លានរៀល ស្មើនឹងប្រមាណ ១៦,៣០លានដុល្លារអាម៉េរិក។ |
| ៨ | **ប្រភពថវិកា៖** ថវិកាដៃគូអភិវឌ្ឍន៍។ |
| ៩ | **អង្គភាពអនុវត្ត៖** អគ្គនាយកដ្ឋានកៅស៊ូ (នាយកដ្ឋានអភិវឌ្ឍន៍កៅស៊ូនិងនាយកដ្ឋានកែច្នៃផលិតផលកៅស៊ូ)។ |
| ១០ | **អ្នកទទួលផល៖** កសិករកៅស៊ូគ្រួសារនិងសហគមន៍កសិកម្មកៅស៊ូគ្រួសារ។ |
| ១១ | **ផលប៉ះពាល់ផ្នែកបរិស្ថាន៖**<br>- គ្មានផលប៉ះពាល់បរិស្ថាន<br>- កាត់បន្ថយការថយចុះដីជាតិដីនិងការខូចគុណភាពដី<br>- ជួយកាត់បន្ថយការកើនឡើងឧស្ម័នផ្ទះកញ្ចក់ ($CO_2$)<br>- ការពារការហូរច្រោះដី ជាគម្របព្រៃឈើ និង<br>- ជួយទប់ស្កាត់ការឡើកម្តៅរបស់ផែនដី។ |
| ១២ | **ផលប៉ះពាល់ផ្នែកសង្គម៖**<br>- គ្មានផលប៉ះពាល់សង្គម<br>- ជួយសម្របសម្រួលកសិករកៅស៊ូទទួលបានសុវត្ថិភាពដីធ្លី<br>- ជួយកសិករមានលទ្ធភាពដាំដំណាំចន្លោះរង បង្កើនសេដ្ឋកិច្ចគ្រួសារ<br>- លើកកម្ពស់សុវត្ថិភាពស្បៀង<br>- ចូលរួមនិងពង្រីកសិទ្ធិអំណាចរបស់សហគមន៍មូលដ្ឋាន និងជួយលើកកម្ពស់សមត្ថភាពកសិករក្នុងការចងក្រងសហគមន៍កសិកម្មកៅស៊ូគ្រួសារ។ |

<table>
<tr><td colspan="3">យុទ្ធសាស្ត្រទី៤៖ ការជំរុញវិនិយោគនិងហិរញ្ញប្បទានតាមរយៈដៃគូក្នុងការអភិវឌ្ឍកៅស៊ូធម្មជាតិ</td></tr>
<tr><td colspan="3">កម្មវិធី/គម្រោងទី៤.៣៖ ប្រព័ន្ធតាមដានចម្ការកៅស៊ូគ្រួសារក្នុងប្រទេសកម្ពុជា</td></tr>
<tr><td rowspan="2">ល.រ</td><td rowspan="2">បរិយាយ</td><td>លេខកូដ</td></tr>
<tr><td>Pj4.3</td></tr>
<tr><td>១</td><td colspan="2">គោលបំណង៖ ទទួលបានព័ត៌មាននិងទិន្នន័យជាក់លាក់សម្រាប់ជាធាតុចូលក្នុងរៀបចំ ការវិនិយោគ គោល-នយោបាយ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍កៅស៊ូធម្មជាតិ។</td></tr>
<tr><td>២</td><td colspan="2">សនិទានភាព៖ ការអភិវឌ្ឍកៅស៊ូគ្រួសារនៅកម្ពុជា បានចាប់ផ្ដើមឡើងតាំងពីឆ្នាំ១៩៥៧ ប៉ុន្តែសកម្មភាពនៃការអភិវឌ្ឍនេះត្រូវបានអាក់ខានអស់រយៈពេលយ៉ាងយូរដោយសារសង្គ្រាមស៊ីវិល និងស្ថានភាពអសន្តិសុខក្នុងតំបន់។ នៅឆ្នាំ១៩៩៩ រាជរដ្ឋាភិបាលបានរៀបចំគម្រោងអភិវឌ្ឍន៍ដំណាំកៅស៊ូគ្រួសារដែលមានរយៈពេល៣ឆ្នាំ (១៩៩៩-២០០១) ដែលបានទទួលជំនួយហិរញ្ញប្បទាន ពីទីភ្នាក់ងារបារាំងសម្រាប់ការអភិវឌ្ឍន៍ (AFD) លើផ្ទៃដីចំនួន ១ ៥០០ ហិកតា ស្ថិតក្នុងខេត្តកំពង់ចាម (ស្រុកត្បូងឃ្មុំ និងតំបែរ) បច្ចុប្បន្នខេត្តត្បូងឃ្មុំ។ មកដល់ឆ្នាំ២០១៩ ផ្ទៃដីដាំដុះដំណាំកៅស៊ូជាលក្ខណៈគ្រួសារសរុបមានចំនួន ១៣១ ១០៣ហិកតា ស្មើនឹង៣២ ១០០គ្រួសារ ដែលមានផ្ទៃដីចៀរជ័រចំនួន ១៣៣ ២៦៩ហិកតា ស្មើនឹង ២៩ ៦៧៣គ្រួសារ។ ការអនុវត្តបច្ចេកទេសដាំដុះរបស់កសិករកៅស៊ូគ្រួសារនៅមិនទាន់មានលក្ខណៈត្រឹមត្រូវនៅឡើយ ដោយកសិករភាគច្រើនមិនបានយកចិត្តទុកដាក់លើការថែទាំ និងដាក់ជីលើដំណាំកៅស៊ូរបស់ពួកគាត់ទេ។ រីឯការបើកមុខចៀរដំបូងក៏មិនបានត្រឹមត្រូវតាមបទដ្ឋានបច្ចេកទេស និងការប្រើប្រាស់ថ្នាំរំញោចច្រើនដងក្នុងមួយឆ្នាំៗ។ គម្រោង "ប្រព័ន្ធតាមដានចម្ការកៅស៊ូគ្រួសារក្នុងប្រទេសកម្ពុជា" គឺជាការងារចាំបាច់ដើម្បីជួយបង្កើនផលិតភាពចម្ការរបស់កសិករកៅស៊ូគ្រួសារ តាមរយៈការត្រួតពិនិត្យការអនុវត្តបច្ចេកទេសរបស់កសិករ និងបង្កើតប្រព័ន្ធតាមដាន ហើយនិងចែករំលែកពីការអនុវត្តល្អៗរបស់កសិករគម្រូដល់កសិករកៅស៊ូគ្រួសារផ្សេងទៀត ឱ្យអនុវត្តតាម សំដៅជួយបង្កើនផលិតភាពចម្ការនិងបង្កើនប្រាក់ចំណូលរបស់ពួកគាត់។</td></tr>
<tr><td>៣</td><td colspan="2">ការពិពណ៌នា៖ ដើម្បីសម្រេចបានគោលបំណងខាងលើ សកម្មភាពចំនួន ៣ត្រូវបានលើកឡើងរួមមាន៖ (១) ការប្រមូលព័ត៌មានពីកសិករកៅស៊ូគ្រួសារ (២) ការបណ្ដុះបណ្ដាលកសិករនិងមន្ត្រីជំនាញលើការវិភាគនិងត្រួតពិនិត្យចម្ការកៅស៊ូគ្រួសារ និង (៣) សិក្ខាសាលាផ្សព្វផ្សាយព័ត៌មានអំពីចម្ការកៅស៊ូគ្រួសារនិងកសិករកៅស៊ូគ្រួសារ។</td></tr>
<tr><td>៤</td><td colspan="2">លទ្ធផលក្នុងឆ្នាំនិងពេលវេលា៖<br>គម្រោងនេះចាប់អនុវត្តឆ្នាំ២០២១ ដល់ឆ្នាំ២០២៥ ដែលមានលទ្ធផលក្នុងឆ្នាំ៖<br>- ចំនួនសំណាក ៤០០-២ ០០០នាក់/តំបន់ ត្រូវបានធ្វើការជ្រើសរើសសម្រាប់ធ្វើការតាមដានការអនុវត្តបច្ចេកទេស<br>- សិក្ខាកាម ៤០-២២០នាក់បានចូលរួមបណ្ដុះបណ្ដាលជំនាញវិភាគនិងត្រួតពិនិត្យចម្ការ<br>- សិក្ខាកាម ២០នាក់បានចូលរួមបណ្ដុះបណ្ដាលការបញ្ចូលក្នុងកម្មវិធីWAW<br>- ការអនុវត្តគម្រោងមានរយៈពេល ០៥ឆ្នាំ។</td></tr>
<tr><td>៥</td><td colspan="2">មុំនៃគោលនយោបាយក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ដែលគម្រោងស្ថិតនៅ៖<br>៤.១ ការលើកស្ទួយវិស័យកសិកម្មនិងការអភិវឌ្ឍជនបទ។</td></tr>
<tr><td>៦</td><td colspan="2">លទ្ធផលចុងក្រោយ៖<br>- ប្រព័ន្ធព័ត៌មានការអនុវត្តបច្ចេកទេសរបស់កសិករកៅស៊ូគ្រួសារមួយត្រូវបានបង្កើតឡើងសម្រាប់ប្រទេសកម្ពុជា។</td></tr>
<tr><td>៧</td><td colspan="2">ថវិកាចំណាយ៖ តម្លៃសរុបប្រមាណ ៣ ៨៨៦លានរៀល ស្មើនឹងប្រមាណ ០,៩៧លានដុល្លារអាមេរិក។</td></tr>
<tr><td>៨</td><td colspan="2">ប្រភពថវិកា៖ ថវិកាដៃគូអភិវឌ្ឍន៍។</td></tr>
</table>

| | |
|---|---|
| ៩ | **អង្គភាពអនុវត្ត៖** អគ្គនាយកដ្ឋានកៅស៊ូ (នាយកដ្ឋានអភិវឌ្ឍន៍កៅស៊ូ)។ |
| ១០ | **អ្នកទទួលផល៖** វិនិយោគគិន និងកសិករកៅស៊ូគ្រួសារ។ |
| ១១ | **ផលប៉ះពាល់ផ្នែកបរិស្ថាន៖**<br>- គ្មានផលប៉ះពាល់បរិស្ថាន<br>- ចូលរួមកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ GHG តាមរយៈការស្រូបយកកាបូនឌីអុកស៊ីត ($CO_2$) ពីបរិយាកាស និងជាតម្របព្រៃឈើ<br>- ជួយកាត់បន្ថយការថយចុះជីជាតិដី និងការខូចគុណភាពដី។ |
| ១២ | **ផលប៉ះពាល់ផ្នែកសង្គម៖**<br>- គ្មានផលប៉ះពាល់សង្គម<br>- ជួយបង្កើតការងារនៅតាមជនបទ កាត់បន្ថយការធ្វើចំណាកស្រុករបស់ប្រជាជន<br>- លើកកម្ពស់ជីវភាពកសិករកៅស៊ូគ្រួសារ។ |

| | | |
|---|---|---|
| **យុទ្ធសាស្ត្រទី៤៖ ការជំរុញវិនិយោគនិងហិរញ្ញប្បទានតាមរយៈដៃគូក្នុងការអភិវឌ្ឍកៅស៊ូធម្មជាតិ** | | |
| **កម្មវិធី/គម្រោងទី៤.៤៖ ការសាងសង់មជ្ឈមណ្ឌលកែច្នៃកៅស៊ូសន្លឹក នៅក្នុងសហគមន៍កសិកម្មកៅស៊ូគ្រួសារ** | | |
| **ល.រ** | **បរិយាយ** | **លេខកូដ**<br>Pj4.4 |
| ១ | **គោលបំណង៖** បង្ហាញនិងជំរុញកសិករឱ្យទទួលយកបច្ចេកទេសកែច្នៃកៅស៊ូសន្លឹក សំដៅបង្កើនតម្លៃបន្ថែម លើកកម្ពស់កម្រិតជីវភាពដល់កសិករក្នុងសហគមន៍កសិកម្មកៅស៊ូគ្រួសារ។ | |
| ២ | **សនិទានភាព៖** នៅក្នុងប្រទេសកម្ពុជាបច្ចុប្បន្នសិប្បកម្មកែច្នៃកៅស៊ូសន្លឹក មិនទាន់ត្រូវបានបង្កើតនៅក្នុងសហគមន៍កសិកម្មកៅស៊ូគ្រួសារនៅឡើយ ស្របពេលដែលផ្ទៃដីចៀរជ័ររបស់កសិករកៅស៊ូគ្រួសារកំពុងកើនឡើង។ បច្ចុប្បន្នកសិករកៅស៊ូគ្រួសារនៅក្នុងសហគមន៍ទាំងនោះបានលក់ទឹកជ័រ និងជ័រកករបស់ខ្លួនទៅឱ្យម្ចាស់រោងចក្រ សិប្បកម្មតាមរយៈឈ្មួញកណ្តាល ឬអ្នកប្រមូលទិញ ធ្វើឱ្យពួកគាត់មានការបាត់បង់នូវអត្ថប្រយោជន៍មួយចំនួនដូចជា ទម្ងន់បរិមាណជ័រស្ងួតសុទ្ធ(DRC) តម្លៃបន្ថែម។ល។ លើសពីនេះទៀត កសិករកៅស៊ូគ្រួសារទាំងនោះត្រូវធ្វើការដឹកជញ្ជូនឆ្ងាយពីចម្ការទៅកន្លែងកែច្នៃ ធ្វើឱ្យចំណាយថ្លៃដឹកជញ្ជូនខ្ពស់។ គម្រោងស្តីពី "ការសាងសង់មជ្ឈមណ្ឌលកែច្នៃកៅស៊ូសន្លឹក នៅក្នុងសហគមន៍កសិកម្មកៅស៊ូគ្រួសារ" គឺជាការចាំបាច់ក្នុងការជួយ ដោះស្រាយបញ្ហាដល់សហគមន៍កៅស៊ូគ្រួសារដែលកំពុងជួបប្រទះក្នុងពេលបច្ចុប្បន្ន។ | |
| ៣ | **ការពិពណ៌នា៖** ដើម្បីសម្រេចបានគោលបំណងខាងលើ សកម្មភាពចំនួន ២ត្រូវបានលើកឡើងរួមមាន៖ (១) ការសាងសង់មជ្ឈមបណ្ឌលកែច្នៃកៅស៊ូសន្លឹក (RSS ឬ ADS) និង (២) ការសម្របសម្រួលក្នុងការផ្តល់ជំនួយបច្ចេកទេសកែច្នៃ។ | |
| ៤ | **លទ្ធផលក្នុងឆ្នាំ និង ពេលវេលា៖**<br>គម្រោងនេះចាប់អនុវត្តឆ្នាំ២០២១ ដល់ឆ្នាំ២០៣០ ដែលមានលទ្ធផលក្នុងឆ្នាំ៖<br>- សិប្បកម្មចំនួនពី ១-២ត្រូវបានបង្កើត/ឆ្នាំ<br>- ចុះសម្របសម្រួលនិងផ្តល់ជំនួយបច្ចេកទេសចំនួនពី ៤-៨ដង/ឆ្នាំ<br>- ការអនុវត្តគម្រោងមានរយៈពេល ១០ឆ្នាំ។ | |
| ៥ | **ទុំនៃគោលនយោបាយក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ដែលគម្រោងស្ថិតនៅ៖**<br>៤.១ ការលើកស្ទួយវិស័យកសិកម្ម និងការអភិវឌ្ឍជនបទ។ | |
| ៦ | **លទ្ធផលចុងក្រោយ៖**<br>- សិប្បកម្មចំនួន ១៩ត្រូវបានបង្កើត<br>- ចុះសម្របសម្រួលនិងផ្តល់ជំនួយបច្ចេកទេសចំនួន ៧៦ដង។ | |
| ៧ | **ថវិកាចំណាយ៖** តម្លៃសរុបប្រមាណ ១៦ ៥៨០លានរៀល ស្មើនឹងប្រមាណ ៤,១៥លានដុល្លារអាម៉េរិក។ | |
| ៨ | **ប្រភពថវិកា៖** ថវិកាជាតិ និងដៃគូអភិវឌ្ឍន៍។ | |
| ៩ | **អង្គភាពអនុវត្ត៖** អគ្គនាយកដ្ឋានកៅស៊ូ (នាយកដ្ឋានកែច្នៃផលិតផលកៅស៊ូ)។ | |
| ១០ | **អ្នកទទួលផល៖** ប្រតិបត្តិករកៅស៊ូ។ | |
| ១១ | **ផលប៉ះពាល់ផ្នែកបរិស្ថាន៖**<br>- គ្មានផលប៉ះពាល់បរិស្ថាន | |

| | |
|---|---|
| | - កាត់បន្ថយការបំពុលដែលចេញពីសិប្បកម្ម<br>- កាត់បន្ថយការប្រើប្រាស់ប្រេងឥន្ធនៈ។ |
| ១២ | **ផលប៉ះពាល់ផ្នែកសង្គមៈ**<br>- គ្មានផលប៉ះពាល់សង្គម<br>- បង្កើតឱ្យមានភាពជាពាណិជក្នុងការចរចាតម្លៃ<br>- បង្កើនតម្លៃបន្ថែមនិងជួយកាត់បន្ថយភាពក្រីក្រ<br>- បង្កើតការងារនិងកាត់បន្ថយការធ្វើចំណាកស្រុក។ |

| | | |
|---|---|---|
| **យុទ្ធសាស្ត្រទី៤៖ ការជំរុញវិនិយោគនិងហិរញ្ញប្បទានតាមរយៈដៃគូក្នុងការអភិវឌ្ឍកៅស៊ូធម្មជាតិ** | | |
| **កម្មវិធី/គម្រោងទី៤.៥៖ ការរៀបចំបង្កើតមណ្ឌលទីផ្សារកៅស៊ូ** | | |
| **ល.រ** | **បរិយាយ** | **លេខកូដ**<br>Pj4.5 |
| ១ | **គោលបំណង៖** ធ្វើឱ្យប្រសើរឡើងនូវការធ្វើធុរកិច្ចកៅស៊ូក្នុងស្រុករបស់កសិករកៅស៊ូគ្រួសារ មានទីផ្សារជាក់លាក់ បង្កើនថ្លៃកៅស៊ូនៅចម្ការរបស់កសិករ ទទួលបានថ្លៃកៅស៊ូខ្ពស់សមស្របតាមថ្លៃនៅលើទីផ្សារកៅស៊ូពិភពលោក និងប្រាក់ចំណូលកើនឡើង។ | |
| ២ | **សនិទានភាព៖** រហូតមកទល់នឹងបច្ចុប្បន្ននេះ កសិករកៅស៊ូគ្រួសារបាននិងកំពុងប្រឈមបញ្ហាថ្លៃកៅស៊ូទាប និងកង្វះបណ្តាញទីផ្សារក្នុងស្រុកតាមតំបន់នីមួយៗ បើធៀបនឹងបណ្តាប្រទេសផលិតកៅស៊ូធម្មជាតិជិតខាង។ ទីផ្សារសម្រាប់ផលិតផលកៅស៊ូគ្រួសារកម្ពុជាបានកើតឡើងដោយឯងៗរវាងអ្នកទិញនិងអ្នកលក់ គ្មានលក្ខណៈប្រមូលផ្តុំ ខ្វះអំណាចចរចាថ្លៃ និងឆ្លងកាត់ឈ្មួញកណ្តាលជាច្រើនដំណាក់កាល។ គម្រោងស្តីអំពី "ការរៀបចំបង្កើតមណ្ឌលទីផ្សារកៅស៊ូ" គឺជាយន្តការដែលមានប្រយោជន៍សម្រាប់ជួយធានាដល់ការលក់ដូរកៅស៊ូរបស់កសិករកៅស៊ូគ្រួសារមាននិរន្តរភាព ដោយផ្សារភ្ជាប់ទៅនឹងថ្លៃកៅស៊ូនៅទីផ្សារកៅស៊ូអន្តរជាតិ តាមរយៈការរៀបចំបណ្តាញទីផ្សារក្នុងស្រុកតាមតំបន់នីមួយៗ ដោយមានកិច្ចសហការគាំទ្រនិងការចូលរួមពីដៃគូរនានា សំដៅធ្វើឱ្យថ្លៃផលិតផលកៅស៊ូរបស់កសិករនៅចម្ការបានប្រសើរឡើង។ | |
| ៣ | **ការពិពណ៌នា៖** ដើម្បីសម្រេចបានតាមគោលបំណងខាងលើ មានសកម្មភាពចំនួន ០៣ត្រូវបានលើកឡើងគឺ៖ (១)ការចុះសិក្សាលទ្ធភាពបង្កើតមណ្ឌលទីផ្សារក្នុងស្រុកតាមតំបន់ (២) ការរៀបចំបង្កើតមណ្ឌលទីផ្សារកៅស៊ូក្នុងស្រុកតាមតំបន់ និង (៣) ការសិក្សាស្រាវជ្រាវនិងរៀបចំចងក្រងឯកសារបង្កើតមជ្ឈមណ្ឌលទីផ្សារកៅស៊ូ។ | |
| ៤ | **លទ្ធផលក្នុងឆ្នាំ និងពេលវេលា៖**<br>គម្រោងនេះចាប់អនុវត្តឆ្នាំ២០២៣ ដល់ឆ្នាំ២០៣០ ដែលមានលទ្ធផលក្នុងឆ្នាំ៖<br>- មណ្ឌលទីផ្សារកៅស៊ូក្នុងស្រុកតាមតំបន់ពីចំនួន ១ទៅ ៤ត្រូវបង្កើត<br>- ឯកសារសម្រាប់បង្កើតមជ្ឈមណ្ឌលទីផ្សារកៅស៊ូ ៥០ច្បាប់ត្រូវបានផលិត។<br>- ការអនុវត្តគម្រោងមានរយៈពេល ០៨ឆ្នាំ។ | |
| ៥ | **មុំនៃគោលនយោបាយក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ដែលគម្រោងស្ថិតនៅ៖**<br>៤.១ ការលើកស្ទួយវិស័យកសិកម្មនិងការអភិវឌ្ឍជនបទ | |
| ៦ | **លទ្ធផលចុងក្រោយ៖**<br>- អត្រាថ្លៃលក់កៅស៊ូរបស់កសិករធៀបនឹងFOB កើនឡើងក្នុងរង្វង់៧៥% នៅឆ្នាំ២០៣០។ | |
| ៧ | **ថវិកាចំណាយ៖** ថវិកាសរុបប្រមាណ ២ ៣០៩លានរៀល ស្មើនឹងប្រមាណ ០,៥៨លានដុល្លារអាម៉េរិក។ | |
| ៨ | **ប្រភពថវិកា៖** ថវិកាដៃគូរអភិវឌ្ឍន៍។ | |
| ៩ | **អង្គភាពអនុវត្ត៖** អគ្គនាយកដ្ឋានកៅស៊ូ (នាយកដ្ឋានទីផ្សារនិងសហប្រតិបត្តិការអន្តរជាតិ)។ | |
| ១០ | **អ្នកទទួលផល៖** សហគមន៍កសិកម្មកៅស៊ូគ្រួសារតាមខេត្តនិងតំបន់និងកសិករកៅស៊ូគ្រួសារ។ | |
| ១១ | **ផលប៉ះពាល់ផ្នែកបរិស្ថាន៖**<br>- គ្មានផលប៉ះពាល់បរិស្ថាន។ | |
| ១២ | **ផលប៉ះពាល់ផ្នែកសង្គម៖**<br>- គ្មានផលប៉ះពាល់សង្គម | |

| | |
|---|---|
| | - បង្កើនទំនុកចិត្តដល់កសិករកៅស៊ូគ្រួសារក្នុងការធ្វើធុរៈកិច្ចកៅស៊ូជាមួយអ្នកទិញ តាមរយៈការលក់ដូរជាលក្ខណៈប្រមូលផ្តុំនិងមានអំណាចចរចាថ្លៃនៅតាមបណ្តាញទីផ្សារក្នុងតំបន់ជាក់លាក់<br>- ជួយជំរុញឱ្យសកម្មភាពក្នុងអនុវិស័យកៅស៊ូមានការអភិវឌ្ឍប្រកបដោយចិរភាព និងលើកកម្ពស់ជីវភាពរបស់កសិករកៅស៊ូគ្រួសារកាន់តែប្រសើរឡើង។ |

| យុទ្ធសាស្ត្រទី៤៖ ការជំរុញវិនិយោគនិងហិរញ្ញប្បទានតាមរយៈដៃគូក្នុងការអភិវឌ្ឍកៅស៊ូធម្មជាតិ | | |
|---|---|---|
| **កម្មវិធី/គម្រោងទី៤.៦៖ ការគ្រប់គ្រងទិន្នន័យកៅស៊ូតាមប្រព័ន្ធព័ត៌មានភូមិសាស្ត្រ (GIS)** | | |
| **ល.រ** | **បរិយាយ** | **លេខកូដ** |
| | | Pj4.6 |
| ១ | **គោលបំណង៖** លើកកម្ពស់ការគ្រប់គ្រងទិន្នន័យកៅស៊ូគ្រួសារ និងកៅស៊ូកសិឧស្សាហកម្ម ដោយប្រើប្រាស់ប្រព័ន្ធព័ត៌មានភូមិសាស្ត្រ (Geographic Information System: GIS) សម្រាប់រៀបចំគោលនយោបាយ ផែនការអភិវឌ្ឍន៍ឱ្យមានប្រសិទ្ធភាពខ្ពស់ និងផ្តល់អនុសាសន៍បច្ចេកទេសដំណាំកៅស៊ូដល់អ្នកដាំ។ | |
| ២ | **សនិទានភាព៖** ដំណាំកៅស៊ូត្រូវបានដាំជាលើកដំបូងក្នុងប្រវត្តិសាស្ត្រកម្ពុជានាឆ្នាំ១៩១០ ដោយលោក **ប៊ូ យ៉ា** ជនជាតិបារាំង នៅក្នុងស្រុកព្រៃនប់ ខេត្តកំពត (បច្ចុប្បន្ន ខេត្តព្រះសីហនុ) លើផ្ទៃដីជាង ១៥០ហិកតា។ ដល់ឆ្នាំ១៩២១ ទើបដំណាំកៅស៊ូជាលក្ខណៈឧស្សាហកម្មទ្រង់ទ្រាយធំ ត្រូវបានបង្កើតឡើងដោយក្រុមហ៊ុនវិនិយោគរបស់បារាំងធំៗចំនួន ៥នៅលើដីក្រហមបាសាល់នៅខេត្តកំពង់ចាម ខេត្តក្រចេះ និងខេត្តរតនគិរី លើផ្ទៃដីទំហំជាង ៥០ ០០០ហិកតា។ រហូតមកដល់ឆ្នាំ១៩៦៩ ដំណាំកៅស៊ូនៅកម្ពុជាបានពង្រីកផ្ទៃដីសរុបជាង ៦៤ ០០០ហិកតា ក្នុងនោះផ្ទៃដីចៀរជ័រមានជាង ៣៩ ០០០ហិកតា ដោយទទួលបានផលិតផលកៅស៊ូជាង ៥០ ០០០តោន សម្រាប់ការប្រើប្រាស់នៅក្នុងស្រុកនិងការនាំចេញទៅបរ-ទេស។ នៅជំនាន់នោះ កម្ពុជាត្រូវបានអន្តរជាតិទទួលស្គាល់ច្បាស់ថាជាប្រទេសដែលមានចម្ការកៅស៊ូល្អ ដែលមានទិន្នផលខ្ពស់និងផលិតផលកៅស៊ូប្រកបដោយគុណភាពខ្ពស់នៅក្នុងតំបន់អាស៊ី។ រហូតដល់ឆ្នាំ២០១៩នេះ ផ្ទៃដីកៅស៊ូកម្ពុជាសរុបចំនួន ៤០៥ ៦៧១ហិកតា ដែលបានត្រូវបានបែងចែកជា ០២ផ្នែកគឺ៖ ក្រុមហ៊ុនចម្ការកៅស៊ូកសិឧស្សាហកម្មសរុបមានចំនួន ២៤៤ ៥៦៨ហិកតា ស្មើនឹង ៦០,២៩% និងកៅស៊ូគ្រួសារមានចំនួន ១៦១ ១០៣ហិកតា ស្មើនឹង ៣៩,៧១% នៃផ្ទៃដីកៅស៊ូសរុប។ ស្ថិតិកៅស៊ូនៅកម្ពុជាមិនទាន់មានភាពច្បាស់លាស់នៅឡើយទេ ព្រោះមិនដឹងពីទីតាំងការដាំដុះ ប្រភេទក្លូន ផ្ទៃដី ឆ្នាំដាំនិងឆ្នាំចៀរជ័រ។ លើសពីនេះទៀត កម្ពុជាមិនទាន់មានប្រព័ន្ធគ្រប់គ្រងស្ថិតិមួយដែលល្អនិងទាន់សម័យ ដែលជួយសម្រួលក្នុងការគ្រប់គ្រងទិន្នន័យ។ គម្រោង "ការគ្រប់គ្រងទិន្នន័យកៅស៊ូតាមប្រព័ន្ធព័ត៌មានភូមិសាស្ត្រ(GIS)" គឺជាការងារចាំបាច់ ដើម្បីប្រមូលព័ត៌មានសម្រាប់ វិភាគ ត្រួតពិនិត្យ បញ្ជូន ប្រើប្រាស់ រក្សាទុក និងបង្ហាញទិន្នន័យ ទីតាំងចម្ការកៅស៊ូនៅលើផែនទីប្រទេស។ | |
| ៣ | **ការពិពណ៌នា៖** ដើម្បីសម្រេចបានគោលបំណងខាងលើ សកម្មភាពចំនួន ០២ត្រូវបានលើកឡើងរួមមាន៖ (១) ការបណ្តុះបណ្តាលធនធានមនុស្សអំពីប្រព័ន្ធព័ត៌មានភូមិសាស្ត្រ(GIS) និង (២) ការចុះប្រមូល វិភាគនិងចងក្រងទិន្នន័យព័ត៌មានកៅស៊ូគ្រួសារនិងកៅស៊ូកសិឧស្សាហកម្ម។ | |
| ៤ | **លទ្ធផលក្នុងឆ្នាំនិងពេលវេលា៖**<br>គម្រោងនេះចាប់អនុវត្តឆ្នាំ២០២៧ ដល់ឆ្នាំ២០៣០ ដែលមានលទ្ធផលក្នុងឆ្នាំ៖<br>- ខេត្តចំនួន ៥ក្នុងមួយឆ្នាំត្រូវបានចុះសិក្សាធ្វើការវាស់វែង<br>- សិក្ខាកាមចំនួន ៥០នាក់ក្នុងមួយឆ្នាំ<br>- ការអនុវត្តគម្រោងមានរយៈពេល ០៤ឆ្នាំ។ | |
| ៥ | **មុំនៃគោលនយោបាយក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ដែលគម្រោងស្ថិតនៅ៖**<br>៤.១ ការលើកស្ទួយវិស័យកសិកម្មនិងការអភិវឌ្ឍជនបទ។ | |

| | |
|---|---|
| ៦ | **លទ្ធផលចុងក្រោយ៖**<br>- ចម្ការប្រមាណជាង ៣០ ០០០ចម្ការត្រូវបានវាស់វែងនិងកំណត់ទីតាំង<br>- ប្រព័ន្ធព័ត៌មានភូមិសាស្ត្រស្ដីពីចម្ការកៅស៊ូនៅកម្ពុជាត្រូវបានបង្កើត។ |
| ៧ | **ថវិកាចំណាយ៖** តម្លៃសរុបប្រមាណ ១ ២៧៣លានរៀល ស្មើនឹងប្រមាណ ០,៣២លានដុល្លារអាម៉េរិក។ |
| ៨ | **ប្រភពថវិកា៖** ថវិកាដៃគូអភិវឌ្ឍន៍។ |
| ៩ | **អង្គភាពអនុវត្ត៖** អគ្គនាយកដ្ឋានកៅស៊ូ (នាយកដ្ឋានអភិវឌ្ឍន៍កៅស៊ូនិងនាយកដ្ឋានផែនការ ហិរញ្ញវត្ថុ និងស្ថិតិ)។ |
| ១០ | **អ្នកទទួលផល៖** អគ្គនាយកដ្ឋានកៅស៊ូ ម្ចាស់ចម្ការកៅស៊ូគ្រួសារ និងកសិឧស្សាហកម្ម។ |
| ១១ | **ផលប៉ះពាល់ផ្នែកបរិស្ថាន៖**<br>- គ្មានផលប៉ះពាល់បរិស្ថាន។ |
| ១២ | **ផលប៉ះពាល់ផ្នែកសង្គម៖**<br>- គ្មានផលប៉ះពាល់សង្គម។ |

| យុទ្ធសាស្ត្រទី៤៖ ការជំរុញវិនិយោគនិងហិរញ្ញប្បទានតាមរយៈដៃគូក្នុងការអភិវឌ្ឍកៅស៊ូធម្មជាតិ | | |
|---|---|---|
| **កម្មវិធី/គម្រោងទី៤.៧ ៖ ការគាំទ្រសមាគមអភិវឌ្ឍន៍កៅស៊ូកម្ពុជា** | | |
| **ល.រ** | **បរិយាយ** | **លេខកូដ**<br>Pj4.7 |
| ១ | **គោលបំណង៖** បង្កើនប្រសិទ្ធភាពនិងធានានិរន្តរភាពការងាររបស់សមាគម តាមរយៈការលើកកម្ពស់កិច្ចសហ-ប្រតិបត្តិការរវាងស្ថាប័នរដ្ឋនិងផ្នែកឯកជន។ | |
| ២ | **សនិទានភាព៖** សមាគមអភិវឌ្ឍន៍កៅស៊ូកម្ពុជា(ARDC) ត្រូវបានបង្កើតឡើងក្នុងឆ្នាំ២០០៥ ដែលមានក្រុមហ៊ុនចម្ការកៅស៊ូធំចំនួន ៧បានសហការគ្នាដើម្បីបង្កើតសមាគមនេះឡើង។ ការបង្កើតសមាគមនេះក្នុងគោលបំណងលើកកម្ពស់គុណភាព និងបរិមាណកៅស៊ូរបស់ក្រុមហ៊ុនកសិឧស្សាហនៅកម្ពុជា ដើម្បីឆ្លើយតបតាមស្តង់ដារទីផ្សារអន្តរជាតិ។ សមាគមមានតួនាទីពង្រឹងសមត្ថភាពដល់អ្នកដាំ អ្នកកែច្នៃ និងធុរកិច្ចកម្ពុជាដែលជាសមាជិករបស់សមាគមតាមរយៈការផ្សព្វផ្សាយ បណ្តុះបណ្តាលនិងសិក្ខាសាលា។ ស្របតាមគោលនយោបាយផ្តល់សម្បទានដីសេដ្ឋកិច្ចដល់អ្នកវិនិយោគិនក្នុងស្រុកនិងបរទេស បានធ្វើឱ្យការអភិវឌ្ឍដំណាំជាលក្ខណៈកសិឧស្សាហកម្មមានការរីកចម្រើនគួរឱ្យកត់សំគាល់។ ជាក់ស្តែងនៅក្នុងឆ្នាំ២០១៨ ក្រុមហ៊ុនដែលបានសិទ្ធិវិនិយោគលើដំណាំកៅស៊ូមានចំនួន ១១៥ក្រុមហ៊ុន នៅរាយបាយក្នុងខេត្តចំនួន ១១ ដោយធ្វើការដាំដុះកៅស៊ូលើផ្ទៃដីប្រមាណ ១៩៥ពាន់ហិកតា។ បច្ចុប្បន្នសមាគមនៅមានភាពទន់ខ្សោយដោយសារ(១) សមាជិកមានចំនួនតិច (២) ខ្វះការផ្សព្វផ្សាយ ដើម្បីគៀរគរសមាជិកថ្មី (៣) រចនាសម្ព័ន្ធនិងការគ្រប់គ្រងរបស់សមាគមនៅមានកំរិត (៤) សមាគមមិនទាន់បានបំពេញតួនាទីនិងភារកិច្ចរបស់ខ្លួនបានពេញលេញនៅឡើយ និង (៥) ខ្វះការសហការគ្នារវាងស្ថាប័នរដ្ឋនិងវិស័យឯកជន។ គម្រោង "ការគាំទ្រសមាគមអភិវឌ្ឍន៍កៅស៊ូកម្ពុជា" គឺជាការងារចាំបាច់ ដើម្បីឱ្យសមាគមមានភាពរឹងមាំក្នុងការប្រតិបត្តិក្នុងនាមធុរកិច្ចកៅស៊ូកម្ពុជាពង្រឹងរចនាសម្ព័ន្ធ តួនាទីនិងភារកិច្ចរបស់សមាគម តាមបរិបទសកល។ លើសពីនេះទៀតសមាគមត្រូវជំរុញការផ្សព្វផ្សាយដើម្បីគៀរគរសមាជិកថ្មី ព្រមទាំងលើកកម្ពស់កិច្ចសហការល្អជាមួយ ស្ថាប័នរដ្ឋ ដៃគូអភិវឌ្ឍន៍នានា អង្គការ វិទ្យាស្ថានជាតិនិងអន្តរជាតិ និងស្ថាប័នពាក់ព័ន្ធផ្សេងៗទៀត។ | |
| ៣ | **ការពិពណ៌នា៖** ដើម្បីសម្រេចបានគោលបំណងខាងលើ សកម្មភាពចំនួន ៤ត្រូវបានលើកឡើងរួមមាន៖ (១) ការពង្រឹងតួនាទី ភារកិច្ចរបស់សមាគមអភិវឌ្ឍន៍កៅស៊ូកម្ពុជា (២) ការរៀបចំសិក្ខាសាលាជំរុញការវិនិយោគកៅស៊ូ (៣) ការចូលរួមសម្របសម្រួលរៀបចំសន្និបាតរបស់សមាគម និង (៤) ការសម្របសម្រួលសមាគមបានចូលរួមកិច្ចប្រជុំ Rubber Dinner, ANRPC, IRRDB, ARBC, GRC, IRSG …។ | |
| ៤ | **លទ្ធផលក្នុងឆ្នាំនិងពេលវេលា៖**<br>គម្រោងនេះចាប់អនុវត្តឆ្នាំ២០២៣ ដល់ឆ្នាំ២០២៦ ដែលមានលទ្ធផលក្នុងឆ្នាំ៖<br>- សមាគមនឹងមានកិច្ចប្រជុំចំនួន ២ដងក្នុងមួយឆ្នាំ<br>- សិក្ខាកាមចំនួន ១៥០នាក់/ឆ្នាំ ចូលរួមសិក្ខាសាលាជំរុញការវិនិយោគ<br>- សិក្ខាកាមចំនួន ២០០នាក់/ឆ្នាំ ចូលរួមសន្និបាទប្រចាំឆ្នាំ<br>- សមាគមបានចូលរួមប្រជុំអន្តរជាតិចំនួន ៤ដងក្នុងមួយឆ្នាំ<br>- ការអនុវត្តគម្រោងមានរយៈពេល ០៤ឆ្នាំ។ | |
| ៥ | **មុំនៃគោលនយោបាយក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ដែលគម្រោងស្ថិតនៅ៖**<br>៤.១ ការលើកស្ទួយវិស័យកសិកម្មនិងការអភិវឌ្ឍជនបទ។ | |
| ៦ | **លទ្ធផលចុងក្រោយ៖**<br>- ក្រុមហ៊ុនកៅស៊ូកសិឧស្សាហកម្ម ៧០បានចូលរួមជាមួយសមាគម។ | |

| | |
|---|---|
| ៧ | **ថវិកាចំណាយ៖** តម្លៃសរុបប្រមាណ ៦៧៣លានរៀល ស្មើនឹងប្រមាណ ០,១៧លានដុល្លារអាម៉េរិក។ |
| ៨ | **ប្រភពថវិកា៖** ថវិកាដៃគូអភិវឌ្ឍន៍។ |
| ៩ | **អង្គភាពអនុវត្ត៖** អគ្គនាយកដ្ឋានកៅស៊ូ (នាយកដ្ឋានអភិវឌ្ឍន៍កៅស៊ូ)។ |
| ១០ | **អ្នកទទួលផល៖** ក្រុមហ៊ុនកៅស៊ូកសិ-ឧស្សាហកម្មសហ ,សិប្បកម្មកែច្នៃកៅស៊ូសន្លឹក ,រោងចក្រកែច្នៃកៅស៊ូ , គមន៍កសិកម្មកៅស៊ូគ្រួសារតាមបណ្តាខេត្ត និងកសិករដាំកៅស៊ូ។ |
| ១១ | **ផលប៉ះពាល់ផ្នែកបរិស្ថាន៖**<br>- គ្មានផលប៉ះពាល់បរិស្ថាន។ |
| ១២ | **ផលប៉ះពាល់ផ្នែកសង្គម៖**<br>- គ្មានផលប៉ះពាល់សង្គម។ |

| យុទ្ធសាស្ត្រទី៤៖ ការជំរុញវិនិយោគនិងហិរញ្ញប្បទានតាមរយៈដៃគូក្នុងការអភិវឌ្ឍកៅស៊ូធម្មជាតិ | | |
|---|---|---|
| **កម្មវិធី/គម្រោងទី៤.៨៖ ការអភិវឌ្ឍធនធានមនុស្សក្នុងអនុវិស័យកៅស៊ូ** | | |
| **ល.រ** | **បរិយាយ** | **លេខកូដ**<br>Pj4.8 |
| ១ | **គោលបំណង៖** បង្កើនសមត្ថភាព ចំណេះដឹង ជំនាញ ដល់មន្ត្រីរាជការ ធានាលើកកម្ពស់ប្រសិទ្ធភាពការងារ ជំរុញការអភិវឌ្ឍប្រទេសជាតិ។ | |
| ២ | **សនិទានភាព៖** ចាប់តាំងពីឆ្នាំ១៩១០ ដែលជាកាលបរិច្ឆេទនៃការដាំដុះកៅស៊ូលើកដំបូងរហូតមកដល់បច្ចុប្បន្ននេះ វិស័យកៅស៊ូនៅកម្ពុជាមានសន្ទុះឆ្ពោះទៅរកការអភិវឌ្ឍមួយប្រកបដោយចីរភាពនៅក្នុងការដាំដុះ និងការយកផល។ ទន្ទឹមនឹងការរីកចម្រើននេះ ចំនួននិងសមត្ថភាពមន្ត្រីរាជការផ្នែកអនុវិស័យកៅស៊ូនៅមានកម្រិតដែលទាមទារការបណ្តុះបណ្តាលឱ្យស្របតាមការវិវត្តថ្មីៗនៃបច្ចេកវិទ្យា។ ដូច្នេះ គម្រោង "ការអភិវឌ្ឍធនធានមនុស្សក្នុងអនុវិស័យកៅស៊ូ" គឺជាការងារកត្តាចម្បងបំផុត ដើម្បីពង្រឹងសមត្ថភាព បង្កើនចំណេះដឹងជំនាញដល់មន្ត្រីរាជការ ក្នុងការបំពេញការងារឱ្យស្របតាមការវិវត្តន៍ថ្មីៗនៃបច្ចេកវិទ្យា សំដៅឆ្ពោះទៅរកជោគជ័យរបស់អង្គភាព ជំរុញដល់ការអភិវឌ្ឍន៍ប្រទេសជាតិ។ | |
| ៣ | **ការពិពណ៌នា៖** ដើម្បីសម្រេចបានគោលបំណងខាងលើសកម្មភាពចំនួន០១ ត្រូវបានលើកឡើងមាន៖ ការអភិវឌ្ឍធនធានមនុស្សក្នុងអនុវិស័យកៅស៊ូ។ | |
| ៤ | **លទ្ធផលចុងក្រោយ និង ពេលវេលា៖**<br>គម្រោងនេះអនុវត្តចាប់ពីឆ្នាំ២០២១ ដល់ឆ្នាំ២០៣០ ដែលមានលទ្ធផលក្នុងឆ្នាំ៖<br>- មន្ត្រីរាជការចំនួន ០៨នាក់/ឆ្នាំ ត្រូវបានទទួលការបណ្តុះបណ្តាលសមត្ថភាពជំនាញក្នុងនិងក្រៅប្រទេស<br>- ការអនុវត្តគម្រោងមានរយៈពេល ១០ឆ្នាំ។ | |
| ៥ | **មុំនៃគោលនយោបាយក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ដែលគម្រោងស្ថិតនៅ៖**<br>៤.១ ការលើកស្ទួយកសិកម្ម និងការអភិវឌ្ឍជនបទ។ | |
| ៦ | **លទ្ធផលចុងក្រោយ៖**<br>- មន្ត្រីរាជការចំនួន ៨០នាក់បានទទួលការបណ្តុះបណ្តាលបង្កើនសមត្ថភាពជំនាញក្នុងនិងក្រៅប្រទេស។ | |
| ៧ | **ថវិកាចំណាយ៖** តម្លៃសរុបប្រមាណ ១ ១៦៥លានរៀល ស្មើនឹងប្រមាណ ០,២៩លានដុល្លារអាម៉េរិក។ | |
| ៨ | **ប្រភពថវិកា៖** ថវិកាដៃគូអភិវឌ្ឍន៍។ | |
| ៩ | **អង្គភាពអនុវត្ត៖** អគ្គនាយកដ្ឋានកៅស៊ូ (នាយកដ្ឋានរដ្ឋបាល និងនីតិកម្ម)។ | |
| ១០ | **អ្នកទទួលផល៖** មន្ត្រីរាជការ នៃអគ្គនាយកដ្ឋានកៅស៊ូ។ | |
| ១១ | **ផលប៉ះពាល់ផ្នែកបរិស្ថាន៖**<br>- គ្មានផលប៉ះពាល់បរិស្ថាន។ | |
| ១២ | **ផលប៉ះពាល់ផ្នែកសង្គម៖**<br>- គ្មានផលប៉ះពាល់សង្គម<br>- រួមចំណែកអភិវឌ្ឍន៍ធនធានមនុស្ស។ | |

| | | |
|---|---|---|
| **យុទ្ធសាស្ត្រទី៤៖ ការជំរុញវិនិយោគនិងហិរញ្ញប្បទានតាមរយៈដៃគូក្នុងការអភិវឌ្ឍកៅស៊ូធម្មជាតិ** | | |
| **កម្មវិធី/គម្រោង៤.៩៖ ការសិក្សាទីតាំងបង្កើតទីក្រុងកៅស៊ូ** | | |
| **ល.រ** | **បរិយាយ** | **លេខកូដ**<br>Pj4.9 |
| ១ | **គោលបំណង៖** កំណត់ទីតាំងដែលមានសក្តានុពលអាចទាក់ទាញវិនិយោគគិនដែលមានបំណងបង្កើតរោងចក្រឧស្សាហកម្មកម្មន្តសាលផលិតផលិតផលសម្រេចពីកៅស៊ូ សំដៅជំរុញការប្រើប្រាស់ផលិតផលកៅស៊ូក្នុងស្រុកនិងបង្កើនប្រាក់ចំណូលដល់អ្នកពាក់ព័ន្ធក្នុងអនុវិស័យកៅស៊ូ។ | |
| ២ | **សនិទានភាព៖** បច្ចុប្បន្នប្រទេសកម្ពុជាមិនទាន់បានបង្កើតទីក្រុងកៅស៊ូនៅឡើយ ដែលជាតំបន់ឧស្សាហកម្មកម្មន្តសាលផលិតផលិតផលសម្រេចពីកៅស៊ូ ស្របពេលដែលផលិតផលកៅស៊ូកំពុងមានការកើនឡើង ភាគច្រើនត្រូវបាននាំចេញទៅបរទេស។ ជាមួយគ្នានោះ នៅក្នុងបណ្តាប្រទេសជាសមាជិកនៃសមាគមបណ្តាប្រទេសផលិតកៅស៊ូធម្មជាតិ(ANRPC) មួយចំនួនក៏បាននឹងកំពុងបង្កើតទីក្រុងកៅស៊ូនេះផងដែរ រួមមាន៖ ប្រទេសថៃឡង់ដ៏ (ចំណាយគម្រោងប្រមាណ២៣៥លានដុល្លាអាមេរិក លើផ្ទៃដីជាង ២០០ហិកតា) ស្រីលង្កា(ចំណាយគម្រោងប្រមាណ ១១ លានដុល្លាអាមេរិក លើផ្ទៃដី ១០០ហិកតា)។ គម្រោង "ការសិក្សាទីតាំងបង្កើតទីក្រុងកៅស៊ូ" ដើរតួនាទីយ៉ាងសំខាន់ក្នុងការផ្តល់ការអភិវឌ្ឍធនធានមនុស្ស ការស្រាវជ្រាវនិងអភិវឌ្ឍន៍ ការបង្កើតរោងចក្រកម្មន្តសាល ការធ្វើពាណិជ្ជកម្ម និងការនាំចេញផលិតផលសម្រេចពីកៅស៊ូ ដើម្បីបង្កើនតម្លៃបន្ថែមដល់ប្រតិបត្តិករកៅស៊ូ ព្រមទាំងចូលរួមចំណែកកាត់បន្ថយភាពក្រីក្រ ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា។ | |
| ៣ | **ការពិពណ៌នា៖** ដើម្បីសម្រេចឱ្យបានតាមគោលបំណងខាងលើ សកម្មភាពចំនួន ០២ត្រូវបានលើកឡើងមាន៖ (១)ការសិក្សានិងកំណត់ទីតាំងទីក្រុងកៅស៊ូ និង (២) ការផ្សព្វផ្សាយទីក្រុងកៅស៊ូ។ ក្រៅពីនេះមានសមាសភាគគម្រោងដទៃទៀតដែលត្រូវបានលើកឡើងទៅតាមក្រសួង/ស្ថាប័នពាក់ព័ន្ធ។ | |
| ៤ | **លទ្ធផលក្នុងឆ្នាំ និង ពេលវេលា៖**<br>គម្រោងនេះអនុវត្តចាប់ពីឆ្នាំ២០២៤ ដល់ឆ្នាំ២០២៥ ដែលមានលទ្ធផលក្នុងឆ្នាំ៖<br>- ការចុះសិក្សាចំនួន៣ដង/ឆ្នាំ<br>- អ្នកចូលរួមសិក្ខាសាលា១៥០នាក់<br>- ការអនុវត្តគម្រោងមានរយៈពេល ២ឆ្នាំ។ | |
| ៥ | **មុំនៃគោលនយោបាយក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ដែលគម្រោងស្ថិតនៅ៖**<br>៤.១ ការលើកស្ទួយវិស័យកសិកម្ម និងការអភិវឌ្ឍជនបទ។ | |
| ៦ | **លទ្ធផលចុងក្រោយ៖**ទីក្រុងកៅស៊ូចំនួន១ត្រូវបានសិក្សា។ | |
| ៧ | **ថវិកាចំណាយ៖** តម្លៃសរុបប្រមាណ ៥៦លានរៀល ស្មើនឹងប្រមាណ ០,០១៤លានដុល្លារអាម៉េរិក។ | |
| ៨ | **ប្រភពថវិកា៖** ថវិកាដៃគូអភិវឌ្ឍន៍។ | |
| ៩ | **អង្គភាពអនុវត្ត៖** ក្រសួង/ស្ថាប័នពាក់ព័ន្ធ។ | |
| ១០ | **អ្នកទទួលផល៖** ប្រតិបត្តិករកៅស៊ូ និងអ្នកពាក់ព័ន្ធ។ | |
| ១១ | **ផលប៉ះពាល់ផ្នែកបរិស្ថាន៖**<br>- គ្មានផលប៉ះពាល់បរិស្ថាន<br>- ការកែច្នៃកាកសំណល់ និងការប្រើប្រាស់ឡើងវិញ។ | |

| | |
|---|---|
| ១២ | **ផលប៉ះពាល់ផ្នែកសង្គម៖**<br>- គ្មានផលប៉ះពាល់សង្គម<br>- បង្កើតឧស្សាហកម្មកម្មមន្តសាល និងជំរុញការប្រើប្រាស់ផលិតផលក្នុងស្រុក<br>- បង្កើនប្រាក់ចំណូលពីការនាំចេញ<br>- បង្កើតការងារ កាត់បន្ថយការធ្វើចំណាកស្រុក និងកាត់បន្ថយភាពក្រីក្រ។ |

## អគ្គនាយកដ្ឋានកៅស៊ូ

អាសយដ្ឋាន ៖ ផ្លូវជាតិលេខ៦អា ភូមិបាក់ខែង សង្កាត់ព្រែកលៀប
ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ កម្ពុជា

ទូរសព្ទលេខ ៖ (៨៥៥) ៩៥ ៣៨៨ ៨៦៨

អ៊ីមែល ៖ gdr.maff@gmail.com

គេហទំព័រ ៖ www.gdr1.maff.gov.kh

## GENERAL DIRECTORATE OF RUBBER

Address : National Road No.6A, Phum Bakkheng,
Sangkat Prek Leap, Khan Chroy Changva,
Phnom Penh, Cambodia

Telephone : (855) 95 388 868

Email : gdr.maff@gmail.com

Website : www.gdr1.maff.gov.kh